សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal university of Law and Economics

## សារណាបញ្ចប់ការសិក្សា

# នីតិវិធីក្នុងការទទួលបានសន្តតិកម្មតាមច្បាប់

# (ករណីសន្តតិកម្មគ្មានមតកសាសន៍ និង

# គ្មានធាតុផ្សំបរទេសរួមបញ្ចូល)

ស្រាវជ្រាវចាប់ពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ លោក **ភាំ ថុនា**

កញ្ញា **ហោង គីមស័រ**

ណែនាំដោយ

លោកស្រី **សំណាង ផលដេត**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២៣

ឆ្នាំចូលរៀន ២០១៩

ឆ្នាំសរសេរសារណា ២០២៣

# **សេចក្តីថ្លែងអំណរគុណ**

យើងខ្ញុំឈ្មោះ **កាំ ថុនា** និងឈ្មោះ **ហេង គីមស៊រ** ជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី២៣ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

សូមគោរពប្រតិបត្តិដឹងគុណជាអនេកកប្បការ និងសម្តែងនូវកតញ្ញូតាធម៌យ៉ាងជ្រាវជ្រៅជូនចំពោះ៖

**លោកឪពុកអ្នកម្តាយ** ដែលជាអ្នកមានគុណទាំងទ្វេ ព្រមទាំងលោកតា និងលោកយាយជាទីគោរពដ៏ខ្ពង់ខ្ពស់ ដែលបានផ្តល់កំណើតចិញ្ចឹមបីបាច់ថែរក្សាដល់កូនៗ និងបានខិតខំលះបង់អស់នូវកម្លាំងកាយកម្លាំងចិត្ត ដោយពុំខ្លាចនឿយហត់ក្នុងការអប់រំទូន្មានប្រៀនប្រដៅ ជំរុញលើកទឹកចិត្តកូនចៅ ឱ្យខិតខំប្រឹងប្រែងសិក្សារៀនសូត្រ ក្រេបជញ្ជក់នូវពុទ្ធិចំណេះដឹងសព្វសារពើ ព្រមទាំងបំពេញបន្ថែមនូវចំណុចខ្វះខាត តាំងពីកម្រិតមូលដ្ឋាន រហូតមកដល់ពេលបច្ចុប្បន្ននេះ និងឈានដល់ការបញ្ចប់ថ្នាក់បរិញ្ញាបត្រនាពេលខាងមុខនេះ។

ឯកឧត្តមបណ្ឌិត **លុយ ចន្ទណ្ណា** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលខិតខំលើកស្ទួយនូវគុណភាពអប់រំជំនាញនីតិសាស្ត្រជូនដល់និស្សិតគ្រប់រូប និងជាពិសេសការលើកទឹកចិត្តដល់និស្សិតគាត់តែងសារណាបញ្ចប់ការសិក្សាផងដែរ។

ជាពិសេសសូមគោរពអរគុណដល់លោកស្រីណែនាំ **សំណាង ផលដេត** ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការខិតខំប្រឹងប្រែងដឹកនាំ និងត្រួតពិនិត្យ ដោយមិនខ្លាចនឿយហត់ ចង្អុលបង្ហាញផ្លូវណែនាំ បំពេញបន្ថែម កែប្រែ និងទូន្មាននូវរាល់កំហុសឆ្គងរបស់យើងខ្ញុំ ដើម្បីធានាបានសមិទ្ធផលនៃស្នាដៃមួយដែលប្រកបដោយគុណភាពនេះ។

ទន្ទឹមនឹងនេះដែរ យើងខ្ញុំក៏សូមថ្លែងអំណរគុណដល់ លោកមេធាវី **ហាក់ សុគារិទ្ធ** ប្រធាន **ការិយាល័យមេធាវី ពិស្សុត & សហការី** និងលោកមេធាវី **អ៊ី ចំរើន** ប្រធាន **ក្រុមមេធាវី ស៊ីនហាន** ដែលបានផ្តល់នូវឯកសារពាក់ព័ន្ធសម្រាប់ជាជំនួយនៅក្នុងសារណា និងបានផ្តល់នូវចំណេះដឹងពាក់ព័ន្ធនឹងការអនុវត្តជាក់ស្តែងទាក់ទងនឹងការស្នើសុំទទួលស្គាល់មត៌កទៅតុលាការដែលជាចំណេះដឹងមូលដ្ឋានសំខាន់នៅក្នុងអត្ថបទសារណានេះ។

**លោក លោកស្រី សាស្ត្រាចារ្យ បុគ្គលលិកគ្រប់រូប** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចដែលបានផ្តល់នូវបទពិសោធន៍ដំបូន្មានល្អៗ ព្រមទាំងការបង្ហាត់បង្រៀនយ៉ាងយកចិត្តទុកដាក់ដល់រូបយើងខ្ញុំតាំងពីឆ្នាំសិក្សាមូលដ្ឋានរហូតដល់ពេលបញ្ចប់ថ្នាក់បរិញ្ញាបត្រនេះ។

**សិស្សច្បង និស្សិត និងរៀមច្បង** ក្នុងវិស័យច្បាប់ ដែលបានជួយណែនាំកែសម្រួលនូវអត្ថន័យអក្ខរាវិរុទ្ធ និងផ្តល់នូវប្រភពឯកសារដល់យើងខ្ញុំ រួមទាំងផ្តល់នូវកម្លាំងជំរុញចិត្តដល់យើងខ្ញុំឱ្យខិតខំបន្តការសិក្សាស្រាវជ្រាវនេះរហូតទទួលបានជោគជ័យ។

ជាចុងក្រោយ យើងខ្ញុំសូមគោរពជូនពរ និងសូមលើកហត្ថាទាំងទ្វេប្តូងសួងដល់វត្ថុសក្តិសិទ្ធិទាំងពួងទេវតា សូមជួយតាមថែរក្សា **លោកអ្នកមានគុណទាំងទ្វេ ឯកឧត្តម  លោកប្រធានការិយាល័យមេធាវីទាំងពីររូបលោក លោកស្រីសាស្ត្រាចារ្យ សិស្សច្បង និស្សិត** និង**រៀមច្បង** ដែលបានជួយផ្តល់មតិយោបល់ក្នុងការចងក្រងកិច្ចការសារណារនេះ សូមឱ្យទទួលបានជោគជ័យគ្រប់ភារកិច្ច សេចក្តីសុខ សំណាងល្អ សុខសុវត្ថិភាព និងសូមឱ្យជួបប្រទះតែពុទ្ធពរទាំងបួនប្រការ គឺ**អាយុ វណ្ណៈ សុខៈ** និង**ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ៕

# អារម្ភកថា

ក្នុងរយៈកាល ៤ (បួន) ឆ្នាំ នៃការសិក្សាកម្រិតបរិញ្ញាបត្រកន្លងមក យើងខ្ញុំបានទទួលនូវចំណេះដឹង និងបទពិសោធន៍ជាច្រើន តាមរយៈការសិក្សាដោយផ្ទាល់ និងការសិក្សាពីចម្ងាយ ដោយសារមានការបិទខ្ទប់ក្នុងកំឡុងពេលវិបត្តិនៃជំងឺកូវីដ-19។ ប៉ុន្តែទោះជាបែបនេះក៏ដោយ ការសិក្សាមួយនេះនៅនូវតែទទួលបានប្រសិទ្ធភាពខ្ពស់ ព្រោះមានការយកចិត្តទុកដាក់ពីសំណាក់ រាជរដ្ឋាភិបាល សាលាការិយាធិការ សាស្រ្តាចារ្យ និងមានការចូលរួមពីនិស្សិតគ្រប់រូប។ ដើម្បីជាតាក់តាងបង្ហាញនូវការខិតខំសិក្សា យើងខ្ញុំបានផ្តួចផ្តើមគំនិតសរសេរជាសារណាមួយនេះឡើង ដើម្បីបញ្ចប់ការសិក្សាបរិញ្ញាបត្រជំនាញនីតិសាស្រ្ត និងដើម្បីបង្ហាញពីប្រសិទ្ធភាពនៃការសិក្សាកន្លងមក។

ដោយឡែក ឆ្លងកាត់ការសិក្សានូវមុខវិជ្ជាសំខាន់ៗជាច្រើនក្នុងថ្នាក់បរិញ្ញាបត្រនីតិសាស្រ្តកន្លងមកនេះ យើងខ្ញុំមានចំណាប់អារម្មណ៍យ៉ាងខ្លាំងទៅលើមុខវិជ្ជានីតិរដ្ឋប្បវេណី ព្រោះថាមុខវិជ្ជានេះគឺជាមុខវិជ្ជា ដែលសិក្សាទាក់ទងនឹងទំនាក់ទំនងនៃបុគ្គលឯកជន ដែលពិតជាមានប្រយោជន៍យ៉ាងខ្លាំងសម្រាប់ការរស់នៅក្នុងសង្គម។ បន្ទាប់ពីការធ្វើការសិក្សាយ៉ាងស៊ីជម្រៅលើទំនាក់ទំនងញាតិមក យើងខ្ញុំបានកំណត់សម្គាល់ថា ក្នុងទំនាក់ទំនងញាតិ ត្រូវមានបែងចែកជា២ (ពីរ) គឺទំនាក់ទំនងគ្រួសារ និងទំនាក់ទំនងសន្តតិកម្ម។ យើងខ្ញុំទាំងពីរនាក់ សង្កេតឃើញថា ការស្វែងយល់ពីសិទ្ធិនៃសន្តតិកម្មរបស់ប្រជាពលរដ្ឋខ្មែរនៅមានកម្រិតនូវឡើយ ដូច្នេះដើម្បីជាប្រយោជន៍ដល់សង្គមជាតិ និងជាប្រយោជន៍ដល់អ្នកអានគ្រប់រូប យើងខ្ញុំសម្រេចចិត្តជ្រើសរើសយក ប្រធានបទមួយគឺ **"នីតិវិធីក្នុងការទទួលបានសន្តតិកម្មតាមច្បាប់(ករណីសន្តតិកម្មគ្មានមតកសាសន៍ និងគ្មានធាតុផ្សំបរទេសរួមបញ្ចូល)"** មកធ្វើការសិក្សាស្រាវជ្រាវ។ មូលហេតុ ដែលយើងខ្ញុំសម្រេចចិត្តជ្រើសរើសយកប្រធានបទមួយនេះមកធ្វើការសិក្សាស្រាវជ្រាវ និងចងក្រងឡើងនោះគឺ ដោយសារយើងខ្ញុំមានបំណងក្នុងការទទួលបាននូវបទពិសោធន៍ និងចំណេះដឹងឱ្យកាន់តែស៊ីជម្រៅអំពីផ្នែកសន្តតិកម្ម។ មួយវិញទៀត ប្រធានបទមួយនេះមានសារៈសំខាន់សម្រាប់ការរស់នៅនាបច្ចុប្បន្ន ហើយការចងក្រងឡើងនូវអត្ថបទមួយនេះ នឹងក្លាយជាឯកសារសម្រាប់ការសិក្សាបន្តរបស់ប្អូនៗជំនាន់ក្រោយ។

ដោយហេតុថា បញ្ញត្តិនៃសន្តតិកម្មមានភាពធំទូលាយខ្លាំង ដូច្នេះក្នុងអត្ថបទសារណាមួយនេះ យើងខ្ញុំនឹងសិក្សាស្រាវជ្រាវត្រឹមកម្រិត នីតិវិធីក្នុងការទទួលបានសន្តតិកម្មតាមច្បាប់ (ករណីសន្តតិកម្មដែលគ្មានមតកសាសន៍ និងគ្មានធាតុផ្សំបរទេសរួមបញ្ចូល) តែប៉ុណ្ណោះ។

យើងខ្ញុំ សូមការអធ្យាស្រ័យទុកជាមុនចំពោះកំហុសពាក្យពេជន៍ ឃ្លាឃ្លោង ប្រយោគទាំងឡាយណាដែលប្រើប្រាស់ទៅមានកំហុសឆ្គង និងមិនសមរម្យ។ យើងខ្ញុំនឹងប្តេជ្ញាចិត្តកែលម្អកំហុសដែលកើតឡើងដោយអចេតនា និងទទួលយកការឱ្យមតិយោបល់កែលម្អ ដោយក្តីរីករាយ។

# មាតិកា

ទំព័រ


**ពន្យល់ពាក្យគន្លឹះ** ........................................ v

**សេចក្តីផ្តើម**

**១. លំនាំបញ្ហានៃការស្រាវជ្រាវ** ........................................ ១

**២. ចំណោទបញ្ហានៃការស្រាវជ្រាវ** ........................................ ២

**៣. គោលបំណងនៃការស្រាវជ្រាវ** ........................................ ៣

**៤. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ** ........................................ ៣

**៥. សារៈសំខាន់នៃការស្រាវជ្រាវ** ........................................ ៤

**៦. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ** ........................................ ៤

**ជំពូកទី១**

**សន្តតិកម្មតាមច្បាប់នៅក្នុងក្រមរដ្ឋប្បវេណីជាធរមាន**

**១.១. សញ្ញាណទូទៅនៃសន្តតិកម្មតាមច្បាប់** ........................................ ៥

១.១.១. ការចាប់ផ្តើម និងអានុភាពនៃសន្តតិកម្មតាមច្បាប់ ........................................ ៥

១.១.១.១. ការចាប់ផ្តើមសន្តតិកម្មតាមច្បាប់ ........................................ ៥

ក. មរណភាពរបស់មតកជន ........................................ ៦

ខ. ការប្រកាសអំពីការបាត់ខ្លួន ........................................ ៦

១.១.១.២. អានុភាពនៃសន្តតិកម្មតាមច្បាប់ ........................................ ៧

១.១.២. ការរក្សាទុក និងការគ្រប់គ្រងមត៌ក ........................................ ៧

១.១.៣. លក្ខណៈសម្បត្តិជាសន្តតិជនតាមច្បាប់ ........................................ ៨

១.១.៣.១. សមត្ថភាពទទួលសិទ្ធិ ........................................ ៨

ក. ជនដែលមានជីវិតរស់នៅ ........................................ ៨

ខ. ទារកនៅក្នុងគភ៌ ........................................ ៩

១.១.៣.២. លំដាប់នៃសន្តតិជន ........................................ ៩

ក. សន្តតិជនលំដាប់ទី១ និងសន្តតិជនជំនួស ........................................ ១០

ខ. សន្តតិជនលំដាប់ទី២ ........................................ ១១

គ. សន្តតិជនលំដាប់ទី៣ និងសន្តតិជនជំនួស ........................................ ១១

ឃ. សន្តតិជនជានិច្ច............................................................................................................ ១២
១.១.៣.៣. អភ័ព្វបុគ្គល .................................................................................................................... ១៣
ក. មូលហេតុនាំឱ្យក្លាយជាអភ័ព្វបុគ្គល..................................................................................... ១៣
ខ. ការកាន់កាប់មត៌កដោយអភ័ព្វបុគ្គល ................................................................................... ១៤
១.១.៣.៤. បុគ្គលដែលត្រូវបានផ្តាច់ពីសន្តតិកម្ម ......................................................................... ១៤
ក. មូលហេតុនៃការផ្តាច់មត៌ក និងការតវ៉ា................................................................................ ១៤
ខ. ការកាន់កាប់មត៌កដោយបុគ្គលដែលត្រូវបានផ្តាច់ពីសន្តតិកម្ម............................................... ១៥
គ. ការលុបចោលការផ្តាច់មត៌កពីសន្តតិជន .............................................................................. ១៥
**១.២. ការយល់ព្រម និងការបោះបង់សន្តតិកម្ម** ................................................................................ ១៥
១.២.១. អំឡុងពេលនៃការយល់ព្រម និងបោះបង់សន្តតិកម្មតាមច្បាប់ ........................................... ១៦
១.២.១.១. ករណីសន្តតិជនទទួលមរណភាព.................................................................................. ១៦
១.២.១.២. ករណីសន្តតិជនជាអនីតិជន ជាអាទិ៍ ............................................................................ ១៧
១.២.១.៣. ករណីសន្តតិជនមិនដឹងអំពីអត្ថិភាពនៃកាតព្វកិច្ច............................................................. ១៧
១.២.២. ការយល់ព្រមចំពោះសន្តតិកម្មតាមច្បាប់ ......................................................................... ១៧
១.២.២.១. ការយល់ព្រមទាំងស្រុង និងអានុភាព ............................................................................ ១៧
ក. លក្ខខណ្ឌនៃការយល់ព្រមទាំងស្រុង..................................................................................... ១៧
ខ. អានុភាពក្រោយការយល់ព្រមទាំងស្រុង ................................................................................ ១៨
១.២.២.២. ការយល់ព្រមដោយមានកម្រិត និងអានុភាព.................................................................... ១៩
ក. របៀបយល់ព្រមដោយមានកម្រិត......................................................................................... ១៩
ខ. អានុភាពក្រោយការយល់ព្រមដោយមានកម្រិត....................................................................... ១៩
១.២.៣. ការបោះបង់សន្តតិកម្មតាមច្បាប់....................................................................................... ២២
១.២.៤. ការលុបចោលការបោះបង់សន្តតិកម្មតាមច្បាប់ .................................................................. ២២
**១.៣. ការសម្រួលចំណែកមត៌ក**........................................................................................................ ២២
១.៣.១. ចំណែកមត៌ករបស់អ្នកទទួលផលប្រយោជន៍ពិសេស............................................................ ២២
១.៣.២. ចំណែកមត៌ករបស់អ្នកបានធ្វើវិភាគទាន............................................................................ ២៤
**១.៤. ភាគបម្រុង**............................................................................................................................. ២៥
១.៤.១. បញ្ញត្តិទូទៅស្តីពីភាគបម្រុង ........................................................................................... ២៥

១.៤.១.១. ទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ........................ ២៥
១.៤.១.២. អ្នកមានសិទ្ធិលើភាគបម្រុង ........................ ២៦
១.៤.១.៣. ចំនួនទឹកប្រាក់នៃការទាមទារឱ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ........................ ២៧
១.៤.២. វិធីកាត់បន្ថយ ........................ ២៨
១.៤.២.១. លំដាប់នៃការកាត់បន្ថយប្រទានកម្ម ឬផលប្រយោជន៍ពិសេស ........................ ២៨
១.៤.២.២. អានុភាពក្រោយការកាត់បន្ថយ ........................ ២៩
១.៤.៣. ការរំលត់សិទ្ធិទាមទារឱ្យកាត់បន្ថយ ........................ ២៩
១.៤.៣.១. អាជ្ញាយុកាលនៃការរំលត់សិទ្ធិទាមទារឱ្យកាត់បន្ថយ ........................ ៣០
១.៤.៣.២. ការបោះបង់ភាគបម្រុង ........................ ៣០

## ជំពូកទី២

## ការទទួលបានសន្តតិកម្មតាមច្បាប់

**២.១. ការពិភាក្សាបែងចែកមត៌ក** ........................ ៣១
២.១.១. មូលដ្ឋាននៃការបែងចែក ........................ ៣២
២.១.២. សិទ្ធិអាទិភាពរបស់សហព័ទ្ធ ........................ ៣៣
២.១.៣. សំណងកាតព្វកិច្ចរបស់មតកជន ........................ ៣៣
២.១.៤. អានុភាពនៃការពិភាក្សាបែងចែក ........................ ៣៤
**២.២. ការបែងចែកដោយតុលាការ** ........................ ៣៥
២.២.១. សមត្ថកិច្ចសាលាជម្រះក្តី ........................ ៣៥
២.២.២. ជនពាក់ព័ន្ធ និងអ្នកតំណាងដោយអាណត្តិ ........................ ៣៥
២.២.៣. ប្រាក់ប្រដាប់ក្តី ........................ ៣៦
២.២.៣.១. ពន្ធដាក់ពាក្យសុំ ........................ ៣៦
២.២.៣.២. ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ ........................ ៣៦
២.២.៣.៣. ប្រាក់ប្រដាប់ក្តីភាគី ........................ ៣៧
២.២.៤. ការវិនិច្ឆ័យ ........................ ៣៧
២.២.៤.១. ពាក្យសុំបែងចែកមត៌ក និងចំណុចដែលត្រូវសរសេរក្នុងពាក្យសុំ ........................ ៣៧
២.២.៤.២. ការទាញហេតុផលដោយផ្ទាល់មាត់ ........................ ៣៩
២.២.៥. សេចក្តីសម្រេច ........................ ៤០

២.២.៥.១. ដីកាសម្រេចបែងចែកមត៌ក............................................................................ ៤០
២.២.៥.២. ការជូនដំណឹងអំពីដីកាសម្រេចបែងចែកមត៌ក..................................................... ៤០
២.២.៥.៣. ការចូលជាស្ថាពររបស់ដីកាសម្រេចបែងចែកមត៌ក .............................................. ៤១
២.២.៥.៤. អានុភាពអនុវត្តនៃដីកាសម្រេចបែងចែកមត៌ក ..................................................... ៤១
**សេចក្ដីសន្និដ្ឋាន**.................................................................................................................. ៤២
**អនុសាសន៍**........................................................................................................................... ៤៣
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# ពន្យល់ពាក្យគន្លឹះ

នៅក្នុងសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ក្រោមប្រធានបទ "**នីតិវិធីក្នុងការទទួលបានសន្តតិកម្មតាមច្បាប់(ករណីសន្តតិកម្មគ្មានមតកសាសន៍ និងគ្មានធាតុផ្សំបរទេសរួមបញ្ចូល)**" មួយនេះ នឹងមានការប្រើប្រាស់ពាក្យច្បាប់ និងពាក្យគន្លឹះមួយចំនួនដែលទាមទារការពន្យល់បន្ថែម។ ខាងក្រោមនេះជាការពន្យល់បន្ថែមទៅលើពាក្យច្បាប់ និងពាក្យគន្លឹះដែលនឹងត្រូវប្រើប្រាស់នៅក្នុងលទ្ធផលនៃការស្រាវជ្រាវទៅលើប្រធានបទសារណា ដោយដកស្រង់ចេញពីសទ្ទានុក្រមពាក្យច្បាប់ ខ្មែរ~អង់គ្លេស~បារាំង ផ្នែករដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណី រៀបចំដោយគណៈកម្មការបណ្ឌិតសភាទទួលបន្ទុកអនុម័តពាក្យច្បាប់[1] និងបោះពុម្ពលើកទី១ ឆ្នាំ២០០៧ ដោយទីស្តីការគណៈរដ្ឋមន្ត្រី។

- ករណីយកិច្ចផ្តាច់មុខ ៖ ករណីយកិច្ច ដែលផ្សារភ្ជាប់នឹងបុគ្គលិកលក្ខណៈរបស់បុគ្គលណាមួយដែលមិនអាចត្រូវបានផ្ទេរតាមរយៈសន្តតិកម្ម។
- កាតព្វកិច្ច ៖ ចំណងតាមផ្លូវច្បាប់ ដែលចងបុគ្គលពីរនាក់ដោយឱ្យបុគ្គលម្នាក់ដែលបានកំណត់ហៅថា "កូនបំណុល" មានករណីយកិច្ចមួយចំនួនចំពោះបុគ្គលម្នាក់ទៀតដែលបានកំណត់ហៅថា "ម្ចាស់បំណុល"។
- ក្ស័យធន ៖ ស្ថានភាពដែលកូនបំណុលមិនអាចសងកាតព្វកិច្ចចំពោះម្ចាស់បំណុលទាំងឡាយបាន ដោយសារការដួលរលំនូវសេដ្ឋកិច្ចរបស់ខ្លួន ដែលត្រូវបានប្រកាសដោយតុលាការ។
- ចលនវត្ថុ ៖ វត្ថុទាំងឡាយក្រៅពីអចលនវត្ថុ។
- ញាតិលោហិតខ្សែផ្ទាល់ ៖ ញាតិ ដែលមានឈាមជ័រជាមួយគ្នា ហើយកើតតគ្នាពីមួយទៅមួយតាមលំដាប់ គឺ ឪពុក ម្តាយ កូន ចៅ ចៅទួត។
- តតិយជន ៖ ជនទីបី ឬជន ដែលមិនមែនជាភាគីនៅក្នុងទំនាក់ទំនងគតិយុត្ត។ ជន ដែលមិនមែនជាភាគីក្នុងរឿងក្តីរដ្ឋប្បវេណី។
- ទំនាក់ទំនងគតិយុត្ត ៖ ចំណងកើតឡើងរវាងបុគ្គលពីរនាក់ ឬច្រើននាក់ តាមរយៈកិច្ចគតិយុត្ត ឬបញ្ញត្តិច្បាប់។
- នត្ថិភាព ៖ ភាវៈគ្មាន ឬភាពនៃអ្វីៗ ដែលមិនមាន។
- នីតិជន ៖ ជនដែលមានអាយុចាប់ពី១៨ឆ្នាំឡើងទៅ។

---

[1] គណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់, *សទ្ទានុក្រមពាក្យច្បាប់ ខ្មែរ~អង់គ្លេស~បារាំង ផ្នែករដ្ឋប្បវេណី និង នីតិវិធីរដ្ឋប្បវេណី*, បោះពុម្ពលើកទី១ (កន្លែងបោះពុម្ព៖ ទីស្តីការគណៈរដ្ឋមន្ត្រី), ផ្នែករដ្ឋប្បវេណី, ១, ៣, ៥, ៦, ៧, ៨, ១០, ១២, ១៣, ១៤, ១៥, ១៦, ១៧, ១៩, ២០, ២១, ២២, ២៣, ២៤, ២៥, ២៦, ២៧, ២៨ និង ផ្នែកនីតិវិធីរដ្ឋប្បវេណី, ២, ៨, ១១, ២០, ២៧ ។ (ចាប់ពីពេលនេះតទៅហៅថា "សទ្ទានុក្រមពាក្យច្បាប់ ខ្មែរ~អង់គ្លេស~បារាំង ផ្នែករដ្ឋប្បវេណី និង នីតិវិធីរដ្ឋប្បវេណី")។

- បច្ឆាញាតិផ្ទាល់ ៖ ជន ឬពួកជន ដែលកើតពីជនមួយពួកទៀត។
- បញ្ជីសារពើភ័ណ្ឌ ៖ បញ្ជីទ្រព្យទាំងអស់។
- បដិគ្គាហក ៖ អ្នកទទួលយកទាន(អំណោយ)។ តាមក្រមរដ្ឋប្បវេណី មានន័យថា ភាគីម្ខាងនៃកិច្ច-សន្យាប្រទានកម្ម ដែលយល់ព្រមទទួលយកនូវទ្រព្យសម្បត្តិពីទាយក ដោយមិនផ្តល់តម្លៃតបស្នង។
- បទដ្ឋានគតិយុត្ត ៖ វិធានច្បាប់ដែលនាំឱ្យមានតម្លៃបង្ខិតបង្ខំ (តម្រូវឱ្យអនុវត្តតាម) ទោះបីជាចេញពីប្រភពណាក៏ដោយ(ច្បាប់ សន្ធិសញ្ញា...) ។
- បុព្វជន ៖ ជន ដែលកើតមុនហើយបង្កើតជនមួយពួកទៀត។
- បុព្វញាតិ ៖ ជន ដែលស្ថិតនៅក្នុងថ្នាក់ញាតិខ្ពស់ជាងខ្លួន។
- ប្រទានកម្ម ៖ កិច្ចសន្យា ដែលភាគីម្ខាងបង្ហាញឆន្ទៈផ្តល់ឱ្យទៅភាគីម្ខាងទៀត នូវទ្រព្យសម្បត្តិ ដោយមិនយកថ្លៃ ហើយភាគីម្ខាងទៀតយល់ព្រមទទួល។
- ផលប្រយោជន៍ពិសេស ៖ ទ្រព្យ ដែលបុគ្គល(សន្តតិជន) បានទទួលជាប្រទានកម្ម នៅក្នុងឱកាសអាពាហ៍ពិពាហ៍ ឬហេតុការណ៍ផ្សេងទៀត ឬដើម្បីមូលធននៃជីវភាពរស់នៅ ឬដែលបានទទួលជាអច្ច័យទានពីមតកជន។
- ភាគបម្រុង ៖ ភាគនៃទ្រព្យសម្បត្តិរបស់មតកជន ដែលបច្ឆាញាតិផ្ទាល់ ឬឪពុក ម្តាយ ឬជីដូន ជីតា និងសហព័ទ្ធរបស់មតកជននោះ អាចទាមទារបាន តាមការកំណត់របស់ច្បាប់។
- មត៌ក ៖ ទ្រព្យសម្បត្តិជាកេរទាំងឡាយ ដែលបុគ្គលម្នាក់(មតកជន) បានបន្សល់ទុកក្រោយពេលស្លាប់។
- មតកជន ៖ ជនដែលបានស្លាប់ហើយ។
- មតកសាសន៍ ៖ លិខិតបណ្តាំ ដែលបុគ្គលម្នាក់បានធ្វើឡើងតាមទម្រង់ ដែលកំណត់ដោយច្បាប់ ដើម្បីសំដែងឆន្ទៈចុងក្រោយ អំពីការចាត់ចែងទ្រព្យសម្បត្តិរបស់ខ្លួនជាអាទិ៍ បន្ទាប់ពីមរណភាព។
- រតនសម្បត្តិ ៖ ចលនវត្ថុប្រចាំត្រកូល ដែលជាកេរដំណែលពីបុព្វជន។
- រូបវន្តបុគ្គល ៖ មនុស្សពិតតាមធម្មជាតិ ដែលផ្ទុយនឹងនីតិបុគ្គល។
- លទ្ធកម្ម ៖ ការទទួលបាន។ ការបានឡើងជាម្ចាស់សិទ្ធិនៃវត្ថុណាមួយ ដោយការងាររបស់ខ្លួនក្តី ដោយទិញ ឬដោយដូរក្តី។

- លិខិតយថាភូត ៖ លិខិតធ្វើឡើងតាមរូបមន្តច្បាប់ ដោយមន្ត្រីសាធារណៈដែលត្រូវបានអនុញ្ញាតឱ្យប្រតិបត្តិមុខងារនោះ។ តាមន័យចង្អៀតគឺជា លិខិតទាំងឡាយដែលរៀបចំឡើងដោយសារការី។
- វិការៈ ៖ ការប្រែប្រួលចាកពីភាពប្រក្រតី។
- សច្ចានុមតិ ៖ ការយល់ព្រមទទួលស្គាល់ ដែលមានអានុភាពប្រតិសកម្ម។
- សន្តតិកម្ម ៖ ការផ្ទេរនូវសិទ្ធិ និងករណីយកិច្ចរបស់មតកជនទៅឱ្យសន្តតិជនម្នាក់ ឬច្រើននាក់តាមឆន្ទៈ ឬតាមច្បាប់។
- សន្តតិជន ៖ ជន ដែលទទួលបន្តនូវសិទ្ធិ និងករណីយកិច្ចរបស់មតកជនតាមរយៈសន្តតិកម្ម។
- សហព័ទ្ធ ៖ ប្តី ឬប្រពន្ធ ឬទាំងប្តី ទាំងប្រពន្ធដែលទទួលបានឋានៈជាសហព័ទ្ធនេះក្រោយពីបានចុះបញ្ជីអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់។
- សហសន្តតិជន ៖ អ្នកដែលត្រូវចូលរួមក្នុងការចែកមរតកណាមួយ។
- សិទ្ធិប្រត្យក្ស ៖ សិទ្ធិគ្រប់គ្រងដោយចំពោះលើវត្ថុ ដែលអាចអះអាងចំពោះបុគ្គលដទៃទៀតបាន។
- សុំកូនធម្មតា ៖ ការសុំកូន ដែលកូននោះអាចជាអនីតិជន ឬ នីតិជន ដោយមិនកាត់ផ្តាច់ញាតិភាពពីឪពុកម្តាយបង្កើត ហើយការសុំនេះត្រូវសម្រេចដោយតុលាការ។
- សុំកូនពេញលេញ ៖ ការសុំអនីតិជន ដែលមានអាយុក្រោម៨ឆ្នាំយកធ្វើជាកូនសុំ ដោយបញ្ចប់ញាតិភាពជាមួយនឹងញាតិលោហិតនៃឪពុកម្តាយបង្កើត ហើយការសុំនេះត្រូវសម្រេចដោយតុលាការ។
- ហិតូបត្ថម្ភ ៖ ការគ្រប់គ្រងលើជនដែលមានសមត្ថភាពតិចតួចពេកក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី។
- ហិតូបត្ថម្ភកៈ ៖ ជនដែលតុលាការចាត់តាំងឱ្យអនុវត្តហិតូបត្ថម្ភ។
- អចលនវត្ថុ ៖ ដីធ្លី និងវត្ថុជាប់នៅនឹងដី ហើយមិនអាចផ្លាស់ប្តូរ ទីកន្លែងបានដូចជា អាគារ សំណង់ ដំណាំរុក្ខជាតិ។ល។
- អត្រានុកូលដ្ឋាន ៖ ចំណងរួមភ្ជាប់សញ្ជាតិទៅនឹងរដ្ឋ និងឋានៈនៅក្នុងគ្រសួង ហើយដែលបង្កើតឱ្យមានសិទ្ធិ និងករណីយកិច្ច។
- អនីតិជន ៖ ជន ដែលមិនទាន់គ្រប់អាយុតាមច្បាប់កំណត់ ឬជនដែលមានអាយុក្រោម១៨ឆ្នាំ។
- អនុប្បទាន ៖ ការផ្ទេរសិទ្ធិ ឬទ្រព្យសម្បត្តិរបស់បុគ្គលណាម្នាក់ដែលជាអនុប្បទាយីទៅឱ្យបុគ្គលម្នាក់ទៀតដែលជាអនុប្បទានិក។
- អវិភាគីយ៍ ៖ ដែលមិនអាចបំបែកបាន។

- អាជ្ញាយុកាល ៖ អំឡុងពេលមួយដែលកំណត់ដោយច្បាប់។ ការកន្លងហួសនៃអំឡុងពេលនេះ បង្កើតឱ្យមានអានុភាពនៃលទ្ធកម្ម ឬការរលត់សិទ្ធិណាមួយ។
- អាទិភាព ៖ ភាពខាងដើម ភាពដំបូង ការផ្តល់ប្រៀបឱ្យមុនគេ។
- អានុភាព ៖ ផលគតិយុត្ត ដែលកើតចេញពីលិខិតគតិយុត្ត ដូចជា កិច្ចសន្យា ច្បាប់ សេចក្តីសម្រេចរបស់តុលាការ សេចក្តីសម្រេចរដ្ឋបាល។ល។
- អានុភាពប្រតិសកម្ម ៖ ឥទ្ធិពលទៅលើសកម្មភាពពីអតីតកាល ដោយសកម្មភាពស្របតាមលក្ខខណ្ឌគតិយុត្ត។ អានុភាពនៃលក្ខខណ្ឌគតិយុត្ត ដែលមានទៅលើសកម្មភាពពីអតីតកាល។
- អំណាចមេបា ៖ សិទ្ធិ និងករណីយកិច្ចក្នុងការបីបាច់ថែរក្សាកូន ដែលជាអនីតិជន និងគ្រប់គ្រងលើទ្រព្យសម្បត្តិរបស់កូននោះ។
- ការចុះបញ្ជី ៖ ការកត់ត្រាចូលក្នុងបញ្ជីផ្លូវការ។
- ការជំនុំជម្រះក្តីលើកទី១ ៖ ការជំនុំជម្រះដែលបើកផ្លូវឧទ្ធរណ៍។
- ជននៅក្រោមហិតូបត្ថម្ភ ៖ ជន ដែលមានសមត្ថភាពតិចតួចក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតីហើយត្រូវបានតុលាការដាក់ឱ្យស្ថិតនៅក្រោមការថែទាំដោយហិតូបត្ថម្ភកៈ។
- ជននៅក្រោមអាណាព្យាបាលទូទៅ ៖ នីតិជនដែលស្ថិតនៅក្នុងស្ថានភាពខ្វះសមត្ថភាពក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់ នៃសកម្មភាពរបស់ខ្លួនជានិរន្តរ៍ដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី ហើយត្រូវបានប្រកាសដាក់ឱ្យស្ថិតនៅក្រោមអាណាព្យាបាលទូទៅ។
- តុលាការមានសមត្ថកិច្ច ៖ តុលាការដែលអាចទទួលបានដោយស្របច្បាប់នូវពាក្យបណ្តឹង វិនិច្ឆ័យសេចក្តីលើរឿងក្តី ហើយចេញសាលក្រម ឬសាលដីកាបាន។
- រូបមន្តអនុវត្ត ៖ រូបមន្ត ដែលចុះលើឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត ដែលអនុញ្ញាតឱ្យបុគ្គលដែលមានផលប្រយោជន៍ធ្វើការទាមទារការអនុវត្តដោយបង្ខំ។
- លិខិតអនុវត្ត ៖ ឯកសារផ្លូវការ ដែលជាមូលដ្ឋាននៃការអនុវត្តដោយបង្ខំមាន សាលក្រម ឬ សាលដីកា និងដីកាសម្រេច អនុវត្តសេចក្តីសម្រេចរបស់មជ្ឈត្តករជាដើម។
- អត្ថិភាព ៖ ភាពមាន ភាពកើតមានភាពស្ថិតនៅភាពនៃអ្វីៗ ដែលមាន(ពាក្យអត្ថិភាពផ្ទុយនឹងពាក្យនត្ថិភាព)។
- អ្នកអាណាព្យាបាល ៖ បុគ្គល ដែលអនុវត្តអាណាព្យាបាលភាព។

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

សន្តតិកម្ម គឺជារបបគតិយុត្តមួយបង្កើតឡើងក្នុងគោលបំណងរក្សាស្ថេរភាពនៃទំនាក់ទំនងឯកជន ជាពិសេសគឺសិទ្ធិ និងករណីយកិច្ចទាំងអស់របស់មតកជន ដែលស្ថិតនៅក្រោមទ្រព្យសម្បត្តិរបស់មតកជន ដោយធានានូវសិទ្ធិប្រត្យក្សលើវត្ថុរបស់មតកជន និងសិទ្ធិលើបំណុលដែលម្ចាស់បំណុលមានចំពោះមតកជន ឬដែលមតកជនមានចំពោះកូនបំណុល ក្រោយពេលជនដែលត្រូវបានសន្មតថាជាមតកជននោះទទួលមរណភាព ដើម្បីជៀសវាងនូវស្ថានភាពដែលទ្រព្យសម្បត្តិរបស់មតកជនត្រូវក្លាយជាអចលនវត្ថុដែលគ្មានម្ចាស់[2] ឬចលនវត្ថុដែលគ្មានម្ចាស់[3] ឬក៏សិទ្ធិ និងករណីយកិច្ច ដែលមតកជនមានត្រូវបានរលត់ដោយការបាត់បង់អស់នូវសមត្ថភាពទទួលសិទ្ធិ[4]។ សន្តតិកម្ម គឺជា"ការផ្ទេរនូវសិទ្ធិ និងករណីយកិច្ចរបស់មតកជនទៅឱ្យសន្តតិជនម្នាក់ ឬច្រើននាក់តាមឆន្ទៈ ឬតាមច្បាប់"[5]។ សន្តតិកម្មដែលត្រូវបានធ្វើឡើងដោយផ្អែកតាមបញ្ញត្តិនៃច្បាប់ ហៅថា សន្តតិកម្មតាមច្បាប់ រីឯ សន្តតិកម្មដែលត្រូវបានធ្វើឡើងដោយផ្អែកតាមឆន្ទៈរបស់មតកជន ហៅថា សន្តតិកម្មមានបណ្តាំ។ ក្នុងនោះដែរ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ របស់ព្រះរាជាណាចក្រកម្ពុជាបានជ្រើសយកគោលការណ៍ទទួលបន្តដោយស្វ័យប្រវត្តិមកធ្វើជាមូលដ្ឋាន ដោយបានបញ្ជាក់យ៉ាងច្បាស់នៅក្នុងកថាខណ្ឌទី១ នៃមាត្រា១១៤៧ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។ គោលការណ៍ទទួលបន្តដោយស្វ័យប្រវត្តិនេះ ជាគោលការណ៍ដែលសន្តតិជនត្រូវទទួលទាំងស្រុងនូវសិទ្ធិ និងករណីយកិច្ចទាំងអស់របស់មតកជន លើកលែងតែករណីយកិច្ចផ្តាច់មុខ ដោយមិនឆ្លងកាត់ការជម្រះបញ្ជី។

បទប្បញ្ញត្តិនៃសន្តតិកម្មតាមច្បាប់[6] ត្រូវយកមកអនុវត្តចំពោះករណីដែលមតកជនមិនបានបន្សល់ទុកនូវមតកសាសន៍ក្រោយពេលជនដែលត្រូវបានសន្មតថាជាសន្តតិជនទទួលមរណភាព ឬលិខិតមតកសាសន៍ដែលបានធ្វើខុសពីទម្រង់ដែលច្បាប់កំណត់។ សន្តតិកម្មតាមច្បាប់ទាមទារនូវការពិភាក្សាបែងចែកមត៌ក[7] ឬការបែងចែកដោយតុលាការតាមរយៈនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង[8] ដើម្បីបានទទួលបន្តនូវសិទ្ធិ និងករណីយកិច្ច ដែលស្ថិតនៅក្រោមទ្រព្យសម្បត្តិរបស់មតកជន ក្នុងទំហំទាំងអស់នៃចំណែកមត៌កករណី

[2] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១៦១។ (ចាប់ពីពេលនេះតទៅហៅថា "ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧") ។

[3] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១៨៨។

[4] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ៨។

[5] សទ្ទានុក្រមពាក្យច្បាប់ ខ្មែរ-អង់គ្លេស-បារាំង ផ្នែករដ្ឋប្បវេណី និង នីតិវិធីរដ្ឋប្បវេណី, ២១។

[6] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, គន្ថីទី៨។

[7] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១២៦៦ថ្មី។

[8] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១២៧០។

មានតែសន្តតិជន ឬក្នុងទំហំតាមសមាមាត្រនៃចំណែកមត៌កករណីមានសហសន្តតិជន។ ក៏ប៉ុន្តែដោយសារតែក្រមរដ្ឋប្បវេណីដែលកំពុងនៅជាធរមានរបស់ព្រះរាជាណាចក្រកម្ពុជាមានអានុភាពអនុវត្តនៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១[9]។ ដូច្នេះហើយ ដោយយោងតាមមាត្រា៥ ស្តីពីគោលការណ៍នៃការអនុវត្តក្រមរដ្ឋប្បវេណី និងមាត្រា៧១ ស្តីពីការអនុវត្តបញ្ញត្តិស្តីពីសន្តតិកម្ម នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី គ្រប់បញ្ញត្តិដែលពាក់ព័ន្ធសន្តតិកម្មនឹងត្រូវយកអនុវត្តចំពោះគ្រប់ករណីដែលសន្តតិកម្មត្រូវបានចាប់ផ្តើមក្រោយកាលបរិច្ឆេទនៃការអនុវត្ត[10] ព្រមទាំងត្រូវអនុវត្តចំពោះហេតុការណ៍ទាំងឡាយមានដូចជា មូលហេតុអភ័ព្វបុគ្គលនៃសន្តតិកម្ម មូលហេតុនៃការផ្តាច់មត៌កពីសន្តតិជន ផលប្រយោជន៍ពិសេស ភាគនៃវិភាគជាដើម ដែលបានកើតឡើងមុនកាលបរិច្ឆេទនៃការអនុវត្ត។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ដោយហេតុថា របបសន្តតិកម្មតាមច្បាប់ជាជម្រើសដែលច្បាប់បង្កើតឡើងដើម្បីការពារផលប្រយោជន៍របស់សន្តតិជន ឬម្ចាស់បំណុលរបស់មតកជន ក៏ដូចជាសិទ្ធិ និងករណីយកិច្ច ដែលស្ថិតនៅក្រោមទ្រព្យសម្បត្តិរបស់មតកជន នៅពេលណាដែលមតកជននោះបានទទួលមរណភាពដោយមិនបានបន្សល់ទុកបណ្តាំមត៌ក ឬមតកសាសន៍ ជាពិសេស គឺធានាឱ្យបាននូវស្ថេរភាពគតិយុត្តនៅក្នុងទំនាក់ទំនងឯកជន។ បន្ថែមពីនេះ ប្រជាជនកម្ពុជាភាគច្រើនមានផ្នត់គំនិតមិនល្អចំពោះការធ្វើបណ្តាំមត៌ក ឬមតកសាសន៍នេះ ដោយសារពួកគាត់គិតថាការធ្វើបណ្តាំមត៌កគឺជាការដាក់បណ្តាសាដល់ខ្លួនឱ្យឆាប់ស្លាប់ ឬការប្រមាថមើលងាយជីវិតរបស់ខ្លួនឯង។ ហេតុដូច្នេះហើយ ស្ថានភាពដែលមតកជនបានស្លាប់ដោយមិនបន្សល់ទុកមតកសាសន៍កើតមានឡើងយ៉ាងច្រើននៅក្នុងសង្គមកម្ពុជា។ ជាងនេះទៅទៀត កង្វះនៃការយល់ដឹងឱ្យស៊ីជម្រៅទៅលើអត្ថបទច្បាប់ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធធ្វើឱ្យសកម្មភាពមួយចំនួនរបស់សន្តតិជននៃសន្តតិកម្មមានលក្ខណៈខ្វះចន្លោះ និងមិនបំពេញលក្ខខណ្ឌដែលច្បាប់តម្រូវ។

ហេតុដូចនេះហើយ អត្ថបទសារណាបញ្ចប់ការសិក្សានេះនឹងធ្វើការបកស្រាយបង្ហាញផ្តោតតែទៅលើនីតិវិធីក្នុងការទទួលបានសន្តតិកម្មតាមច្បាប់(ករណីសន្តតិកម្មគ្មានមតកសាសន៍ និងគ្មានធាតុផ្សំបរទេសរួមបញ្ចូល) ប៉ុណ្ណោះ។ ក្នុងនោះដែរ ចំណោទបញ្ហាដែលចោទឡើង ហើយទាមទារនូវដំណោះស្រាយរួមមាន៖

- តើសន្តតិកម្មតាមច្បាប់ដែលកំណត់ក្នុងក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មានអត្ថន័យបែបណាខ្លះ?
- តើមាននីតិវិធីអ្វីខ្លះដែលសន្តតិជន ឬសហសន្តតិជនត្រូវបំពេញ ដើម្បីទទួលបានចំណែកមត៌កដែលបានកំណត់ដោយក្រមរដ្ឋប្បវេណីឆ្នាំ២០០៧?

---

[9] ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី, លេខ នស/រកម/០៥១១/០០៧, ៣១ ឧសភា ២០១១, មាត្រា ៤, មាត្រា ៨៤។ (ចាប់ពីពេលនេះតទៅហៅថា "ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី") ។

[10] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១១៤៥ កថាខណ្ឌទី១ និង មាត្រា ៤៣។

## ៣. គោលបំណងនៃការស្រាវជ្រាវ

អត្ថបទសារណាដែលស្រាវជ្រាវទៅប្រធានបទ "**នីតិវិធីក្នុងការទទួលបានសន្តតិកម្មតាមច្បាប់(ករណីសន្តតិកម្មគ្មានមតកសាសន៍ និងគ្មានជាតុផ្សំបរទេសរួមបញ្ចូល)**" នេះមានគោលបំណង៖

- បង្ហាញអំពីសញ្ញាណនៃសន្តតិកម្មតាមច្បាប់
- បង្ហាញពីលក្ខណៈសម្បត្តិជាសន្តតិជន និងពីជនដែលត្រូវសន្មតថាជាសន្តតិជនតាមលំដាប់ច្បាប់
- បង្ហាញពីការគ្រប់គ្រងមត៌កមុនពេលមានការបែងចែក
- បង្ហាញពីការយល់ព្រម និងការបោះបង់សន្តតិកម្ម
- បង្ហាញវិធីក្នុងការសម្រួលចំណែកមត៌ក
- បង្ហាញការធ្វើបណ្ដឹងទាមទារឱ្យបញ្ជាក់អំពីអត្ថិភាព ឬនត្ថិភាពនៃសន្តតិជន តាមរយៈនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល
- បង្ហាញការធ្វើបណ្ដឹងទាមទារឱ្យបញ្ជាក់អំពីទំហំមត៌ក តាមរយៈនីតិវិធីរឿងក្ដីរដ្ឋប្បវេណី
- បង្ហាញពីការពិភាក្សាបែងចែកមត៌ករវាងសហសន្តតិជន
- បង្ហាញពីការបែងចែកមត៌កដោយតុលាការ តាមរយៈនីតិវិធីរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង
- ធ្វើការឆ្លើយតបទៅនឹងស្ថានភាពសង្គម ក្នុងករណីដែលប្រជាជនទូទៅទទួលមរណភាពដោយមិនបានបន្សល់ទុកនូវបណ្ដាំមត៌ក ឬមតកសាសន៍
- តម្កល់ជាឯកសារសម្រាប់បញ្ញវន្តអ្នកសិក្សាច្បាប់ និងប្រជាជនទូទៅសិក្សាស្វែងយល់ ឬបំពេញបន្ថែមចំណេះដឹង

## ៤. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

យើងសង្កេតឃើញថា យោងតាមក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ សន្តតិកម្មត្រូវបានបែងចែកជាពីរប្រភេទ គឺសន្តតិកម្មតាមច្បាប់ និងសន្តតិកម្មមានបណ្ដាំ។ ដោយហេតុថា សន្តតិកម្មទាំងពីរប្រភេទមានវិសាលភាពធំ និងគ្រប់ដណ្ដប់លើស្ថានភាពច្រើនប្រភេទខុសៗគ្នា។ ដូច្នេះហើយ ចំពោះអត្ថបទសារណាមួយនេះ យើងនឹងធ្វើការសិក្សាស្រាវជ្រាវផ្ដោតទៅលើនីតិវិធីក្នុងការទទួលបានសន្តតិកម្មតាមច្បាប់(**ករណីសន្តតិកម្មគ្មានមតកសាសន៍ និងគ្មានជាតុផ្សំបរទេសរួមបញ្ចូល)** ដែលអត្ថបទសារណានេះនឹងមានបង្ហាញអំពីសញ្ញាណពាក់ព័ន្ធនឹងសន្តតិកម្មតាមច្បាប់ក្នុងច្បាប់សារធាតុ ហើយមានបន្ថែមនូវនីតិវិធីនៃការជម្រះក្ដីលើកទីមួយដើម្បីអនុញ្ញាតឱ្យសន្តតិជន ឬសហសន្តតិជន ដែលត្រូវសន្មតថាមានអត្ថិភាពនៅទីនេះទទួលបានមត៌កតាមចំណែកខ្លួន និងស្របតាមច្បាប់។ ផ្ទុយទៅវិញ អត្ថបទសារណានេះនឹងមិនមានការស្រាវជ្រាវបង្ហាញអំពីខ្លឹមសារពាក់ព័ន្ធនឹងសន្តតិកម្មតាមបណ្ដាំ ឬ

ការរួមបញ្ចូលពាក់ព័ន្ធគ្នារវាងខ្លឹមសារនៃសន្តតិកម្មតាមច្បាប់ ជាមួយនឹងខ្លឹមសារនៃសន្តតិកម្មតាមបណ្តាំ ឬមានការរួមបញ្ចូលនូវធាតុផ្សំបរទេសណាមួយចូលក្នុងសន្តតិកម្មតាមច្បាប់ចំពោះប្រធានបទសារណានេះនោះទេ។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវអំពីប្រធានបទ "**នីតិវិធីក្នុងការទទួលបានសន្តតិកម្មតាមច្បាប់ (ករណីសន្តតិកម្មគ្មានមតកសាសន៍ និងគ្មានធាតុផ្សំបរទេសរួមបញ្ចូល)**" ផ្តល់នូវឧត្តមប្រយោជន៍យ៉ាងច្រើនដល់និស្សិត និងប្រជាពលរដ្ឋទូទៅដែលសិក្សាស្រាវជ្រាវលើវិស័យច្បាប់ រួមមានដូចជា ការយល់ដឹងអំពីការចាត់បែងទ្រព្យសម្បត្តិនៅពេលមានមុនស្សស្លាប់ ថាតើច្បាប់ធ្វើការបែងចែងទ្រព្យសម្បត្តិយ៉ាងដូចម្តេចនៅពេលមានមនុស្សស្លាប់? តើនរណាខ្លះអាចទទួលមកត៌បាន? តើធ្វើដូចម្តេចទើបអាចទទួលបានមតក៌ពីមតកជនស្របតាមច្បាប់?

## ៦. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ចំពោះប្រធាននីតិវិធីក្នុងការទទួលបានសន្តតិកម្មតាមច្បាប់(ករណីសន្តតិកម្មគ្មានមតកសាសន៍ និងគ្មានធាតុផ្សំបរទេសរួមបញ្ចូល) យើងខ្ញុំនឹងធ្វើការបកស្រាយបែងចែកជាពីរជំពូកសំខាន់៖

ជំពូកទី១ សន្តតិកម្មតាមច្បាប់នៅក្នុងក្រមរដ្ឋប្បវេណីជាធរមាន

ជំពូកទី២ ការទទួលបានសន្តតិកម្មតាមច្បាប់

# ជំពូកទី១

# សន្តិកម្មតាមច្បាប់

# នៅក្នុងក្រុមរដ្ឋប្បវេណីជាធរមាន

# ជំពូកទី១
# សន្តតិកម្មតាមច្បាប់នៅក្នុងក្រមរដ្ឋប្បវេណីជាធរមាន

នៅក្នុងស្ថានភាពមួយដែលមតកជនមិនបានបន្សល់ទុកបណ្តាំ ឬមតកសាសន៍ ឬស្ថានភាពដែលបណ្តាំ ឬមតកសាសន៍នោះមិនបានបំពេញតាមលក្ខខណ្ឌច្បាប់ នោះស្មារតីនៃក្រមរដ្ឋប្បវេណីដែលនៅជាធរមានបានកំណត់ថាសិទ្ធិ និងករណីយកិច្ចទាំងអស់ ដែលស្ថិតនៅក្រោមទ្រព្យសម្បត្តិរបស់មតកជន ត្រូវធ្វើការចាត់ចែងដោយផ្អែកតាមបទប្បញ្ញត្តិស្តីពីសន្តតិកម្មតាមច្បាប់។ ក្រមរដ្ឋប្បវេណីបញ្ញត្តិតែអំពីសញ្ញាណជាសារធាតុទាក់ទងនឹងសន្តតិកម្មតាមច្បាប់ ដោយមិនមានកំណត់នូវនីតិវិធីសម្រាប់អនុវត្តនោះទេ។ ដូច្នេះហើយ នៅក្នុងជំពូកទី១ នេះ យើងនឹងសិក្សាបង្ហាញជារួមនូវសញ្ញាណនានាដែលពាក់ព័ន្ធនឹងសន្តតិកម្មតាមច្បាប់ ដោយជាដំបូងចាប់ផ្តើមពីសញ្ញាណទូទៅនៃសន្តតិកម្មតាមច្បាប់(**ចំណុច ១.១**) រួចបន្តទៅ ការយល់ព្រម និងការបោះបង់សន្តតិកម្មតាមច្បាប់(**ចំណុច ១.២**) ក៏ដូចជាការសម្រួលចំណែកមត៌ក(**ចំណុច ១.៣**) និងចុងបញ្ចប់ទៅលើភាគបម្រុង(**ចំណុច ១.៤**)។

## ១.១. សញ្ញាណទូទៅនៃសន្តតិកម្មតាមច្បាប់

សន្តតិកម្មតាមច្បាប់ ជាសញ្ញាណដែលមានលក្ខណៈស្មុគស្មាញ និងពិសេសដោយឡែកមួយ យើងអាចនិយាយថាសញ្ញាណនេះមានការរួមបញ្ចូលគ្នាទាំងទំនាក់ទំនងញាតិ និងទំនាក់ទំនងទ្រព្យសម្បត្តិ។ បន្ថែមពីនេះទៀត សញ្ញាណនេះកើតឡើងនៅក្រោយពេលមរណភាពរបស់ជនដែលត្រូវបានសន្មតថាជាមតកជនដែលទាមទារនូវការកំណត់ឱ្យបានច្បាស់លាស់ជាមុននៅក្នុងច្បាប់ ដើម្បីការពារនូវសិទ្ធិរបស់បុគ្គលពាក់ព័ន្ធ។ ដូច្នេះនៅក្នុងចំណុចនេះយើងនឹងធ្វើការសិក្សាស្រាវជ្រាវលើសញ្ញាណទូទៅពាក់ព័ន្ធនឹងសន្តតិកម្មតាមច្បាប់រួមមានការចាប់ផ្តើម និងអានុភាពនៃសន្តតិកម្មតាមច្បាប់(**១.១.១**) ការរក្សាទុក និងការគ្រប់គ្រងមត៌ក(**១.១.២**) និងលក្ខណៈសម្បត្តិជាសន្តតិជនតាមច្បាប់(**១.១.៣**)។

### ១.១.១. ការចាប់ផ្តើម និងអានុភាពនៃសន្តតិកម្មតាមច្បាប់

ចំណុចនេះនឹងធ្វើការបង្ហាញពីលក្ខខណ្ឌដែលនាំឱ្យមានការចាប់ផ្តើមសន្តតិកម្មតាមច្បាប់(**១.១.១.១**) និងអានុភាពនៃសន្តតិកម្មតាមច្បាប់(**១.១.១.២**)។

#### ១.១.១.១. ការចាប់ផ្តើមសន្តតិកម្មតាមច្បាប់

សន្តតិកម្មតាមច្បាប់ត្រូវចាប់ផ្តើមដោយមរណភាពរបស់មតកជន[11]និងដោយអានុភាពនៃការប្រកាសពីការបាត់ខ្លួន[12]នៅលំនៅឋានរបស់មតកជន[13]។

[11] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១១៤៥ កថាខណ្ឌទី១។

[12] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ៤៣។

[13] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១១៤៦។

### ក. មរណភាពរបស់មតកជន

នៅក្នុងក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មិនមានការឱ្យនិយមន័យពីពាក្យថាមរណភាពនោះទេ ប៉ុន្តែយើងអាចកំណត់បកស្រាយតាមវិធីពីរបែប គឺវិធីទីមួយ តាមនិយមន័យរបស់វចនានុក្រមខ្មែរ ពាក្យថា **មរណភាព** មានថ្នាក់ពាក្យជានាមសព្ទ មានន័យថា "ដំណើរស្លាប់ សេចក្ដីស្លាប់" ហើយពាក្យថា **ស្លាប់** មានថ្នាក់ពាក្យជាកិរិយាសព្ទ មានន័យថា "អស់ខ្យល់ដង្ហើម អស់ជីវិត"។ វិធីទីពីរ **មរណភាព** "តាមទំនៀមទម្លាប់ គឺជាពេលដែលសួត បេះដូង ខួរក្បាលឈប់មានដំណើរការ ហើយគេបញ្ជាក់មរណភាពដោយពិនិត្យមើល ការអស់ដង្ហើម បេះដូងឈប់លោត និងការរីកនៃប្រស្រីភ្នែក ព្រមទាំងភាពគ្មានប្រតិកម្មនឹងពន្លឺ"[14]។

នៅពេលដែលមតកជនទទួលមរណភាព នោះមតកជនត្រូវបាត់បង់អស់នូវសមត្ថភាពទទួល ដូច្នេះហើយទើបច្បាប់បានកំណត់ថា "សន្តតិកម្ម ត្រូវចាប់ផ្ដើមដោយមរណភាពរបស់មតកជន។"[15] តាមន័យនេះ គឺច្បាប់មិនទទួលស្គាល់សន្តតិកម្មនៅពេលដែលមតកជននៅរស់នោះទេ។

### ខ. ការប្រកាសអំពីការបាត់ខ្លួន

ការប្រកាសអំពីការបាត់ខ្លួនអាចធ្វើឡើងក្រោមស្ថានភាពពីរផ្សេងគ្នា ដោយស្ថានភាពទីមួយ គឺករណីធម្មតា រីឯស្ថានភាពទីពីរ គឺករណីពិសេស។[16]

ចំពោះស្ថានភាពទីមួយ ជាល័ក្ខខ័ណ្ឌប្រសិនបើពុំមានដំណឹងច្បាស់លាស់ថា អ្នកអវត្តមាននៅរស់ ឬទទួលមរណភាពក្នុងអំឡុងពេល ៥ ឆ្នាំ នោះជនដែលមានទំនាក់ទំនងពាក់ព័ន្ធនឹងអ្នកអវត្តមានដែលរួមមានដូចជា សហព័ទ្ធ អ្នកដែលត្រូវបានសន្មតថាជាសន្តតិជន អច្ច័យលាភី អ្នកទទួលប្រាក់ធានារ៉ាប់រង អ្នកមានសិទ្ធិអំណាចមេបា អ្នកអាណាព្យាបាល ឪពុកម្ដាយ ឬអ្នកផ្សេងទៀតដែលមានផលប្រយោជន៍សំខាន់តាមផ្លូវច្បាប់ក្នុងការប្រកាសអំពីការបាត់ខ្លួន អាចដាក់ពាក្យសុំទៅតុលាការ ដើម្បីប្រកាសអំពីការបាត់ខ្លួនបាន។[17]

ចំពោះស្ថានភាពទីពីរ ជាល័ក្ខខ័ណ្ឌប្រសិនបើអ្នកអវត្តមាននោះបានចូលទៅតំបន់ដែលមានសង្គ្រាម ឬបុគ្គលដែលមានវត្តមាននៅក្នុងនាវាដែលបានលិច ឬបុគ្គលដែលបានជួបប្រទះនឹងគ្រោះថ្នាក់ផ្សេងទៀតដែលអាចនាំឱ្យទទួលមរណភាព ហើយពុំមានដំណឹងច្បាស់លាស់ថា អ្នកអវត្តមាននៅរស់ ឬទទួលមរណភាពក្នុងអំឡុងពេល ១ ឆ្នាំ ក្រោយពីស្ថានភាពខាងលើបានបញ្ចប់ នោះជនដែលមានទំនាក់ទំនងពាក់ព័ន្ធនឹងអ្នកអវត្តមានដែលរួមមានដូចជា សហព័ទ្ធ អ្នកដែលត្រូវបានសន្មតថាជាសន្តតិជន អច្ច័យលាភី អ្នកទទួលប្រាក់ធានារ៉ាប់រងអ្នកមាន

[14] គណៈកម្មការទទួលបន្ទុកការពារសេចក្ដីព្រាងក្រមរដ្ឋប្បវេណី និងក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្ដីព្រាងក្រមរដ្ឋប្បវេណី, *សេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី*, ភាគ១, *គន្ថីទី១-ទី៣* (ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០០៩), ៦។

[15] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១១៤៥ កថាខណ្ឌទី១។

[16] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ៤១។

[17] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ៤១ កថាខណ្ឌទី១។

សិទ្ធិអំណាចមេបា អ្នកអាណាព្យាបាល ឪពុកម្ដាយ ឬអ្នកផ្សេងទៀតដែលមានផលប្រយោជន៍សំខាន់តាមផ្លូវច្បាប់ ក្នុងការប្រកាសអំពីការបាត់ខ្លួន អាចដាក់ពាក្យសុំទៅតុលាការ ដើម្បីប្រកាសអំពីការបាត់ខ្លួនបាន[18]។

ក្រោយពីការបាត់ខ្លួនត្រូវបានប្រកាស អ្នកបាត់ខ្លួនត្រូវបានចាត់ទុកថាបានទទួលមរណភាព[19]។

#### ១.១.១.២. អានុភាពនៃសន្តតិកម្មតាមច្បាប់

សន្តតិកម្មតាមច្បាប់មានអានុភាពនាំឱ្យសន្តតិជនម្នាក់ទទួលបន្តនូវមត៌ក [20] ឬសន្តតិជនច្រើននាក់ទទួលបន្តនូវមត៌ក[21] ចាប់ពីពេលដែលចាប់ផ្ដើមសន្តតិកម្ម។ លើកលែងតែសិទ្ធិ និងករណីយកិច្ចផ្ដាច់មុខទាំងស្រុងរបស់មតកជនដែលមិនអាចទទួលបន្តតាមរយៈសន្តតិកម្ម ព្រមទាំងកម្មសិទ្ធិលើវត្ថុសម្រាប់ជំនឿសាសនា និងចេតិយ ឬចលនវត្ថុដែលជារតនសម្បត្តិគ្រួសារនៃបុព្វជនដែលត្រូវទទួលបន្តតាមការកំណត់របស់មតកជន ឬបើមតកជនមិនបានកំណត់ទេជនដែលត្រូវដឹកនាំពិធីបុណ្យនៃបុព្វជនត្រូវទទួលបន្តនូវកម្មសិទ្ធិទាំងនោះ ដោយយោងតាមទំនៀមទម្លាប់ ឬតាមការកំណត់របស់តុលាការ[22]។

ក្នុងករណីដែលមានសន្តតិជនតែម្នាក់ សន្តតិជននោះត្រូវទទួលបន្តនូវសិទ្ធិ និងករណីយកិច្ចទាំងអស់ដែលស្ថិតនៅក្រោមទ្រព្យសម្បត្តិរបស់មតកជន[23]។ ដោយឡែកចំពោះករណីដែលមានសន្តតិជនច្រើននាក់ នោះសហសន្តតិជនម្នាក់ៗត្រូវទទួលបន្តនូវសិទ្ធិ និងករណីយកិច្ច តាមសមាមាត្រនៃចំណែកមត៌កនោះ។ ប៉ុន្តែ ប្រសិនបើសិទ្ធិ ឬករណីយកិច្ចដែលមិនអាចបែងចែកបាន តាមលក្ខណៈនៃសិទ្ធិ ឬករណីយកិច្ចនោះ សហសន្តតិជនត្រូវទទួលបន្តដោយអវិភាគីយ៍។ ក្នុងករណីដែលមានសន្តតិជនច្រើននាក់ មុនពេលមានការបែងចែកមត៌ក មត៌កនេះត្រូវស្ថិតនៅក្រោមកម្មសិទ្ធិអវិភាគរបស់សហសន្តតិជន[24]។

### ១.១.២. ការរក្សាទុក និងការគ្រប់គ្រងមត៌ក

ការរក្សាទុក និងការគ្រប់គ្រងមត៌កជាវិធីមួយដែលធ្វើឡើងដើម្បីថែរក្សាទ្រព្យសម្បត្តិរបស់មតកជនក្រោយពេលស្លាប់ឱ្យស្ថិតនៅស្ថានភាពដដែល ចំពោះករណីពីរផ្សេងគ្នា គឺទីមួយករណីសន្តតិកម្មមានតែសន្តតិជន និងទីពីរករណីសន្តតិកម្មមានសហសន្តតិជន។

---

[18] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ៤១ កថាខណ្ឌទី២។
[19] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ៤៣។
[20] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១១៤៧។
[21] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១១៤៨។
[22] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១១៤៧។
[23] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១១៤៧ កថាខណ្ឌទី១។
[24] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១១៤៨។

ចំពោះករណីទីមួយដែលសន្តតិកម្មមានតែសន្តតិជន នោះសន្តតិជនដែលកំពុងកាន់កាប់មត៌ក នៅពេលមតកជនទទួលមរណភាពត្រូវរក្សាទុក និងគ្រប់គ្រងមត៌កទាំងនោះរហូតដល់ពេលធ្វើការបែងចែកមត៌ក[25]។

ចំពោះករណីទីពីរដែលសន្តតិកម្មមានសហសន្តតិជន នោះសន្តតិជនដែលកំពុងកាន់កាប់មត៌ក នៅពេលមតកជនទទួលមរណភាពត្រូវរក្សាទុក និងគ្រប់គ្រងមត៌កទាំងនោះ រីឯចំពោះមត៌កដែលមិនត្រូវបានកាន់កាប់ដោយសន្តតិជនណាម្នាក់ទេ នោះសហសន្តតិជនត្រូវរក្សាទុក និងគ្រប់គ្រងជាមួយគ្នា[26]។

### ១.១.៣. លក្ខណៈសម្បត្តិជាសន្តតិជនតាមច្បាប់

ដើម្បីអាចកំណត់ថាបុគ្គលណាម្នាក់មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាសន្តតិជន លុះត្រាតែបុគ្គលនោះមានជីវិតរស់នៅនាពេលចាប់ផ្តើមសន្តតិកម្ម ឬអាចហៅម្យ៉ាងទៀតថាមានសមត្ថភាពទទួលសិទ្ធិនាពេលចាប់ផ្តើមសន្តតិកម្ម(**១.១.៣.១**) ហើយលុះត្រាតែបុគ្គលនោះស្ថិតនៅក្នុងលំដាប់នៃសន្តតិជនដែលច្បាប់បានកំណត់(**១.១.៣.២**) ផ្ទុយទៅវិញបុគ្គលដែលជាអភ័ព្វបុគ្គល(**១.១.៣.៣**) និងបុគ្គលដែលត្រូវបានផ្តាច់ពីសន្តតិកម្ម(**១.១.៣.៤**) ពុំអាចក្លាយជាសន្តតិជនបានទេ[27]។

#### ១.១.៣.១. សមត្ថភាពទទួលសិទ្ធិ

សមត្ថភាពទទួលសិទ្ធិគឺជា "លក្ខណសម្បត្តិដែលអាចក្លាយជាម្ចាស់សិទ្ធិ និងកាតព្វកិច្ច"[28]។ យោងតាមមាត្រា ៦ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ "រូបវន្តបុគ្គលគ្រប់រូបមានលក្ខណសម្បត្តិអាចក្លាយជាប្រធាននៃសិទ្ធិ និងកាតព្វកិច្ចបាន"។ ជាគោលការណ៍ "រូបវន្តបុគ្គលម្នាក់ៗមានសមត្ថភាពទទួលសិទ្ធិនៅពេលចាប់កំណើត ហើយបាត់បង់អស់នូវសមត្ថភាពទទួលសិទ្ធិនេះ នៅពេលទទួលមរណភាព"[29]។ ដូច្នេះ លក្ខណៈទីមួយដើម្បីឱ្យបុគ្គលណាម្នាក់អាចក្លាយជាសន្តតិជនតាមច្បាប់ គឺជននោះចាំបាច់ត្រូវមានជីវិតរស់នៅនាពេលចាប់ផ្តើមសន្តតិកម្ម ប៉ុន្តែគោលការណ៍ខាងលើមានអញ្ញត្រកម្មចំពោះទារកនៅក្នុងគភ៌។

##### ក. ជនដែលមានជីវិតរស់នៅ

ដោយហេតុថា សន្តតិកម្ម គឺជាសិទ្ធិដែលអនុញ្ញាតឱ្យសន្តតិជនអាចទទួលបន្តនូវមត៌កពីមតកជនបាន ដូច្នេះហើយជាគោលការណ៍ ជនដែលត្រូវសន្មតថាជាសន្តតិជនចាំបាច់ត្រូវតែមានជីវិតរស់នៅនាពេលចាប់ផ្តើមសន្តតិកម្ម ទើបជននោះមានសមត្ថភាពទទួលបន្តនូវសិទ្ធិ និងករណីយកិច្ចបន្តពីមតកជនបាន[30]។

---

[25] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១២៦២ កថាខណ្ឌទី១ វាក្យខណ្ឌទី១។

[26] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១២៦២ កថាខណ្ឌទី១ វាក្យខណ្ឌទី១។

[27] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១១៤៩ កថាខណ្ឌទី១។

[28] សន្ទានុក្រមពាក្យច្បាប់ ខ្មែរ~អង់គ្លេស~បារាំង ផ្នែករដ្ឋប្បវេណី និង នីតិវិធីរដ្ឋប្បវេណី, ២១។

[29] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ៨។

[30] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១១៤៩ កថាខណ្ឌទី១។

**ខ. ទារកនៅក្នុងគភ៌**

មានការចែងផ្ទុយពីចំណុច ក ខាងលើ ចំពោះទារកដែលនៅក្នុងគភ៌។ ថ្វីត្បិតតែ ទារកនោះពុំទាន់ចាប់កំណើតមកក៏ដោយ ឬអាចនិយាយបានថាពុំទាន់មានសមត្ថភាពទទួលសិទ្ធិ ដើម្បីអាចទទួលបន្តនូវមត៌កពីមតកជនបានទេ[31]។ ប៉ុន្តែ ការចែងកំណត់បែបនេះមានភាពមិនសមរម្យ និងផ្តល់ផលប៉ះពាល់យ៉ាងខ្លាំងចំពោះផលប្រយោជន៍របស់ទារកដែលនៅក្នុងគភ៌ពាក់ព័ន្ធនឹងការទទួលបន្តនូវមត៌កតាមរយៈសន្តតិកម្ម បើគេអាចសន្និដ្ឋានបានថាទារកនោះនឹងមានកំណើតឆាប់ៗនាពេលខាងមុខ។ ដូច្នេះហើយ ដើម្បីឆ្លើយតបទៅនឹងស្ថានភាពខាងលើនេះ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មានការកំណត់ជាអញ្ញត្រកម្មក្នុងកថាខណ្ឌទី២ នៃមាត្រា ៩ ថា "ទារកដែលនៅក្នុងគភ៌នាពេលដែលចាប់ផ្តើមសន្តតិកម្ម បើទារកនោះមានកំណើតនៅពេលក្រោយ អាចទទួលមត៌ក ដោយសន្តតិកម្មនោះបាន។" ហើយនៅក្នុង កថាខណ្ឌទី២ មាត្រា ១១៤៩ នៃក្រមរដ្ឋប្បវេណីដដែលក៏បានទទួលស្គាល់នូវអានុភាពអនុវត្តនៃ កថាខណ្ឌទី២ មាត្រា៩ ចំពោះទារកដែលនៅក្នុងគភ៌ផងដែរ។

សូមបញ្ជាក់ថា ករណីដែលចែងកំណត់បែបនេះមិនមានភាពផ្ទុយគ្នាស្រឡះពីបទប្បញ្ញត្តិទាក់ទងនឹងការចាប់ផ្តើមសមត្ថភាពទទួលសិទ្ធិពេកនោះទេ ព្រោះថាគោលការណ៍អញ្ញត្រកម្មនេះនៅតែមានកំណត់នូវលក្ខខណ្ឌថា "បើទារកនោះមានកំណើតនៅពេលក្រោយ" ដែលគោរពតាមការចាប់ផ្តើមនូវសមត្ថភាពទទួលសិទ្ធិ នៃមាត្រា ៨ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ គ្រាន់តែអានុភាពនៃសមត្ថភាពទទួលសិទ្ធិមានអានុភាពប្រតិសកម្មហូតដល់ពេលចាប់ផ្តើមសន្តតិកម្មតែប៉ុណ្ណោះ ហើយសម្រាប់តែករណីទារកនៅក្នុងគភ៌តែមួយគត់។

**១.១.៣.២. លំដាប់នៃសន្តតិជន**

ទោះបីជាបុគ្គលណាម្នាក់មានសមត្ថភាពទទួលសិទ្ធិ នាពេលដែលចាប់ផ្តើមសន្តតិកម្មក៏ដោយ ប៉ុន្តែដោយហេតុថាសន្តតិកម្មជាការផ្ទេរនូវសិទ្ធិ និងករណីយកិច្ចទាំងអស់ ដែលស្ថិតនៅក្រោមទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិឯកជនរបស់មតកជន ដូច្នេះហើយទ្រព្យសម្បត្តិទាំងនោះគួរណាស់តែធ្វើការផ្ទេរទៅកាន់ជនដែលមានទំនាក់ទំនងញាតិជិតដិតជាមួយមតកជនតែប៉ុណ្ណោះ ដែលពុំអាចជាតតិយជននោះឡើយ លើកលែងតែមានឆន្ទៈផ្ទុយរបស់មតកជនដែលបានធ្វើមតកសាសន៍។ នៅក្នុងចំណុចនេះ យើងនឹងធ្វើការសិក្សាទៅលើលំដាប់នៃសន្តតិជនតាមច្បាប់ដែលបានកំណត់ក្នុងក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ ដែលរួមមានបីលំដាប់គឺ សន្តតិជនលំដាប់ទី១ និងសន្តតិជនជំនួស សន្តតិជនលំដាប់ទី២ សន្តតិជនលំដាប់ទី៣ និងសន្តតិជនជំនួស ព្រមទាំងសន្តតិជនជានិច្ចដែលគ្មានលំដាប់។

[31] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ៨។

### ក. សន្តតិជនលំដាប់ទី១ និងសន្តតិជនជំនួស

កូនរបស់មតកជន គឺជាសន្តតិជនដែលលំដាប់ទី១[32]។ កូនរបស់មតកជនអាចជាកូនបង្កើត ឬកូនសុំ។ ក្នុងករណីកូនសុំ មតកជនត្រូវតែសុំកូននោះតាមរយៈរបបសុំកូនធម្មតា ឬសុំកូនពេញលេញ ទើបអាចក្លាយជាកូនរបស់មតកជនក្នុងន័យសន្តតិកម្មបាន។

ក្នុងករណីកូនបង្កើត ត្រូវបានបែងចែកជាស្ថានភាពពីរផ្សេងពីគ្នា គឺស្ថានភាពទីមួយ កូនបង្កើតក្នុងចំណងអាពាហ៍ពិពាហ៍ និងស្ថានភាពទីពីរ កូនបង្កើតក្រៅចំណងអាពាហ៍ពិពាហ៍។

➢ ស្ថានភាពទីមួយ ៖ កូនបង្កើតក្នុងចំណងអាពាហ៍ពិពាហ៍ ដែលហៅតាមទំនៀមទម្លាប់ថា "កូនមានខាន់ស្លា" គឺជាកូនដែលត្រូវបានបង្កើតដោយប្តី និងប្រពន្ធដែលបានរៀបអាពាហ៍ពិពាហ៍ស្របច្បាប់ និងនៅក្នុងចំណងអាពាហ៍ពិពាហ៍។

➢ ស្ថានភាពទីពីរ ៖ កូនបង្កើតក្រៅចំណងអាពាហ៍ពិពាហ៍ ដែលហៅតាមទំនៀមទម្លាប់ថា "កូនឥតខាន់ស្លា" គឺជាកូនដែលត្រូវបានបង្កើតដោយប្តី ឬប្រពន្ធ ជាមួយជនដទៃដែលមិនមែនជាសហព័ទ្ធរបស់ខ្លួន។ ប្រសិនបើមតកជន គឺជាស្ត្រីភេទ ការកំណត់ថាជនណាម្នាក់ជាកូនបង្កើតក្រៅចំណងអាពាហ៍ពិពេហ៍ គឺមិនមានបញ្ហាស្មុគស្មាញនោះទេ ព្រោះថាច្បាប់កំណត់ថា "ស្ត្រីដែលបានសម្រាលកូន គឺជាម្តាយរបស់កូន"[33]។ ប៉ុន្តែប្រសិនបើមតកជន គឺជាបុរសភេទ ការកំណត់ថាជនណាម្នាក់ជាកូនបង្កើតក្រៅចំណងអាពាហ៍ពិពាហ៍ គឺអាចមានបញ្ហាស្មុគស្មាញ គេអាចកំណត់ដោយផ្អែកទៅលើ ការទទួលស្គាល់ដោយស្ម័គ្រចិត្ត[34] ដែលអាចជាការទទួលស្គាល់កូនជាអនីតិជន[35] ការទទួលស្គាល់កូនជាទារកនៅក្នុងគភ៌[36] ការទទួលស្គាល់កូនជានីតិជន និងកូនដែលបានទទួលមរណភាព[37] ដោយអាចធ្វើក្រោមទម្រង់ជាការជូនដំណឹងទៅមន្ត្រីអត្រានុកូលដ្ឋា[38]។ ចំពោះកូនវិញ កូនអាចដាក់ពាក្យបណ្ដឹងទាមទារឱ្យទទួលស្គាល់បានតាមមាត្រា ១០០១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

ចំពោះសន្តតិកម្មរវាងសហសន្តតិជនដែលមានលំដាប់ទី១ កូនរបស់មតកជន ទោះបីជាកូនបង្កើតក្តី ឬកូនសុំក្តី ត្រូវមានចំណែកមត៌កស្មើៗគ្នា[39]។

---

[32] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១១៥៦ កថាខណ្ឌទី១។
[33] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ៩៨៧។
[34] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ៩៩៣។
[35] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ៩៩៥ កថាខណ្ឌទី១។
[36] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ៩៥៥ កថាខណ្ឌទី២។
[37] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ៩៩៦។
[38] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ៩៩៧។
[39] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១១៥៦ កថាខណ្ឌទី១។

ផ្ទុយទៅវិញ ស្ថានភាពមួយចំនួនអាចកើតឡើងដែលធ្វើឱ្យប៉ះពាល់ឋានៈជាសន្តតិជនលំដាប់ទី១របស់កូន ដូចជាករណីដែលកូនទទួលមរណភាពមុន ឬព្រមគ្នានឹងមតកជន ឬបានបាត់បង់សិទ្ធិសន្តតិកម្មដោយសារជនបានក្លាយជាអភ័ព្វបុគ្គលនៃសន្តតិកម្ម[40] ឬដោយការផ្ដាច់មត៌ក[41]នោះកូនរបស់បុគ្គលនោះត្រូវក្លាយទៅជាសន្តតិជនជំនួស[42] ហើយការទទួលសន្តតិកម្មជំនួសត្រូវអនុវត្តជាបន្តបន្ទាប់ចំពោះបច្ឆាញាតិផ្ទាល់របស់មតកជន[43]។

ដោយហេតុថា សន្តតិជនជំនួសធ្វើការទទួលបន្តនូវសិទ្ធិសន្តតិកម្មរបស់បុព្វញាតិផ្ទាល់ ដូច្នេះហើយចំណែកមត៌ករបស់សន្តតិជនជំនួសត្រូវដូចគ្នានឹងចំណែកមត៌កដែលបុព្វញាតិផ្ទាល់របស់បច្ឆាញាតិផ្ទាល់នោះត្រូវទទួលបាន។ ប្រសិនបើបច្ឆាញាតិផ្ទាល់មានចំនួនច្រើននាក់ នោះអ្នកទាំងនោះមានសិទ្ធិទទួលបានចំណែកស្មើៗគ្នាពីក្នុងចំណែកមត៌កដែលបុព្វញាតិផ្ទាល់របស់បច្ឆាញាតិផ្ទាល់នោះត្រូវទទួល[44]។

### ខ. សន្តតិជនលំដាប់ទី២

ប្រសិនបើមតកជនមិនមានបច្ឆាញាតិផ្ទាល់ដូចជាកូន ឬសន្តតិជនជំនួសរបស់កូនដែលត្រូវក្លាយជាសន្តតិជនទេ បុព្វញាតិផ្ទាល់របស់មតកជននោះត្រូវក្លាយជាសន្តតិជន។ ក្នុងករណីនេះ រវាងបុគ្គលដែលមានថ្នាក់ញាតិខុសគ្នាត្រូវយកបុព្វញាតិដែលនៅជិតជាងជាមុន មានន័យថាប្រសិនបើមតកជនមាន ឪពុកម្ដាយដែលជាបុព្វញាតិថ្នាក់ទីមួយនៃញាតិលោហិតខ្សែផ្ទាល់ និងជីដូនជីតាដែលជាបុព្វញាតិថ្នាក់ទីពីរនៃញាតិលោហិតខ្សែផ្ទាល់ នោះឪពុកម្ដាយត្រូវក្លាយជាសន្តតិជនដែលមានលំដាប់ទី២ មិនមែនជីដូនជីតានោះទេ[45]។

ចំណែកមត៌ករវាងសន្តតិជនលំដាប់ទី២ ក្នុងករណីបុព្វញាតិផ្ទាល់មានចំនួនច្រើននាក់ បុព្វញាតិផ្ទាល់នីមួយៗត្រូវទទួលចំណែកមត៌កស្មើៗគ្នា[46]។ ប៉ុន្តែ បើក្នុងករណីមានបុព្វញាតិផ្ទាល់តែម្នាក់ បុព្វញាតិផ្ទាល់នោះត្រូវទទួលចំណែកមត៌កតែម្នាក់ឯង។

### គ. សន្តតិជនលំដាប់ទី៣ និងសន្តតិជនជំនួស

ប្រសិនបើក្នុងករណីដែលមតកជនពុំមានទាំងបច្ឆាញាតិផ្ទាល់ ព្រមទាំងបុព្វញាតិផ្ទាល់ ដែលត្រូវក្លាយជាសន្តតិជនទេ បងប្អូនបង្កើតរបស់មតកជននោះ ត្រូវក្លាយជាសន្តតិជន[47]។ ជាគោលការណ៍ "បើបងប្អូនបង្កើត

[40] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១១៥០។
[41] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១១៥១។
[42] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១១៥៧ កថាខណ្ឌទី១។
[43] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១១៥៧ កថាខណ្ឌទី២។
[44] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១១៥៨។
[45] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១១៥៩ កថាខណ្ឌទី១។
[46] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១១៥៩ កថាខណ្ឌទី២។
[47] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១១៦០ កថាខណ្ឌទី១។

មានចំនួនច្រើននាក់ បងប្អូនបង្កើតម្នាក់ត្រូវបានចំណែកមត៌កភាគស្មើៗគ្នា"។[48] ដោយហេតុ បងប្អូនបង្កើតដែលមានតែឪពុក ឬម្ដាយតែម្ខាងដូចគ្នា ក៏ត្រូវចាត់ទុកជាបងប្អូនបង្កើត និងអាចក្លាយជាសន្តតិជនលំដាប់ទី៣ផងដែរ។ ប៉ុន្តែដោយសារតែ បងប្អូនបង្កើតដែលមានតែឪពុក ឬម្ដាយតែម្ខាងដូចគ្នាមិនមានភាពជិតស្និទ្ធដូចបងប្អូនបង្កើតដែលមានឪពុក និងម្ដាយទាំងសងខាងដូចគ្នា ដូច្នេះហើយ ទើបក្រមរដ្ឋប្បវេណីចែងថា "ចំណែកមត៌ករបស់បងប្អូនបង្កើតដែលមានឪពុក ឬម្ដាយតែម្ខាងដូចគ្នា ត្រូវមាន ១ ភាគ ២ (មួយភាគពីរ) នៃចំណែកមត៌ករបស់បងប្អូនដែលមានឪពុក និងម្ដាយទាំងសងខាងដូចគ្នា"។[49]

ដោយឡែក ក្នុងករណីដែលបងប្អូនបង្កើតរបស់មតកជនដែលត្រូវក្លាយជាសន្តតិជនលំដាប់ទី៣ បានទទួលមរណភាពនៅមុនពេលចាប់ផ្ដើមសន្តតិកម្ម កូនរបស់បុគ្គលនោះត្រូវក្លាយទៅជាសន្តតិជនជំនួស។ សូមបញ្ជាក់ថា ការអនុវត្តសន្តតិកម្មជំនួសនេះមិនមានលក្ខណៈបន្តបន្ទាប់ចំពោះបច្ឆាញាតិផ្ទាល់ដូចទៅនឹងសន្តតិកម្មជំនួសចំពោះសន្តតិជនលំដាប់ទី១ នោះទេ ពោលគឺអនុវត្តតែចំពោះកូនរបស់សន្តតិជនលំដាប់ទី៣ តែប៉ុណ្ណោះ។ ចំណែកឯ ចំណែកមត៌កសម្រាប់សន្តតិជនជំនួសក្នុងករណីនេះវិញ គឺដូចគ្នានឹងករណីសន្តតិកម្មជំនួសចំពោះសន្តតិជនលំដាប់ទី១ដែរ ដែលមានត្រឹមកម្រិតដូចគ្នានឹងចំណែកមត៌កដែលបុព្វញាតិផ្ទាល់របស់បច្ឆាញាតិផ្ទាល់នោះត្រូវទទួលបាន។[50]

### ឃ. សន្តតិជនជានិច្ច

ក្រៅពីសន្តតិជនលំដាប់ទី១ សន្តតិជនលំដាប់ទី២ និងសន្តតិជនលំដាប់ទី៣ មានសន្តតិជនមួយប្រភេទទៀតដែលគេឱ្យឈ្មោះថាសន្តតិជនជានិច្ច។ "សន្តតិជនជានិច្ច គឺជាសហព័ទ្ធរបស់មតកជន"។[51]

សន្តតិជនជានិច្ច គឺជាសន្តតិជនដែលគ្មានលំដាប់ ជាគោលការណ៍សន្តតិជនជានិច្ចត្រូវមានលំដាប់ស្មើគ្នានឹងសន្តតិជនលំដាប់ទី១ ឬសន្តតិជនលំដាប់ទី២ ឬសន្តតិជនលំដាប់ទី៣ ក្នុងករណីមតកជនមានសន្តតិជន។ ហើយទោះបីជាមតកជនគ្មានសន្តតិជនក៏សន្តតិជនជានិច្ចនៅតែមានសិទ្ធិទទួលមត៌ករបស់មតកជនដដែល។[52]

ប្រសិនបើមតកជនគ្មានសន្តតិជននោះទេ សន្តតិជនជានិច្ចត្រូវទទួលនូវមត៌កទាំងអស់របស់មតកជន។ ប៉ុន្តែនៅក្នុងករណីដែលសហព័ទ្ធរបស់មតកជន និងបុគ្គលផ្សេងទៀតក្រៅពីសហព័ទ្ធត្រូវក្លាយជាសន្តតិជន ចំណែកមត៌ករបស់សន្តតិជននឹងត្រូវបែងចែកខុសៗគ្នាទៅតាមករណីនីមួយៗ។

---

[48] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១១៦០ កថាខណ្ឌទី២ វាក្យខណ្ឌទី១។

[49] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១១៦០ កថាខណ្ឌទី២ វាក្យខណ្ឌទី២។

[50] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១១៦០ កថាខណ្ឌទី៣។

[51] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១១៦១ កថាខណ្ឌទី១។

[52] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១១៦១ កថាខណ្ឌទី២។

➢ ករណីទីមួយ ៖ "បើសហព័ទ្ធ និងបច្ឆាញាតិផ្ទាល់របស់មតកជននោះជាសន្តតិជន សហព័ទ្ធ និងកូននីមួយៗ របស់មតកជននោះនឹងត្រូវទទួលចំណែកមត៌កស្មើគ្នា"។ [53] ករណីទីមួយនេះប្រើចំពោះករណីដែលសន្តតិជនដែលមានអត្ថិភាពនោះគឺជាសន្តតិជនលំដាប់ទី១ និងសន្តតិជំនួស។

➢ ករណីទីពីរ ៖ "បើសហព័ទ្ធ និង ឪពុក ម្ដាយរបស់មតកជនជាសន្តតិជន ចំណែកមត៌ករបស់សហព័ទ្ធ ត្រូវជា ១ ភាគ ៣ (មួយភាគបី) ឯចំណែកមត៌ករបស់ឪពុក ម្ដាយ ត្រូវជា ២ ភាគ ៣ (ពីរភាគបី)។ ប៉ុន្តែបើឪពុក ឬម្ដាយ របស់មតកជនតែម្នាក់នៅរស់ ឪពុក ម្ដាយនោះ និងសហព័ទ្ធ ត្រូវបានចំណែកមត៌កស្មើគ្នា"។[54] ករណីទីពីរនេះប្រើចំពោះករណីដែលសន្តតិជនដែលមានអត្ថិភាពនោះគឺជាសន្តតិជនលំដាប់ទី២ ដែលជាឪពុក និងម្ដាយរបស់មតកជនតែប៉ុណ្ណោះដោយមិនរួមបញ្ចូលបុព្វញាតិផ្ទាល់របស់មតកជនក្រៅពីឪពុក និងម្ដាយរបស់មតកជនឡើយ។

➢ ករណីទីបី ៖ "បើសហព័ទ្ធ និងបុព្វញាតិផ្ទាល់ក្រៅឪពុក ម្ដាយរបស់មតកជន ឬបងប្អូនបង្កើតរបស់មតកជន ឬអ្នកទទួលសន្តតិកម្មជំនួសបុគ្គលទាំងនោះជាសន្តតិជន ចំណែកមត៌ករបស់សហព័ទ្ធ ត្រូវជា ១ ភាគ ២ (មួយភាគពីរ) ឯចំណែកមត៌ករបស់បុព្វញាតិផ្ទាល់ក្រៅពីឪពុក ម្ដាយ របស់មតកជន ឬបងប្អូនបង្កើតរបស់មតកជន ឬអ្នកទទួលសន្តតិកម្មជំនួសនោះ ត្រូវជា ១ ភាគ ២ (មួយភាគពីរ)"។[55] ករណីទីបីនេះប្រើចំពោះករណីដែលសន្តតិជនដែលមានអត្ថិភាពនោះគឺជាសន្តតិជនលំដាប់ទី៣ និងសន្តតិជនលំដាប់ទី២ ក្រៅពីឪពុក ម្ដាយរបស់មតកជនដែលអាចជាជីដូន ឬជីតា ឬបុព្វញាតិរបស់ជីដូន ជីតាបន្តបន្ទាប់គ្នា។

#### ១.១.៣.៣. អភ័ព្វបុគ្គល

អភ័ព្វបុគ្គល គឺជាការកំណត់ដោយច្បាប់នូវជនដែលពុំមានលក្ខណៈសម្បត្តិជាសន្តតិជន។ [56] ក្នុងចំណុចនេះយើងនឹងសិក្សាទៅលើមូលហេតុដែលនាំឱ្យបុគ្គលណាម្នាក់ក្លាយជាអភ័ព្វបុគ្គល និងការកាន់កាប់មត៌កដោយអភ័ព្វបុគ្គលនោះផងដែរ។

#### ក. មូលហេតុនាំឱ្យក្លាយជាអភ័ព្វបុគ្គល

នៅក្នុងក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ បានកំណត់ពីមូលហេតុមួយចំនួនដែលនាំឱ្យបុគ្គលដែលបានកំណត់ដូចខាងក្រោមនេះ ពុំអាចក្លាយជាសន្តតិជនបាននោះទេ៖

"ក - បុគ្គលដែលបានទទួលទោស ដោយមានចេតនាធ្វើឃាត ឬប៉ុនប៉ងធ្វើឃាតលើមតកជន ឬលើជនដែលមានលំដាប់សន្តតិកម្មមុន ឬលំដាប់ស្មើគ្នា ទោះដោយផ្ទាល់ក្ដី ឬដោយប្រយោលក្ដី។

[53] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១១៦២ ចំណុច ក។
[54] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១១៦២ ចំណុច ខ។
[55] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១១៦២ ចំណុច គ។
[56] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១១៥០។

ខ - បុគ្គលដែលដឹងអំពីការសម្លាប់មតកជន តែមិនបានរាយការណ៍ ឬមិនបានប្ដឹង។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលបុគ្គលនោះ មិនអាចវិនិច្ឆ័យអំពើល្អ ឬអាក្រក់បាន ឬករណីដែលអ្នកសម្លាប់ជាសហព័ទ្ធ ឬញាតិលោហិតខ្សែផ្ទាល់របស់បុគ្គលនោះ។"[57]

ក្រៅពីការរៀបរាប់ខាងលើ បុគ្គលដែលបានរារាំងមតកជនក្នុងការធ្វើ ឬដែលបានឱ្យមតកជនធ្វើមតកសាសន៍ស្ដីពីសន្តតិកម្ម ដោយការឆបោក ឬ គម្រាមកំហែង។ ព្រមទាំងបុគ្គលដែលបានក្លែង បំផ្លាញចោលនូវលិខិតមតកសាសន៍ស្ដីពីសន្តតិកម្មរបស់មតកជន ក៏ត្រូវចាត់ទុកថាជាអភ័ព្វបុគ្គលដែរ។[58]

### ខ. ការកាន់កាប់មត៌កដោយអភ័ព្វបុគ្គល

នៅពេលដែលបុគ្គលណាម្នាក់ត្រូវបានក្លាយជាអភ័ព្វបុគ្គលកំពុងកាន់កាប់មត៌ក បុគ្គលនោះត្រូវបានចាត់ទុកថាជាអ្នកកាន់កាប់ដោយទុច្ចរិត គិតចាប់ពីពេលចាប់ផ្ដើមសន្តតិកម្ម[59]។ ការចាត់ទុកអភ័ព្វបុគ្គលថាជាអ្នកកាន់កាប់ដោយទុច្ចរិតនេះ នាំឱ្យអភ័ព្វបុគ្គលមានករណីយកិច្ចសងនូវសំណងនៃការខូចខាតទាំងស្រុង ចំពោះការបាត់បង់ ឬខូចខាតណាមួយទៅលើវត្ថុដែលត្រូវបានកាន់កាប់នោះគិតចាប់ពីពេលចាប់ផ្ដើមសន្តតិកម្ម។

### ១.១.៣.៤. បុគ្គលដែលត្រូវបានផ្ដាច់ពីសន្តតិកម្ម

ក្រៅពីអភ័ព្វបុគ្គល បុគ្គលដែលត្រូវបានកាត់ផ្ដាច់ពីសន្តតិកម្មក៏គ្មានលក្ខណៈសម្បត្តិក្លាយជាសន្តតិជនផងដែរ។ ការផ្ដាច់មត៌កពីសន្តតិជនទាមទារឱ្យមតកជនដាក់ពាក្យសុំទៅតុលាការ ដោយផ្អែកតាមនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង វាផ្ទុយពីអភ័ព្វបុគ្គលដែលកើតឡើងដោយស្វ័យប្រវត្តិជាមួយនឹងសំអាងហេតុ ឬភស្តុតាងផ្សេងៗ។

នៅក្នុងចំណុចនេះយើងនឹងធ្វើការសិក្សាទៅលើមូលហេតុនៃការផ្ដាច់មត៌ក និងការតវ៉ា ការកាន់កាប់មត៌កដោយបុគ្គលដែលត្រូវបានផ្ដាច់ពីសន្តតិកម្ម និងការលុបចោលការផ្ដាច់មត៌កពីសន្តតិជន។

### ក. មូលហេតុនៃការផ្ដាច់មត៌ក និងការតវ៉ា

នៅក្នុងក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ បានកំណត់ពីមូលហេតុដែលនាំឱ្យ មតកជនកាលនៅរស់អាចដាក់ពាក្យសុំទៅតុលាការឱ្យផ្ដាច់មត៌កពីជនដែលត្រូវសន្មតថាជាសន្តតិជននោះ ដើម្បីពុំអាចឱ្យទទួលសន្តតិកម្មបាន បើជនដែលត្រូវបានសន្មតថាជាសន្តតិជនដែលមានភាគបម្រុង បានប្រព្រឹត្តនូវសកម្មភាពដែលបានកំណត់ដូចខាងក្រោមនេះ៖

"ក - បើបានធ្វើបាបចំពោះមតកជន។

ខ - បើបានប្រមាថមតកជនយ៉ាងធ្ងន់ធ្ងរ។

---

[57] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១១៥០។

[58] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១១៥០។

[59] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១១៥៣។

គ - បើអាចមកមើលថែទាំមតកជននៅពេលដែលមានជម្ងឺ ប៉ុន្តែមិនមកថែទាំ។

ឃ- បើត្រូវបានទទួលសាលក្រម ឬសាលដីកាផ្តន្ទាទោសឱ្យជាប់ពន្ធនាគារមួយជីវិត។

ង - បើបានប្រព្រឹត្តអំពើល្មើសធ្ងន់ធ្ងរគួរឱ្យកត់សម្គាល់ជាអាទិ៍។"[60]

ក៏ប៉ុន្តែក្រោយពេលដាក់ពាក្យសុំ នៅក្នុងនីតិវិធីនៃការធ្វើសេចក្តីសម្រេចផ្តាច់មត៌កពីសន្តតិជន អនុញ្ញាតឱ្យជនដែលត្រូវសន្មតថាជាសន្តតិជនដែលបានទទួលការទាមទារផ្តាច់មត៌កធ្វើវិវាទអំពីអត្ថិភាព ឬនត្ថិភាពនៃមូលហេតុនៃការផ្តាច់មត៌កនោះបាន។[61]

### ខ. ការកាន់កាប់មត៌កដោយបុគ្គលដែលត្រូវបានផ្តាច់ពីសន្តតិកម្ម

នៅពេលបុគ្គលណាម្នាក់ដែលត្រូវបានកាត់ផ្តាច់ពីសន្តតិកម្មកំពុងកាន់កាប់មត៌ក បុគ្គលនោះត្រូវបានចាត់ទុកថាជាអ្នកកាន់កាប់ដោយទុច្ចរិត គិតចាប់ពីពេលចាប់ផ្តើមសន្តតិកម្ម[62]។ ការចាត់ទុកបុគ្គលដែលត្រូវបានកាត់ផ្តាច់ពីសន្តតិកម្មថាជាអ្នកកាន់កាប់ដោយទុច្ចរិតនេះ នាំឱ្យបុគ្គលដែលត្រូវបានកាត់ផ្តាច់ពីសន្តតិកម្មមានករណីយកិច្ចសងនូវសំណងនៃការខូចខាតទាំងស្រុង ចំពោះការបាត់បង់ ឬខូចខាតណាមួយទៅលើវត្ថុដែលត្រូវបានកាន់កាប់នោះគិតចាប់ពីពេលចាប់ផ្តើមសន្តតិកម្ម។

### គ. ការលុបចោលការផ្តាច់មត៌កពីសន្តតិជន

"មតកជន កាលនៅរស់អាចដាក់ពាក្យសុំទៅតុលាការឱ្យលុបចោលការផ្តាច់មត៌កពីជនដែលត្រូវបានសន្មតថាជាសន្តតិជន នៅពេលណាក៏បាន"។[63]

## ១.២. ការយល់ព្រម និងការបោះបង់សន្តតិកម្មតាមច្បាប់

"សន្តតិជនត្រូវទទួលបន្តនូវសិទ្ធិ និងករណីយកិច្ចទាំងអស់ដែលស្ថិតនៅក្រោមទ្រព្យសម្បត្តិរបស់មតកជនចាប់ពីពេលចាប់ផ្តើមសន្តតិកម្ម"។[64] ប៉ុន្តែ ប្រសិនបើក្នុងករណីដែលសន្តតិជនមិនមានបំណងទទួលយកមត៌ករបស់មតកជននោះទេ ឬប្រសិនបើករណីដែលទំហំនៃកាតព្វកិច្ចនៅក្នុងមត៌កមានច្រើនជាងទំហំនៃសិទ្ធិដែលអាចនាំឱ្យសន្តតិជនក្ស័យធនបានក្រោយពេលដែលទទួលយកមត៌ករបស់មតកជន នោះការកំណត់ឱ្យសន្តតិជនត្រូវតែទទួលមត៌ករបស់មតកជនហាក់ដូចជាការបង្ខិតបង្ខំដែលផ្ទុយពីគោលការណ៍ស្វ័យភាពនៃបុគ្គលឯកជន[65] ដែលជាគោលការណ៍មូលដ្ឋាននៅក្នុងទំនាក់ទំនងឯកជន។

[60] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១១៥១ កថាខណ្ឌទី១។

[61] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១១៥១ កថាខណ្ឌទី២។

[62] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១១៥៣។

[63] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១១៥៤ កថាខណ្ឌទី១។

[64] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១១៤៧ កថាខណ្ឌទី១ វាក្យខណ្ឌទី១។

[65] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ៣។

ហេតុដូច្នេះហើយ ក្រមរដ្ឋប្បវេណីក៏បានបើកសិទ្ធិអនុញ្ញាតឱ្យសន្តតិជន នៅក្នុងអំឡុងពេលកំណត់ដោយច្បាប់មួយ(**១.២.១**) អាចធ្វើការយល់ព្រមទទួលសន្តតិកម្មតាមច្បាប់(**១.២.២**) ឬធ្វើការបោះបង់សន្តតិកម្មតាមច្បាប់(**១.២.៣**) ចំពោះសន្តតិកម្មទាំងមូលបាន ផ្អែកតាមឆន្ទៈផ្ទាល់របស់សន្តតិជន ព្រមទាំងកំណត់ពីវិធាននៃការលុបចោលការបោះបង់សន្តតិកម្មតាមច្បាប់(**១.២.៤**)ផងដែរ។

### ១.២.១. អំឡុងពេលនៃការយល់ព្រម និងបោះបង់សន្តតិកម្មតាមច្បាប់

"សន្តតិជន ត្រូវធ្វើការយល់ព្រម ឬបោះបង់សន្តតិកម្មទាំងស្រុង ឬដោយកម្រិត នៅក្នុងអំឡុងពេល ៣ (បី) ខែ គិតចាប់ពីពេលដែលបានដឹងថា សន្តតិកម្មចំពោះខ្លួនបានចាប់ផ្តើម"។[66]

អំឡុងពេលខាងលើ បង្កើតឡើងក្នុងគោលបំណងឱ្យសន្តតិជនវិនិច្ឆ័យថាតើគួរយល់ព្រមទាំងស្រុង ឬដោយកម្រិត ឬបោះបង់មត៌ករបស់មតកជនដោយពិចារណាលើទំហំនៃកាតព្វកិច្ច ទំហំនៃសិទ្ធិ និងស្ថានភាពពាក់ព័ន្ធផ្សេងទៀត ឬក៏ធ្វើការស្រាវជ្រាវមត៌កជាមុនសិន។ [67] ហើយប្រសិនបើការសម្រេចចិត្តមិនអាចធ្វើឡើងបានក្នុងអំឡុងពេល ៣ (បី) ខែ ដោយសារមូលហេតុជាច្រើនដូចជា មត៌កមានច្រើន ឬមត៌កស្ថិតនៅទីតាំងផ្សេងគ្នា ឬមិនច្បាស់ថាមានមតកជនមត៌កណាខ្លះ ឬមូលហេតុផ្សេងៗទៀត សន្តតិជនអាចដាក់ពាក្យសុំពន្យារអំឡុងពេលនេះទៅតុលាការបាន។[68] ថ្វីត្បិតតែ អំឡុងពេលនៃការយល់ព្រម ឬបោះបង់សន្តតិកម្មទាំងស្រុង ឬដោយកម្រិត មានរយៈពេល ៣ (បី) ខែ ដោយគិតចាប់ពីពេលបានដឹងថា សន្តតិកម្មចំពោះខ្លួនបានចាប់ផ្តើមក៏ដោយ។ ក៏ប៉ុន្តែ ចំណុចដែលត្រូវចាប់ផ្តើមគិតអំឡុងពេលខាងលើមិនដូចគ្នានោះទេ ដូចជាករណីសន្តតិជនទទួលមរណភាព (**១.២.១.១**) ករណីសន្តតិជនជាអនីតិជនជាអាទិ៍(**១.២.១.២**) និងករណីសន្តតិជនមិនដឹងពីអត្ថិភាពនៃកាតព្វកិច្ច (**១.២.១.៣**)។

#### ១.២.១.១. ករណីសន្តតិជនទទួលមរណភាព

ក្នុងករណីដែលសន្តតិជនបានទទួលមរណភាព នៅមុនពេលធ្វើការយល់ព្រម ឬការបោះបង់ នោះ អំឡុងពេល ៣ (បី) ខែ សម្រាប់ការយល់ព្រម ឬការបោះបង់សន្តតិកម្ម ដែលកំណត់ក្នុងមាត្រា ១២៤៨ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ ត្រូវគណនាដោយគិតចាប់ពីពេលដែលសន្តតិជនរបស់ជននោះ បានដឹងថាសន្តតិកម្មចំពោះខ្លួនបានចាប់ផ្តើម។[69]

---

[66] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា កថាខណ្ឌទី១ វាក្យខណ្ឌទី១។

[67] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១២៤៨ កថាខណ្ឌទី២។

[68] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១២៤៨ កថាខណ្ឌទី១ វាក្យខណ្ឌទី២។

[69] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១២៤៩។

#### ១.២.១.២. ករណីសន្តតិជនជាអនីតិជន ជាអាទិ៍

ក្នុងករណីដែលសន្តតិជនជាអនីតិជន ឬជននៅក្រោមអាណាព្យាបាលទូទៅ នោះអំឡុងពេល ៣ (បី) ខែ សម្រាប់ការយល់ព្រម ឬការបោះបង់សន្តតិកម្ម ដែលកំណត់ក្នុងមាត្រា ១២៤៨ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ ត្រូវគណនាដោយគិតចាប់ពីពេលដែលអ្នកតំណាងដែលច្បាប់បានកំណត់នោះ បានដឹងថាសន្តតិកម្មចំពោះជនដែលជាអនីតិជន ឬជននៅក្រោមអាណាព្យាបាលទូទៅនោះបានចាប់ផ្តើម។[70]

#### ១.២.១.៣. ករណីសន្តតិជនមិនដឹងអំពីអត្ថិភាពនៃកាតព្វកិច្ច

ក្នុងករណីដែលមតកជនមានកាតព្វកិច្ចដែលមានចំនួនទឹកប្រាក់ច្រើន ហើយមិនអាចយកមត៌កទៅសងឱ្យគ្រប់ចំនួនបានទេ បើសន្តតិជនមិនអាចដឹងអំពីអត្ថិភាពនៃកាតព្វកិច្ចនោះ តាមស្ថានភាពនៃជីវភាពរបស់មតកជន ស្ថានភាពនៃទ្រព្យសម្បត្តិរបស់មតកជន ឬស្ថានភាពផ្សេងៗទៀត នោះអំឡុងពេល ៣ (បី) ខែ សម្រាប់ការយល់ព្រម ឬការបោះបង់សន្តតិកម្ម ដែលកំណត់ក្នុងមាត្រា ១២៤៨ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ ត្រូវគណនាដោយគិតចាប់ពីពេលដែលសន្តតិជនបានដឹងអំពីអត្ថិភាពនៃកាតព្វកិច្ចនោះ។[71]

### ១.២.២. ការយល់ព្រមចំពោះសន្តតិកម្មតាមច្បាប់

ជម្រើសនៃការយល់ព្រមចំពោះសន្តតិកម្មតាមច្បាប់បែងចែកជាពីរប្រភេទគឺ ការយល់ព្រមទាំងស្រុង (**១.២.២.១**) និងការយល់ព្រមដោយមានកម្រិត(**១.២.២.២**)។

#### ១.២.២.១. ការយល់ព្រមទាំងស្រុង និងអានុភាព

ការយល់ព្រមទាំងស្រុងមិនមាននីតិវិធីដូចនឹងការយល់ព្រមដោយកម្រិតនោះទេ សន្តតិជនគ្រាន់តែបំពេញនូវលក្ខខណ្ឌមួយចំនួននោះនឹងត្រូវបានចាត់ទុកថាយល់ព្រមទាំងស្រុង ហើយក្រោយការយល់ព្រមទាំងស្រុងនឹងកើតមានឡើងនូវស្ថានភាពមួយចំនួនផងដែរ។

##### ក. លក្ខខណ្ឌនៃការយល់ព្រមទាំងស្រុង

ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ បានកំណត់ពីលក្ខខណ្ឌមួយចំនួនប្រសិនបើសន្តតិជនបានធ្វើ ឬមិនបានធ្វើ នឹងនាំឱ្យមានការចាត់ទុកថាសន្តតិជនបានយល់ព្រមទាំងស្រុងតាមច្បាប់ ដូចក្នុងករណីដែលបានកំណត់ដូចខាងក្រោមនេះនឹងត្រូវចាត់ទុកថា សន្តតិជនបានយល់ព្រមទាំងស្រុងតាមច្បាប់៖

"ក - បើសន្តតិជនបានចាត់ចែងមត៌កនោះទាំងអស់ ឬមួយភាគ។ ប៉ុន្តែបញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយចំពោះសកម្មភាពរក្សា និងសកម្មភាពត្រឹមតែជាការគ្រប់គ្រង។

[70] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១២៥០។

[71] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១២៥១ កថាខណ្ឌទី១។

ខ - បើសន្តតិជនមិនបានយល់ព្រមដោយកម្រិត ឬបោះបង់ នៅក្នុងអំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ នៃមាត្រា ១២៤៨(អំឡុងពេលនៃការយល់ព្រម ឬការបោះបង់)នៃក្រមនេះ។

គ - ទោះបីជាសន្តតិជនបានយល់ព្រមដោយកម្រិត ឬបោះបង់ក៏ដោយ បើសន្តតិជនបានលាក់មត៌កទាំងអស់ ឬមួយភាគ ឬបានប្រើប្រាស់មត៌កនោះដើម្បីខ្លួន។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ នៅក្រោយពេលដែលជនដែលបានក្លាយជាសន្តតិជនដោយសារការបោះបង់របស់សន្តតិជនលំដាប់មុនបានយល់ព្រម។"[72]

មានករណីដោយឡែកមួយបើ "ក្នុងករណីដែលជនដែលបានធ្វើសន្តតិកម្មតែម្នាក់ឯង បានយល់ព្រមដោយកម្រិត បើសន្តតិជននោះមិនបានសរសេរទ្រព្យសម្បត្តិទាំងអស់ ឬមួយភាគ នៅក្នុងបញ្ជីសារពើភ័ណ្ឌ ដោយទុច្ចរិត ឬបើមានហេតុដែលបានកំណត់នៅក្នុងចំណុច ក ឬគ នៃមាត្រា ១២៥៥ ការយល់ព្រមទាំងស្រុងតាមច្បាប់) នៃក្រមនេះ កើតឡើងចំពោះសន្តតិជននោះត្រូវចាត់ទុកថា សន្តតិជននោះបានយល់ព្រមទាំងស្រុង ហើយសេចក្តីថ្លែងការណ៍នៃការយល់ព្រមដោយកម្រិត មិនបង្កើតអានុភាពតាំងពីដំបូងមក។"[73] ហើយចំពោះករណីសហសន្តតិកម្ម បើមានសន្តតិជនមានមូលហេតុខាងលើ នឹងត្រូវយកបញ្ញត្តិខាងលើមកអនុវត្តដូចគ្នា។ ហេតុដូច្នេះហើយ ម្ចាស់បំណុលអាចអនុវត្តសិទ្ធិរបស់ខ្លួនទៅលើសន្តតិជនម្នាក់ ឬច្រើននាក់ចំពោះចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលដែលពុំអាចទទួលការសងដោយមត៌កដោយបែងចែកតាមចំណែកមត៌កដែលកំណត់ដោយច្បាប់របស់សន្តតិជនម្នាក់ៗត្រូវទទួលបាន ប្រសិនបើមត៌ករបស់មតកជនមានតិចជាងកាតព្វកិច្ច នោះម្ចាស់បំណុលអាចយកទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់សន្តតិជនម្នាក់ ឬច្រើននាក់មកសងបន្ថែមបាន។[74]

## ខ. អានុភាពក្រោយការយល់ព្រមទាំងស្រុង

"បើសន្តតិជនបានយល់ព្រមទាំងស្រុង ត្រូវទទួលបន្តដោយគ្មានកម្រិតនូវសិទ្ធិ និងកាតព្វកិច្ចរបស់មតកជន។"[75]

មុនពេលពេលផុតអំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ នៃមាត្រា ១២៤៨ ស្តីពីអំឡុងពេលនៃការយល់ព្រម ឬការបោះបង់ ការផ្លាស់ប្តូរឈ្មោះម្ចាស់សិទ្ធិលើមត៌កអាចធ្វើបានតែក្នុងករណីចាំបាច់ដើម្បីសងកាតព្វកិច្ចរបស់មតកជន។[76] ក្រោយផុតអំឡុងពេលខាងលើ សន្តតិជន និងអ្នកគ្រប់គ្រងមត៌កអាចផ្លាស់ប្តូរឈ្មោះម្ចាស់សិទ្ធិលើមត៌កទៅឱ្យសន្តតិជនបាន។[77]

ជាមួយគ្នានេះដែរ ក្រោយការផុតអំឡុងពេលខាងលើនឹងបង្កើតបានជាសិទ្ធិសម្រាប់ម្ចាស់បំណុលរបស់មតកជន និងម្ចាស់បំណុលរបស់សន្តតិជន។

[72] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១២៥៥។

[73] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១២៥៩ កថាខណ្ឌទី២។

[74] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១២៥៩ កថាខណ្ឌទី២។

[75] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១២៥៤។

[76] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១២៧៧ វាក្យខណ្ឌទី២។

[77] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១២៧៧ វាក្យខណ្ឌទី១។

➢ សិទ្ធិសម្រាប់ម្ចាស់បំណុលរបស់មតកជន គឺក្រោយផុតអំឡុងពេលខាងលើ ម្ចាស់បំណុលរបស់មតកជនអាចអនុវត្តសិទ្ធិរបស់ខ្លួន ចំពោះទ្រព្យសម្បត្តិផ្ទាល់របស់សន្តតិជនបាន។[78]

➢ សិទ្ធិសម្រាប់ម្ចាស់បំណុងលរបស់សន្តតិជន គឺក្រោយផុតអំឡុងពេលខាងលើ ម្ចាស់បំណុលរបស់សន្តតិជនអាចអនុវត្តសិទ្ធិរបស់ខ្លួន ចំពោះមត៌ករបស់សន្តតិជនបាន។[79]

### ១.២.២.២. ការយល់ព្រមដោយមានកម្រិត និងអានុភាព

ក្រៅពីការយល់ព្រមទាំងស្រុង សន្តតិជនក៏អាចជ្រើសរើសការយល់ព្រមដោយកម្រិតបានដែរ។ ការយល់ព្រមដោយមានកម្រិត គឺជាការយល់ព្រមដោយបម្រុងទុកនូវសំណងកាតព្វកិច្ច និងអច្ច័យទានរបស់មតកជនត្រឹមកម្រិតនៃទ្រព្យសម្បត្តិដែលខ្លួនបានទទួលតាមរយៈសន្តតិកម្ម តែប៉ុណ្ណោះ។[80] នៅក្នុងចំណុចនេះយើងនឹងធ្វើការសិក្សាទៅលើរបៀបយល់ព្រមដោយមានកម្រិត និងអានុភាពក្រោយការយល់ព្រមដោយមានកម្រិត។

#### ក. របៀបយល់ព្រមដោយមានកម្រិត

ក្នុងករណីសន្តតិជនមានតែម្នាក់ សន្តតិជននោះត្រូវធ្វើការយល់ព្រមដោយមានកម្រិតម្នាក់ឯង តែប្រសិនបើក្នុងករណីសន្តតិជនមានច្រើននាក់ សហសន្តតិជនត្រូវតែធ្វើការយល់ព្រមដោយមានកម្រិតរួមគ្នាទាំងអស់។[81]

ការយល់ព្រមដោយមានកម្រិតត្រូវធ្វើឡើងតាមនីតិវិធីដែលជាដំបូងត្រូវធ្វើបញ្ជីសារពើភ័ណ្ឌដែលមានកំណត់ពីមត៌កសកម្ម មត៌កអកម្មទាំងអស់ដែលសន្តតិជនត្រូវទទួល និងមានលទ្ធភាពដឹង។ បន្ទាប់មក សន្តតិជនត្រូវដាក់ពាក្យសុំអំពីការយល់ព្រមដោយកម្រិតនោះ ទៅតុលាការដោយផ្អែកតាមនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង នៅក្នុងអំឡុងពេលនៃការយល់ព្រម។[82]

#### ខ. អានុភាពក្រោយការយល់ព្រមដោយមានកម្រិត

ផ្ទុយពីការយល់ព្រមទាំងស្រុង ឬការបោះបង់សន្តតិកម្ម។ ក្រោយការយល់ព្រមដោយមានកម្រិតនឹងកើតមានភាពស្មុគស្មាញទៅលើបញ្ហាជាច្រើនដូចជា ការគ្រប់គ្រងមត៌ក ជាពិសេសគឺការជម្រះបញ្ជីរវាងទ្រព្យអកម្ម និងទ្រព្យសកម្ម នៅក្នុងមត៌ករបស់មតកជន បើក្រឡេកមើលការយល់ព្រមទាំងស្រុង ឬការបោះបង់សន្តតិកម្មវិញ ការគ្រប់គ្រងមត៌កនៅតែអនុវត្តបន្តចាប់ពីពេលចាប់ផ្តើមសន្តតិកម្ម រីឯចំពោះការជម្រះបញ្ជីរវាងទ្រព្យអកម្ម និងទ្រព្យសកម្ម នៅក្នុងមត៌ករបស់មតកជនវិញ ប្រសិនសន្តតិជនធ្វើការយល់ព្រមទាំងស្រុង នោះសន្តតិជននឹងត្រូវទទួលបន្តនូវសិទ្ធិ និងកាតព្វកិច្ចរបស់មតកជនតាមចំណែកមត៌ករបស់ខ្លួន ហើយប្រសិនបើសន្តតិជនធ្វើការ

[78] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១២៧៨។

[79] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១២៧៩។

[80] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១២៥៦ កថាខណ្ឌទី១។

[81] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១២៥៦ កថាខណ្ឌទី២។

[82] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១២៥៧។

បោះបង់សន្តតិកម្មវិញ បុគ្គលនោះត្រូវចាត់ទុកថាពុំមែនជាសន្តតិជនតាំងពីដំបូង ហើយនេះមិនប៉ះពាល់ដល់ការបែងចែកមត៌កឡើយ ព្រោះម្ចាស់បំណុលត្រូវទាមទារក្រោយពេលបែងចែកមត៌កទៅតាមចំណែកមត៌កដែលបានបែងចែកទៅឱ្យសន្តតិជន។ ចំពោះការយល់ព្រមដោយកម្រិត ការជម្រះបញ្ជីត្រូវតែធ្វើមុនការបែងចែកមត៌ក ដែលគេហៅថានីតិវិធីជម្រះមត៌ក ព្រោះថាប្រសិនបើទ្រព្យសកម្មនៅសល់ទើបសន្តតិជនដែលយល់ព្រមដោយមានកម្រិតចាំបាច់ធ្វើការបែងចែកមត៌ក។

ប្រសិនបើមានតែសន្តតិជន សន្តតិជននោះត្រូវបន្តគ្រប់គ្រងមត៌ក ដោយប្រុងប្រយ័ត្ន ក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត។[83]ប៉ុន្តែ ប្រសិនបើមានសន្តតិជនច្រើន តុលាការត្រូវជ្រើសតាំងអ្នកគ្រប់គ្រងមត៌ក ពីក្នុងចំណោមសន្តតិជនទាំងនោះ។[84] អ្នកគ្រប់គ្រងមត៌កត្រូវបំពេញរាល់សកម្មភាពចាំបាច់ក្នុងការគ្រប់គ្រងមត៌ក និងសងកាតព្វកិច្ច ដើម្បីខ្លួនឯងផ្ទាល់ និងជំនួសសហសន្តតិជនដទៃទៀត។[85]

"ក្នុងករណីដែលសន្តតិជនបានយល់ព្រមដោយកម្រិត ម្ចាស់បំណុលរបស់មតកជនពុំអាចតាមទាមទារឱ្យសន្តតិជនទទួលខុសត្រូវ ចំពោះទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់សន្តតិជននោះបានឡើយ។" [86] ប៉ុន្តែប្រសិនបើ សន្តតិជនមានសិទ្ធិ និងកាតព្វកិច្ចលើមតកជន នឹងមិនអាចរលត់ដោយព្យាកុលភាពឡើយ មានន័យថាសន្តតិជនអាចតាំងខ្លួនជាម្ចាស់បំណុលដើម្បីទាមទារក្នុងពេលជម្រះមត៌កបាន។[87]

ក្រោយការយល់ព្រមដោយមានកម្រិត អ្នកយល់ព្រមដោយកម្រិត ឬអ្នកគ្រប់គ្រង[88] ត្រូវជូនដំណឹងជាសារធារណៈ នៅក្នុងអំឡុងពេល ៥(ប្រាំ)ថ្ងៃ បន្ទាប់ពីបានយល់ព្រមដោយកម្រិតហើយ ចំពោះម្ចាស់បំណុលរបស់មតកជន អំពីការណ៍ដែលខ្លួនបានយល់ព្រមដោយកម្រិត និងការណ៍ដែលម្ចាស់បំណុលត្រូវស្នើសុំអំពីការទាមទារនៅក្នុងអំឡុងពេលកំណត់ដែលមិនតិចជាង ២(ពីរ)ខែ។[89] ការជូនដំណឹងជាសាធារណៈនេះ ត្រូវសរសេរបន្ថែមថា បើម្ចាស់បំណុលមិនបានស្នើសុំនៅក្នុងអំឡុងពេលកំណត់នោះទេ សិទ្ធិលើបំណុលនោះនឹងត្រូវដកចេញពីការជម្រះ។ ប៉ុន្តែ អ្នកយល់ព្រមដោយកម្រិត ឬអ្នកគ្រប់គ្រង នោះមិនអាចដកម្ចាស់បំណុលចេញបានឡើយ ប្រសិនបើខ្លួនដឹងថាមានអត្ថិភាពនៃម្ចាស់បំណុល។[90] ហើយអ្នកយល់ព្រមដោយកម្រិត ឬអ្នកគ្រប់គ្រង ត្រូវ

---

[83] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១២៨០។
[84] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១២៨៩ កថាខណ្ឌទី១។
[85] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១២៨៩ កថាខណ្ឌទី២។
[86] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១២៥៨ កថាខណ្ឌទី១។
[87] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១២៥៨ កថាខណ្ឌទី២។
[88] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១២៨៩ កថាខណ្ឌទី៣។
[89] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១២៨១ កថាខណ្ឌទី១។
[90] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១២៨១ កថាខណ្ឌទី២។

ធ្វើការដាស់តឿនដោយឡែកៗ ចំពោះម្ចាស់បំណុលដែលខ្លួនបានដឹង។[91] នៅក្នុងអំឡុងពេលនៃការជូនដំណឹងជាសាធារណៈខាងលើ អ្នកយល់ព្រមដោយកម្រិត អាចបដិសេធការសងចំពោះម្ចាស់បំណុលរបស់មតកជនបាន។[92]

ក្រោយផុតអំឡុងពេលនៃការជូនដំណឹងជាសាធារណៈ អ្នកយល់ព្រមដោយកម្រិត ត្រូវយកមត៌កនោះមកសងឱ្យម្ចាស់បំណុលទៅតាមសមាមាត្រនៃចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលនីមួយៗ ទោះបីជាសិទ្ធិលើបំណុលមិនទាន់ដល់កំណត់សងក៏ដោយ[93] ប៉ុន្តែត្រូវគោរពទៅតាមលំដាប់នៃការសង ដូចខាងក្រោម៖

- លំដាប់ទី១ គឺម្ចាស់បំណុលដែលមានសិទ្ធិអាទិភាព។[94]
- លំដាប់ទី២ គឺម្ចាស់បំណុលដែលបានស្នើសុំនៅក្នុងអំឡុងពេលជូនដំណឹងជាសាធារណៈ និងម្ចាស់បំណុលផ្សេងទៀតដែលអ្នកយល់ព្រមដោយកម្រិតបានដឹង។[95]
- លំដាប់ទី៣ គឺម្ចាស់បំណុលដែលពុំបានស្នើសុំនៅក្នុងអំឡុងពេលនៃការជូនដំណឹងជាសាធារណៈ ហើយដែលអ្នកយល់ព្រមដោយមានកម្រិតពុំអាចដឹងបាន។[96]

នៅក្នុងដំណើរការនៃការសងចំពោះម្ចាស់បំណុលលំដាប់ទី១ និងទី២ ប្រសិនបើចាំបាច់ត្រូវលក់មត៌ក។ អ្នកយល់ព្រមដោយកម្រិត ត្រូវលក់មត៌ក តាមវិធីលក់ដោយបង្ខំ ឬលក់ក្នុងតម្លៃខ្ពស់ជាងការវាយតម្លៃរបស់អ្នកវាយតម្លៃដែលត្រូវបានជ្រើសរើសដោយតុលាការ។ អ្នកយល់ព្រមដោយមានកម្រិត ម្ចាស់បំណុលរបស់មតកជនអាចក្លាយជាអ្នកទិញដោយផ្ទាល់ខ្លួន នៅក្នុងការលក់ទាំងពីរវិធីខាងលើ។[97]

ចំណុចសំខាន់មួយទៀត គឺការទទួលខុសត្រូវក្នុងការសងសំណងការខូចខាតពីសំណាក់អ្នកយល់ព្រមដោយមានកម្រិត ឬពីសំណាក់ម្ចាស់បំណុលដែលបានទទួលការសងដោយដឹងអំពីភាពមិនត្រឹមត្រូវនៃការសង ប្រសិនបើអ្នកយល់ព្រមដោយមានកម្រិតនោះបានប្រព្រឹត្តសកម្មភាពដូចខាងក្រោម៖[98]

- មានការធ្វេសប្រហែសក្នុងការជូនដំណឹងជាសាធារណៈ ឬការដាស់តឿន
- ពុំអាចសងទៅម្ចាស់បំណុល ដោយសារបានសងទៅឱ្យម្ចាស់បំណុលណាផ្សេងនៅក្នុងអំឡុងពេលនៃការជូនដំណឹងជាសាធារណៈ ដោយមិនអនុវត្តសិទ្ធិបដិសេធការសង។

[91] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១២៨១ កថាខណ្ឌទី៣។
[92] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១២៨២។
[93] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១២៨៤ កថាខណ្ឌទី១។
[94] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១២៨៣ វាក្យខណ្ឌទី២។
[95] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១២៨៣ វាក្យខណ្ឌទី១។
[96] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១២៨៨ វាក្យខណ្ឌទី១។
[97] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១២៨៦។
[98] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១២៨៧។

### ១.២.៣. ការបោះបង់សន្តតិកម្មតាមច្បាប់

ក្រៅពីការយល់ព្រមទាំងស្រុង និងការយល់ព្រមដោយមានកម្រិតចំពោះសន្តតិកម្ម សន្តតិជនអាចធ្វើការបោះបង់សន្តតិកម្មបាន "បុគ្គលដែលមានបំណងបោះបង់សន្តតិកម្ម ត្រូវដាក់ពាក្យសុំការបោះបង់សន្តតិកម្ម នោះទៅតុលាការ។"[99] ការដាក់ពាក្យសុំនេះត្រូវធ្វើឡើងតាមនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង។ "បុគ្គលដែលបានបោះបង់សន្តតិកម្មត្រូវចាត់ទុកថា បុគ្គលនោះមិនមែនជាសន្តតិជនចំពោះសន្តតិកម្មតាំងពីដំបូង។"[100]

### ១.២.៤. ការលុបចោលការបោះបង់សន្តតិកម្មតាមច្បាប់

ជាគោលការណ៍ ការបោះបង់សន្តតិកម្មមិនអាចធ្វើការលុបចោលបានឡើយ ទោះបីជាការលុបចោលនោះធ្វើឡើងនៅក្នុងអំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ មាត្រា ១២៤៨ (អំឡុងពេលនៃការយល់ព្រម ឬការបោះបង់) នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ ក៏ដោយ។[101]

ប៉ុន្តែ ប្រសិនបើការលុបចោលនោះធ្វើឡើងដោយយកមូលហេតុមានវិការៈក្នុងការបង្ហាញឆន្ទៈ សន្តតិជនមានសិទ្ធិដាក់ពាក្យសុំលុបចោលទៅតុលាការ[102] ក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ គិតចាប់ពីពេលដែលអាចផ្តល់សច្ចានុមតិបាន។ ហើយប្រសិនបើសន្តតិជនពុំបានអនុវត្តសិទ្ធិលុបចោលនេះ នៅក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ គិតចាប់ពីពេលដែលអាចផ្តល់សច្ចានុមតិបាន ឬប្រសិនបើសន្តតិជនពុំអនុវត្តសិទ្ធិលុបចោលក្នុងអំឡុងពេល ៥ (ប្រាំ) ឆ្នាំ គិត ចាប់ពីពេលដែលចាប់ផ្តើមសន្តតិកម្ម នោះសិទ្ធិលុបចោលត្រូវរលត់។[103]

## ១.៣. ការសម្រួលចំណែកមត៌ក

ការសម្រួលចំណែកមត៌ក ជាវិធានដែលបង្កើតឡើងដើម្បីធានានូវសមភាពលើមត៌ករវាងសន្តតិជនទាំងអស់។ ការសម្រួលចំណែកមត៌កធ្វើឡើងពេលមានស្ថានភាពពីរកើតឡើង ទីមួយគឺនៅពេលមានអ្នកទទួលផលប្រយោជន៍ពិសេស(**១.៣.១**) និងទីពីរនៅពេលមានអ្នកបានធ្វើវិភាគទាន(**១.៣.២**)។

### ១.៣.១. ចំណែកមត៌ករបស់អ្នកទទួលផលប្រយោជន៍ពិសេស

ក្នុងចំណោមសហសន្តតិជនទាំងអស់ ប្រសិនបើមានបុគ្គលណាបានទទួលប្រទានកម្ម នៅក្នុងឱកាសអាពាហ៍ពិពាហ៍ ឬហេតុការណ៍ផ្សេងទៀត ឬដើម្បីមូលធននៃជីវភាពរស់នៅ នោះតម្លៃសរុបនៃមត៌កដែលមតកជន

---

[99] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១២៦០។

[100] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១២៦១ថ្មី។

[101] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១២៥២ កថាខណ្ឌទី១។

[102] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១២៥២ កថាខណ្ឌទី៣។

[103] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១២៥២ កថាខណ្ឌទី២។

មាននៅពេលចាប់ផ្ដើមសន្តតិកម្ម ដោយបូកបញ្ចូលនូវតម្លៃនៃប្រទានកម្ម ត្រូវបានចាត់ទុកជាមត៌កសម្រាប់យកមកបែងចែកឱ្យសន្តតិជនទាំងអស់។[104]

➢មត៌កសម្រាប់បែងចែក = មត៌កដែលមតកជនមានពេលចាប់ផ្ដើមសន្តតិកម្ម + តម្លៃនៃប្រទានកម្ម

ក្រោយពីកំណត់មត៌កសម្រាប់បែងចែករួចហើយ យើងអាចប្រើប្រាស់មត៌កដែលបានគណនាខាងលើទៅកំណត់នូវចំណែកមត៌កតាមច្បាប់របស់សន្តតិជនដែលបានទទួលផលប្រយោជន៍ពិសេស។ ដោយសារតែច្បាប់បានកំណត់ចំណែកមត៌កទុកជាមុនសម្រាប់សន្តតិជនចំពោះសន្តតិកម្មតាមច្បាប់ ហេតុដូច្នេះហើយ ដើម្បីកំណត់នូវចំណែកមត៌ករបស់សន្តតិជនដែលបានទទួលផលប្រយោជន៍ពិសេស គេត្រូវយកចំណែកមត៌ករបស់សន្តតិជនដែលបានគណនាតាមបញ្ញត្តិនៃផ្នែកទី១(សន្តតិជន) និងផ្នែកទី២(សន្តតិកម្មរបស់សហព័ទ្ធ) ដោយប្រើប្រាស់មត៌កសម្រាប់បែងចែកខាងលើជាមូលដ្ឋាន ដកនឹងតម្លៃនៃប្រទានកម្មចេញ។

➢ចំណែកមត៌កអ្នកទទួលផលប្រយោជន៍ពិសេស = ចំណែកមត៌កតាមច្បាប់របស់សន្តតិជន - តម្លៃនៃប្រទានកម្ម

ក្រោយការសម្រួល ប្រសិន "បើតម្លៃនៃប្រទានកម្ម ឬអច្ច័យទាន ស្មើគ្នានឹងតម្លៃនៃចំណែកមត៌ក ឬលើសពីតម្លៃនៃចំណែកមត៌ក សហសន្តតិជននោះពុំអាចទទួលយកចំណែកមត៌កនោះបានឡើយ"។[105] ប៉ុន្តែ សហសន្តតិជនក៏មិនចាំបាច់បង្វិលមកវិញនូវទ្រព្យសម្បត្តិដែលទាក់ទងនឹងប្រទានកម្ម ដើម្បីសហសន្តតិជនផ្សេងទៀតឡើយ លើកលែងតែត្រូវកាត់បន្ថយដើម្បីភាគបម្រុង។[106] ក្នុងករណីដែលតម្លៃនៃប្រទានកម្មលើសពីចំណែកមត៌ក ចំណែកមត៌ករបស់សន្តតិជនផ្សេងទៀតត្រូវគណនាដោយយកមត៌កដែលមតកជនមាននៅពេលចាប់ផ្ដើមសន្តតិកម្ម ទៅបែងចែកតាមសមាមាត្រនៃចំណែកមត៌ករបស់សហសន្តតិជននីមួយៗ ដែលបានកំណត់ខាងលើ។[107]

➢ ចំណែកមត៌កជាក់ស្ដែង = មត៌កដែលមតកជនមានពេលចាប់ផ្ដើមសន្តតិកម្ម X ចំណែកមត៌ករបស់សន្តតិជន ÷ តម្លៃសរុបនៃចំណែកមត៌ករបស់សហសន្តតិជន

ដើម្បីធ្វើការសម្រួលចំណែកមត៌កឱ្យបានត្រឹមត្រូវចំណុចសំខាន់មួយទៀតដែលគេត្រូវធ្វើ គឺកំណត់នូវតម្លៃនៃប្រទានកម្ម។ ការកំណត់តម្លៃប្រទានកម្មត្រូវបែងចែកជាពីរករណី។

➢ ករណីទីមួយ ៖ ប្រសិនបើបដិគ្គាហក បានចាត់ចែងទ្រព្យសម្បត្តិដែលខ្លួនទទួលដោយប្រទានកម្ម នៅមុនពេលចាប់ផ្ដើមសន្តតិកម្ម ឬបើទ្រព្យសម្បត្តិនោះត្រូវបានបាត់ ឬវិនាស នៅមុនពេលចាប់ផ្ដើមសន្តតិកម្ម។ តម្លៃនៃប្រទានកម្មត្រូវគណនាដោយគិតតម្លៃនៅពេលដែលបានចាត់ចែង ឬនៅពេលបាត់បង់ ឬវិនាសនោះ។[108]

[104] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១១៦៣ កថាខណ្ឌទី១។
[105] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១១៦៣ កថាខណ្ឌទី២។
[106] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១១៦៥ កថាខណ្ឌទី១។
[107] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១១៦៥ កថាខណ្ឌទី២។
[108] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១១៦៤ វាក្យខណ្ឌទី១។

➢ ករណីទីពីរ ៖ ប្រសិនបើតម្លៃនៃប្រទានកម្មនោះត្រូវបានផ្លាស់ប្តូរ ដោយសារលទ្ធផលដែលបដិគ្គាហក បានផ្លាស់ប្តូរទ្រព្យសម្បត្តិនោះមួយផ្នែក។ តម្លៃនៃប្រទានកម្មនោះត្រូវបានគណនាដោយចាត់ទុកថា មានស្ថានភាពដើមនៅពេលចាប់ផ្តើមសន្តតិកម្ម។[109]

សូមបញ្ជាក់ថា "ការប្រាក់ និងផលចំណេញ ដែលកើតចេញពីប្រទានកម្ម ដែលសន្តតិជននោះបានទទួល ពុំត្រូវគណនាចូលក្នុងតម្លៃនោះឡើយ"។[110]

### ១.៣.២. ចំណែកមត៌ករបស់អ្នកបានធ្វើវិភាគទាន

ក្នុងចំណោមសហសន្តតិជនទាំងឡាយ បើមានបុគ្គលណាបានធ្វើវិភាគទានពិសេស ដើម្បីថែរក្សា ឬបង្កើនទ្រព្យសម្បត្តិរបស់មតកជន ដោយការផ្តល់សេវាកម្មលើកិច្ចការរបស់មតកជន ឬដោយការផ្តល់តាវកាលិកលើទ្រព្យសម្បត្តិ ឬដោយការថែទាំព្យាបាលមតកជន ឬដោយវិធីផ្សេងទៀត នោះតម្លៃសរុបនៃមត៌កដែលមតកជនមាននៅពេលចាប់ផ្តើមសន្តតិកម្ម ដកនូវតម្លៃភាគនៃវិភាគទានរបស់បុគ្គលនោះដែលបានកំណត់តាមការពិភាក្សារបស់សហសន្តតិជនចេញ ត្រូវបានចាត់ទុកជាមត៌កសម្រាប់យកមកបែងចែកឱ្យសន្តតិជនទាំងអស់។[111]

➢មត៌កសម្រាប់បែងចែក = មត៌កដែលមតកជនមានពេលចាប់ផ្តើមសន្តតិកម្ម - តម្លៃភាគនៃវិភាគទាន

ក្រោយពីកំណត់មត៌កសម្រាប់បែងចែករួចហើយ យើងអាចប្រើប្រាស់មត៌កដែលបានគណនាខាងលើទៅកំណត់នូវចំណែកមត៌កតាមច្បាប់របស់សន្តតិជនដែលបានធ្វើវិភាគទានពិសេស ដូចគ្នានឹងករណីចំណែកមត៌ករបស់សន្តតិជនដែលបានទទួលផលប្រយោជន៍ពិសេសដែរ។ ក្រោយពេលគេកំណត់ចំណែកមត៌ករបស់សន្តតិជនរួចហើយ គេត្រូវយកចំណែកមត៌ករបស់សន្តតិជនដែលបានគណនាតាមបញ្ញត្តិនៃផ្នែកទី១(សន្តតិជន) និងផ្នែកទី២(សន្តតិកម្មរបស់សហព័ទ្ធ) ដោយប្រើប្រាស់មត៌កសម្រាប់បែងចែកខាងលើជាមូលដ្ឋាន បូកនឹងភាគវិភាគទាន។[112]

➢ចំណែកមត៌កអ្នកដែលបានធ្វើវិភាគទានពិសេស = ចំណែកមត៌កតាមច្បាប់របស់សន្តតិជន + តម្លៃភាគនៃវិភាគទាន

ដូចគ្នានឹងករណីផលប្រយោជន៍ពិសេសដែរ ដើម្បីធ្វើការសម្រួលចំណែកមត៌កឱ្យបានត្រឹមត្រូវចំណុចសំខាន់ដែល គេត្រូវធ្វើ គឺកំណត់នូវភាគនៃវិភាគទាន។ ការកំណត់តម្លៃភាគនៃវិភាគទានត្រូវបែងចែកជាពីរករណី។

➢ ករណីទីមួយ ៖ តម្លៃភាគនៃវិភាគទានត្រូវកំណត់តាមការពិភាក្សារបស់សហសន្តតិជន។[113]

---

109 ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១១៦៤ វាក្យខណ្ឌទី២។
110 ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១១៦៤ វាក្យខណ្ឌទី៣។
111 ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១១៦៦ កថាខណ្ឌទី១។
112 ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១១៦៦ កថាខណ្ឌទី១។
113 ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១១៦៦ កថាខណ្ឌទី១។

➢ ករណីទីពីរ ៖ បើការពិភាក្សានៅក្នុងករណីទីមួយពុំបានសម្រេច ឬបើពុំអាចពិភាក្សាបានទេ បុគ្គលដែលបានផ្ញើវិភាគទានត្រូវដាក់ពាក្យសុំទៅតុលាការដើម្បីកំណត់ភាគនៃវិភាគទាន។ តុលាការនឹងកំណត់ដោយពិចារណាទៅលើពេល វិធី និងកម្រិតនៃវិភាគទាននោះ ចំនួនទឹកប្រាក់នៃមត៌ក និងស្ថានភាពទាំងអស់ផ្សេងទៀត។[114] ការដាក់ពាក្យសុំនេះអាចធ្វើបានតែក្នុងករណីដែលមានពាក្យសុំតាមកថាខណ្ឌទី១ នៃមាត្រា ១២៧០ (ការបែងចែកដោយតុលាការ) ឬមានពាក្យបណ្តឹងតាមមាត្រា ១២៧៤ (ការទាមទាររបស់ជនដែលត្រូវបានទទួលស្គាល់ក្រោយការបែងចែកមត៌ក) តែប៉ុណ្ណោះ។[115]

## ១.៤. ភាគបម្រុង

ភាគបម្រុង គឺជារបបមួយដែលច្បាប់បង្កើតឡើងដើម្បីធានានូវភាគនៃចំណែកមត៌កតាមច្បាប់របស់សន្តតិជនមួយចំនួន ដើម្បីការពារនូវផលប្រយោជន៍របស់សន្តតិជនមួយចំនួននោះនៅក្នុងកម្រិតមួយដែលចាំបាច់។ នៅក្នុងន័យទូទៅ ភាគបម្រុងជាការសម្រួលចំណែកមត៌ករបស់សន្តតិជនរវាងសន្តតិកម្មតាមមតកសាសន៍ និងសន្តតិកម្មតាមច្បាប់។ ប៉ុន្តែ ភាគបម្រុងនៅក្នុងអត្ថបទសារណានេះ គឺជាការសម្រួលចំណែកមត៌ករវាងជនដែលសន្មតថាជាសន្តតិជនក្រោយបានបាត់បង់សិទ្ធិសន្តតិកម្មតែទទួលបានប្រទានកម្មក្នុងចំនួនដ៏ច្រើន ឬសន្តតិជនដែលទទួលបានផលប្រយោជន៍ពិសេសក្នុងចំនួនដ៏ច្រើន ជាមួយនឹងសន្តតិជនដែលរងការបំពានភាគបម្រុង។ នៅក្នុងចំណុចនេះ យើងនឹងសិក្សាទៅលើបញ្ញត្តិទូទៅស្តីពីភាគបម្រុង(**ចំណុច ១.៤.១**) វិធីកាត់បន្ថយភាគបម្រុង (**ចំណុច ១.៤.២**) និងការរំលត់សិទ្ធិទាមទារឱ្យកាត់បន្ថយ(**ចំណុច ១.៤.៣**)។

### ១.៤.១. បញ្ញត្តិទូទៅស្តីពីភាគបម្រុង

នៅក្នុងចំណុចនេះ យើងនឹងធ្វើការកំណត់អំពីទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង(**ចំណុច ១.៤.១.១**) អ្នកមានសិទ្ធិលើភាគបម្រុង(**ចំណុច ១.៤.១.២**) និងចំនួនទឹកប្រាក់នៃការទាមទារឱ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង(**ចំណុច ១.៤.១.៣**)។

#### ១.៤.១.១. ទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង

ទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងក្នុងស្ថានភាពនៃប្រធានបទសារណានេះរួមមាន ការទទួលផលប្រយោជន៍ពិសេស និងប្រទានកម្មដែលបានកំណត់នៅក្នុងមាត្រា ១២៣២ (ប្រទានកម្មដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុង)។[116] ក៏ប៉ុន្តែ ប្រសិនបើការទទួលផលប្រយោជន៍ពិសេសរបស់សន្តតិជនណាម្នាក់ដែលនឹងត្រូវកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងឱ្យសន្តតិជនដែលរងការបំពានភាគបម្រុង

[114] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១១៦៦ កថាខណ្ឌទី២។
[115] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១១៦៦ កថាខណ្ឌទី៤។
[116] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១២៣៣ វាក្យខណ្ឌទី១។

ការកាត់បន្ថយនោះមានត្រឹមតែផ្នែកដែលលើសពីចំនួនទឹកប្រាក់នៃភាគបម្រុងរបស់សន្តតិជនដែលនឹងត្រូវកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងនោះតែប៉ុណ្ណោះ[117]ដើម្បីកុំឱ្យមានការបំពានភាគបម្រុងរបស់សន្តតិជនទាំងអស់។

**១.៤.១.២. អ្នកមានសិទ្ធិលើភាគបម្រុង**

អ្នកមានសិទ្ធិលើភាគបម្រុងរួមមាន បច្ឆាញាតិផ្ទាល់ ឬឪពុកម្តាយ ឬជីដូនជីតា និង សហព័ទ្ធរបស់មតកជន។[118] ប៉ុន្តែ ចំពោះសន្តតិជនជំនួសរបស់បច្ឆាញាតិផ្ទាល់ក៏ត្រូវបានចាត់ទុកថាជាអ្នកមានសិទ្ធិលើភាគបម្រុងផងដែរ។[119]

ក្នុងករណីដែលអ្នកមានសិទ្ធិលើភាគបម្រុងមានតែសន្តតិជនជាឪពុកម្តាយ ឬជីដូន ជីតា នោះឪពុកម្តាយ ឬជីដូនជីតា អាចធ្វើលទ្ធកម្មនូវទ្រព្យសម្បត្តិ ១ ភាគ ៣ (មួយភាគីបី) នៃទ្រព្យសម្បត្តិរបស់មតកជន។[120] ផ្ទុយពីករណីខាងលើ អ្នកមានសិទ្ធិលើភាគបម្រុង អាចធ្វើលទ្ធកម្មនូវទ្រព្យសម្បត្តិ ១ ភាគ ២ (មួយភាគីពីរ) នៃទ្រព្យសម្បត្តិរបស់មតកជន។[121]

ទ្រព្យសម្បត្តិរបស់មតកជនដែលកំណត់ខាងលើសំដៅទៅលើទ្រព្យដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុងតាមមាត្រា ១២៣១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

"ក្នុងករណីដែលមានសន្តតិជនច្រើននាក់ អ្នកមានសិទ្ធិលើភាគបម្រុងនីមួយៗអាចទទួលភាគបម្រុង តាមសមាមាត្រនៃចំណែកមត៌កបាន។"[122] មានន័យថា អ្នកមានសិទ្ធិលើភាគបម្រុងត្រូវទទួលភាគបម្រុងផ្អែកទៅតាមសមាមាត្រនៃចំណែកមត៌ករបស់ខ្លួនដែលត្រូវបានកំណត់ដោយច្បាប់សម្រាប់សន្តតិជន ព្រមទាំងចំណែកមត៌កសម្រាប់សន្តតិជនជំនួស[123] ដែលរួមមាន៖

- ចំណែកមត៌ករបស់សន្តតិជនលំដាប់ទី១
- ចំណែកមត៌ករបស់សន្តតិជនជំនួសរបស់សន្តតិជនលំដាប់សន្តតិជនទី១
- ចំណែកមត៌ករបស់សន្តតិជនលំដាប់ទី២ ដែលរួមបញ្ចូលត្រឹមឪពុកម្តាយ ឬជីដូនជីតា របស់មតកជនតែប៉ុណ្ណោះ
- ចំណែកមត៌ករបស់សន្តតិជនជានិច្ច។

[117] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១២៣៣ វាក្យខណ្ឌទី២។
[118] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១២៣០ កថាខណ្ឌទី១។
[119] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១២៣០ កថាខណ្ឌទី៣។
[120] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១២៣០ ចំណុច ក ។
[121] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១២៣០ ចំណុច ខ ។
[122] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១២៣០ កថាខណ្ឌទី២។
[123] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១២៣០ កថាខណ្ឌទី៣។

### ១.៤.១.៣. ចំនួនទឹកប្រាក់នៃការទាមទារឱ្យកាត់បន្ថយដើម្បីបង្រ្គប់ភាគបម្រុង

អ្នកមានសិទ្ធិលើភាគបម្រុងអាចទាមទារឱ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងត្រឹមចំនួនទឹកប្រាក់មួយដែលត្រូវបានគណនាដោយយក៖[124]

- ចំនួនទឹកប្រាក់នៃភាគបម្រុង
- ដកចេញ ចំនួនសរុបនៃទ្រព្យសម្បត្តិដែលអ្នកមានសិទ្ធិលើភាគបម្រុងបានទទួលដោយសន្តតិកម្ម
- ដកចេញ ចំនួននៃផលប្រយោជន៍ពិសេស ដែលបានកំណត់នៅក្នុងមាត្រា ១១៦៣ ស្តីពីចំណែកមត៌ករបស់អ្នកទទួលផលប្រយោជន៍ពិសេស)
- បូកនឹង ចំនួនទឹកប្រាក់នៃកាតព្វកិច្ចដែលបុគ្គលនោះត្រូវទទួលបន្ទុកដោយសន្តតិកម្ម។

ជំហានបន្ទាប់យើងត្រូវកំណត់ពី ចំនួនទឹកប្រាក់នៃភាគបម្រុងរបស់សន្តតិជនដែលត្រូវបានបំពានភាគបម្រុង។ ចំនួនទឹកប្រាក់នៃភាគបម្រុង ត្រូវគណនាដោយយក៖[125]

- ទ្រព្យសម្បត្តិដែលមតកជនមាននៅពេលចាប់ផ្តើមសន្តតិកម្ម
- បូកនឹង ផលប្រយោជន៍ពិសេស
- បូកនឹង តម្លៃនៃប្រទានកម្ម
- ដកចេញ នូវចំនួនប្រាក់សរុបនៃកាតព្វកិច្ច។

ចំពោះតម្លៃប្រទានកម្មខាងលើ គឺជាប្រទានកម្មដែលខុសពីប្រទានកម្មដែលជាផលប្រយោជនពិសេស ព្រោះថាប្រទានកម្មដែលជាផលប្រយោជន៍ពិសេស គឺផ្តល់ជូនសន្តតិជន។ រីឯ ប្រទានកម្មនៅទីនេះ គឺផ្តល់ជូនជនក្រៅពីសន្តតិជន ហើយការលើកលែងកាតព្វកិច្ចដោយមិនយកតម្លៃថ្នូរក៏ត្រូវចាត់ទុកថាជាប្រទានកម្មដែរ។[126] ប្រទានកម្មទាំងនោះរួមមាន៖[127]

- ប្រទានកម្មដែលបានធ្វើក្នុងអំឡុងពេល ១(មួយ)ឆ្នាំ នៅមុនពេលចាប់ផ្តើមសន្តតិកម្ម។
- ប្រទានកម្មដែលបានត្រូវធ្វើឡើងដោយភាគីសងខាងដឹងថា នឹងបណ្តាលឱ្យខូចខាតដល់អ្នកមានសិទ្ធិលើភាគបម្រុង។

ក្រោយពីកំណត់ចំនួនទឹកប្រាក់នៃភាគបម្រុងរួច ត្រូវយកចំនួននោះទៅគណនាតាមភាគរបស់អ្នកមានសិទ្ធិលើភាគបម្រុង។

---

[124] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១២៣៤។

[125] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១២៣១ កថាខណ្ឌទី១។

[126] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១២៣២ កថាខណ្ឌទី២។

[127] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១២៣២ កថាខណ្ឌទី១។

### ១.៤.២. វិធីកាត់បន្ថយ

ការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង គឺជាវិធានមួយដើម្បីស្តារផលប្រយោជន៍របស់សន្តតិជនដែលមានសិទ្ធិលើភាគបម្រុង ឱ្យទទួលបាននូវសិទ្ធិរបស់ខ្លួនតាមកំណត់ច្បាប់។ អ្នកមានសិទ្ធិលើភាគបម្រុង និងអ្នកទទួលបន្តនោះ អាចបង្ហាញឆន្ទៈទាមទារឱ្យធ្វើការកាត់បន្ថយប្រទានកម្ម និងការទទួលផលប្រយោជន៍ពិសេសចំពោះជនដែលបានទទួលទ្រព្យសម្បត្តិ ឬផលប្រយោជន៍ដែលជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងបាន ត្រឹមកម្រិតដែលចាំបាច់ដើម្បីរក្សាភាគបម្រុងនោះ។ ការកាត់បន្ថយប្រទានកម្ម ឬការទទួលផលប្រយោជន៍ពិសេសត្រូវគោរពទៅតាមលំដាប់នៃការកាត់បន្ថយ(**១.៤.២.១**) ហើយការកាត់បន្ថយក៏បង្កើតបាននូវអានុភាពមួយចំនួនផងដែរ(**១.៤.២.២**)។

#### ១.៤.២.១. លំដាប់នៃការកាត់បន្ថយប្រទានកម្ម ឬផលប្រយោជន៍ពិសេស

"ការកាត់បន្ថយប្រទានកម្ម ឬការទទួលផលប្រយោជន៍ពិសេស ត្រូវចាប់ផ្តើមពីប្រទានកម្ម ឬការទទួលផលប្រយោជន៍ពិសេសដែលបានធ្វើក្រោយគេ បន្ទាប់មក ត្រូវធ្វើចំពោះប្រទានកម្ម ឬការទទួលផលប្រយោជន៍ពិសេសដែលបានធ្វើពីមុនមកជាបន្តបន្ទាប់។"[128] ប៉ុន្តែ ចំពោះប្រទានកម្ម ឬការទទួលផលប្រយោជន៍ពិសេស ដែលបានធ្វើលើសពី ២០(ម្ភៃ)ឆ្នាំ នៅមុនពេលចាប់ផ្តើមសន្តតិកម្ម បដិគ្គាហក ឬសន្តតិជនដែលបានទទួលផលប្រយោជន៍ពិសេសនោះអាចបដិសេធនូវការទាមទារកាត់បន្ថយដើម្បីបង្គប់ភាគបម្រុងបាន។[129]

សូមបញ្ជាក់ថានៅក្នុងករណីខ្លះ ការកាត់បន្ថយត្រូវធ្វើចំពោះប្រទានកម្មដែលមានភ្ជាប់បន្ទុក ឬកិច្ចសន្យាដែលត្រូវចាត់ទុកថាជាប្រទានកម្ម ឬករណីខ្លះទៀតមានការចាត់ចែងកម្មវត្ថុនៃប្រទានកម្ម។

- ចំពោះប្រទានកម្មដែលមានភ្ជាប់បន្ទុក តម្លៃដែលអាចទាមទារឱ្យកាត់បន្ថយបានមានត្រឹមតម្លៃដែលបានមកពីការដកតម្លៃនៃបន្ទុកចេញពីក្នុងតម្លៃនៃកម្មវត្ថុតែប៉ុណ្ណោះ។[130]
- ចំពោះកិច្ចសន្យាដែលបានធ្វើឡើងដោយយកតម្លៃថ្នូរមិនត្រឹមត្រូវ ឬការលើកលែងកាតព្វកិច្ចដោយយកតម្លៃថ្នូរមិនត្រឹមត្រូវ ត្រូវចាត់ទុកថាជាប្រទានកម្ម តែក្នុងករណីដែលភាគីទាំងសងខាងបានដឹងថានឹងបណ្តាលឲ្យខូចខាតដល់អ្នកមានសិទ្ធិលើភាគបម្រុងប៉ុណ្ណោះ។
- បើសហសន្តតិជន ឬបដិគ្គាហក ដែលត្រូវទទួលការកាត់បន្ថយនោះ បានធ្វើអនុប្បទាននូវកម្មវត្ថុនៃប្រទានកម្មទៅឱ្យអ្នកដទៃ ឬបានបង្កើតសិទ្ធិលើកម្មវត្ថុនៃប្រទានកម្ម ជននោះត្រូវសងចំនួនទឹកប្រាក់ក្នុងកម្រិតនៃតម្លៃនៅពេលដែលបានចាតចែងនោះ ទៅឱ្យអ្នកមានសិទ្ធិលើភាគបម្រុង។ ហើយអ្នកមានសិទ្ធិលើភាគបម្រុងក៏អាច

[128] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១២៣៨ កថាខណ្ឌទី១។
[129] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១២៣៨ កថាខណ្ឌទី២។
[130] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១២៤១។

ទាមទារឱ្យកាត់បន្ថយចំពោះអនុប្បទានិកនោះបាន ប្រសិនបើអនុប្បទានិកបានដឹងថា នឹងបណ្តាលឱ្យមានការខូចខាតដល់អ្នកមានសិទ្ធិលើភាគបម្រុង។[131]

ការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងអាចធ្វើដោយបង់សំណងជាតម្លៃជំនួសបាន។ សហសន្តតិជន ឬបដិគ្គាហក អាចរួចផុតពីកាតព្វកិច្ចនៃការសងបាន ដោយបង់ តម្លៃនៃកម្មវត្ថុនៃប្រទានកម្ម ឬតម្លៃនៃសិទ្ធិដែលបានបង្កើតលើកម្មវត្ថុនៃប្រទានកម្ម ទៅឱ្យអ្នកមានសិទ្ធិលើភាគបម្រុង ត្រឹមកម្រិតដែលត្រូវកាត់បន្ថយ។[132]

**១.៤.២.២. អានុភាពក្រោយការកាត់បន្ថយ**

ក្រោយពេលកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង សហសន្តតិជន ឬបដិគ្គាហក ត្រូវតែសងមកវិញនូវទ្រព្យសម្បត្តិ ប្រាក់សំណង[133] និងផលទាំងឡាយដែលកើតឡើងដោយគិតចាប់ពីថ្ងៃដែលបានទាមទារឱ្យធ្វើការកាត់បន្ថយ[134]។

ផ្ទុយទៅវិញ ប្រសិនបើមានការខាតបង់ដែលកើតឡើងដោយសារអសាធនភាពរបស់សហសន្តតិជន ឬបដិគ្គាហកដែលត្រូវទទួលការកាត់បន្ថយ ការខាតបង់នោះត្រូវជាបន្ទុករបស់អ្នកមានសិទ្ធិភាគបម្រុង មានន័យថា ប្រសិនបើសហសន្តតិជន ឬបដិគ្គាហក មិនអាចសងទ្រព្យដែលទទួលពីមតកជនវិញបាន ឬមិនអាចសងនូវតម្លៃនៃទ្រព្យនោះបាន ក៏អ្នកមានសិទ្ធិលើភាគបម្រុងពុំអាចទាមទារឱ្យអ្នកមានកាតព្វកិច្ចសងនៅលំដាប់បន្ទាប់ សងនូវចំណែកដែលទាមទារមិនបានគ្រប់នោះទេ ឬបង្ខំឱ្យអ្នកមានកាតព្វកិច្ចប៉ុន្តែស្ថិតក្នុងស្ថានភាពអសាធនភាពត្រូវតែសងដែរ។[135]

**១.៤.៣. ការរំលត់សិទ្ធិទាមទារឱ្យកាត់បន្ថយ**

សិទ្ធិក្នុងការទាមទារលើភាគបម្រុង គឺជាសិទ្ធិដែលមានអាជ្ញាយុកាលកំណត់ច្បាស់លាស់ ដោយសន្តតិជនដែលអ្នកមានសិទ្ធិលើភាគបម្រុងមិនអាចទាមទារបានតាមចិត្តគ្រប់ពេលឡើយ ការកំណត់បែបនេះ គឺធ្វើឡើងដើម្បីធានានូវស្ថេរភាពនៃទំនាក់ទំនងគតិយុត្ត និងការពារផលប្រយោជន៍របស់ជនពាក់ព័ន្ធ។ ក៏ប៉ុន្តែសន្តតិជនក៏អាចបោះបង់នូវភាគបម្រុងផងដែរ ប្រសិនបើមិនចង់ទទួលយកភាគបម្រុង។ ហើយទោះបីជាសិទ្ធិទាមទារឱ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងរបស់សន្តតិជនណាម្នាក់ត្រូវបានរលត់ដោយសារអាជ្ញាយុកាល ឬសន្តតិជនណាម្នាក់បានបោះបង់ភាគបម្រុង ក៏សកម្មភាពនោះគ្មានឥទ្ធិពលទៅលើភាគបម្រុងរបស់សន្តតិជនផ្សេង

[131] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១២៤៣។
[132] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១២៤៤។
[133] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១២៣៥។
[134] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១២៣៩។
[135] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១២៤០។

ទៀតឡើយ។[136] នៅក្នុងចំណុចនេះយើងនឹងធ្វើការសិក្សាអំពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិ(១.៤.៣.១) និងការបោះបង់ភាគបម្រុង(១.៤.៣.២) ។

### ១.៤.៣.១. អាជ្ញាយុកាលនៃការរំលត់សិទ្ធិទាមទារឱ្យកាត់បន្ថយ

ការរំលត់សិទ្ធិទាមទារឱ្យកាត់បន្ថយកើតឡើងដោយសារការមិនអនុវត្តសិទ្ធិក្នុងអំឡុងពេលដែលបានកំណត់ក្នុងច្បាប់។ សិទ្ធិទាមទារឲ្យកាត់បន្ថយត្រូវរលត់ដោយអាជ្ញាយុកាលដូចខាងក្រោម៖[137]

- បើអំឡុងពេល ១(មួយ)ឆ្នាំ បានកន្លងហួស គិតចាប់ពីពេលដែលអ្នកមានសិទ្ធិលើភាគបម្រុងបានដឹងអំពីការចាប់ផ្តើមសន្តតិកម្ម និងប្រទានកម្ម ឬការទទួលផលប្រយោជន៍ពិសេសដែលត្រូវបានកាត់បន្ថយ។
- បើអំឡុងពេល ៥(ប្រាំ)ឆ្នាំ បានកន្លងហួសគិតចាប់ពីពេលចាប់ផ្តើមសន្តតិកម្ម។

### ១.៤.៣.២. ការបោះបង់ភាគបម្រុង

អ្នកមានសិទ្ធិលើភាគបម្រុង ប្រសិនបើមានបំណងចង់បោះបង់ភាគបម្រុង អាចបោះបង់ភាគបម្រុងចោលទាំងអស់ ឬមួយផ្នែកបាន។

ការបោះបង់ភាគបម្រុងអាចធ្វើបានមុនពេលចាប់ផ្តើមសន្តតិកម្ម ឬក្រោយពេលចាប់ផ្តើមសន្តតិកម្ម។ ក្រោយពេលចាប់ផ្តើមសន្តតិកម្ម ការបោះបង់ភាគបម្រុងអាចធ្វើបានដោយគ្រាន់តែបង្ហាញឆន្ទៈតែម្ខាងចំពោះអ្នកមានកាតព្វកិច្ចប៉ុណ្ណោះ។ "ប៉ុន្តែ ការបោះបង់ភាគបម្រុងនៅមុនពេលចាប់ផ្តើមសន្តតិកម្ម មានអានុភាព លុះត្រាតែបានទទួលការអនុញ្ញាតពីតុលាការ។"[138]

[136] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១២៤៧។

[137] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១២៤៥។

[138] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១២៤៦ វាក្យខណ្ឌទី២។

# ជំពូកទី២
# ការទទួលបានសន្តតិកម្មតាមច្បាប់

# ជំពូកទី២
# ការទទួលបានសន្តតិកម្មតាមច្បាប់

ចំពោះសន្តតិកម្មដែលមានសន្តតិជនតែម្នាក់ មិនមានភាពស្មុគស្មាញនោះទេសម្រាប់សន្តតិជនក្នុងការទទួលបានសន្តតិកម្មតាមច្បាប់ ព្រោះថាក្រោយពីសន្តតិជនបានបង្ហាញឆន្ទៈយល់ព្រមទាំងស្រុង សន្តតិជននឹងត្រូវទទួលបន្តនូវសិទ្ធិ និងករណីយកិច្ចរបស់មតកជនទាំងស្រុង ឬប្រសិនបើសន្តតិជនបានបង្ហាញឆន្ទៈយល់ព្រមដោយមានកម្រិត សន្តតិជននឹងត្រូវទទួលបន្តនូវសិទ្ធិ និងករណីយកិច្ចដែលសល់ក្រោយពីឆ្លងកាត់នីតិវិធីជម្រះបញ្ជី។ ប៉ុន្តែ ចំពោះសន្តតិកម្មដែលមានសន្តតិជនច្រើននាក់ ក្រោយពេលសហសន្តតិជនបានបង្ហាញឆន្ទៈយល់ព្រមទាំងស្រុង ឬបានបង្ហាញឆន្ទៈយល់ព្រមដោយមានកម្រិត សហសន្តតិជនទាំងអស់ត្រូវធ្វើការបែងចែកមត៌កទៅតាមចំណែកមត៌ករវាងសន្តតិជនម្នាក់ៗ ការសម្រួលចំណែកមត៌ក និងចៀសវាងការបំពានភាគបម្រុងរបស់អ្នកមានសិទ្ធិលើភាគបម្រុង ដូចដែលបានបកស្រាយលម្អិតរួចនៅក្នុងជំពូកទី១ ការបែងចែកនេះអាចធ្វើឡើងនៅពេលណាក៏បានក្រោយអំឡុងពេល ១(មួយ)ខែ គិតចាប់ពីការចាប់ផ្តើមសន្តតិកម្ម។[139] សហសន្តតិជនមានជម្រើសពីរសម្រាប់បែងចែកមត៌ក ទីមួយ គឺការពិភាក្សាបែងចែកមត៌ក(**ចំណុច ២.១**) ទីពីរ គឺការបែងចែកដោយតុលាការ(**ចំណុច ២.២**)។

## ២.១. ការពិភាក្សាបែងចែកមត៌ក

ការពិភាក្សាបែងចែកមត៌កជាវិធីសាស្ត្រដ៏ងាយស្រួលបំផុតក្នុងការបែងចែកមត៌កដែលចំពោះករណីដែលការពិភាក្សារវាងសហសន្តតិជនចំពោះការបែងចែកមត៌កបានសម្រេច ឬអាចពិភាក្សាបាន។ ការពិភាក្សាបែងចែកមត៌ក មិនទាមទារទាល់តែធ្វើការបែងចែកទៅតាមចំណែកមត៌កដែលច្បាប់កំណត់នោះទេ ព្រោះថាការទទួលបន្តមត៌កគឺជាសិទ្ធិរបស់សហសន្តតិជន ដូច្នេះ សហសន្តតិជនអាចធ្វើការចាត់ចែងសិទ្ធិនោះឱ្យផ្ទុយពីចំណែកមត៌កដែលច្បាប់បានកំណត់ឱ្យសន្តតិជនម្នាក់ៗបាន ដោយគ្រាន់តែសហសន្តតិជនបង្ហាញឆន្ទៈយល់ព្រម និងបំពេញទៅតាមទម្រង់ចាំបាច់ដើម្បីផ្ទេរសិទ្ធិនីមួយៗដូចជាលិខិតជាលាយល័ក្ខណ៍អក្សរ ឬលិខិតយថាភូតជាដើមនោះជាការគ្រប់គ្រាន់ហើយ។ ការពិភាក្សាបែងចែកមត៌ក ទោះបីជាបានលទ្ធផលល្អក៏ដោយ ក៏សហសន្តតិជនពុំអាចប្តូរឈ្មោះម្ចាស់សិទ្ធិលើមត៌កទៅឱ្យសន្តតិជនបានដែរ បើអំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ មាត្រា ១២៤៨ ស្តីពីអំឡុងពេលនៃការយល់ព្រម ឬការបោះបង់ បានកន្លងហួស ការកំណត់បែបនេះ គឺដើម្បីការពារម្ចាស់បំណុល។[140]

[139] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១២៦៦ថ្មី កថាខណ្ឌទី១ វាក្យខណ្ឌទី១។

[140] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១២៦៦ថ្មី កថាខណ្ឌទី១ វាក្យខណ្ឌទី២។

នៅក្នុងការពិភាក្សាបែងចែកមត៌ក សហសន្តតិជនត្រូវពិចារណាទៅលើហេតុភេទមួយចំនួនដូចជាមូលដ្ឋាននៃការបែងចែក(២.១.១) សិទ្ធិអាទិភាពរបស់សហព័ទ្ធ(២.១.២) សំណងកាតព្វកិច្ចរបស់មតកជន(២.១.៣) ក្រៅពីនេះយើងត្រូវសិក្សាពីអានុភាពក្រោយការពិភាក្សាបែងចែក(២.១.៤)។

### ២.១.១. មូលដ្ឋាននៃការបែងចែក

នៅពេលមានការបែកចែកមត៌ក សហសន្តតិជនអាចធ្វើការបែងចែកមត៌កដោយពិចារណាទៅលើស្ថានភាពជាច្រើនដូចខាងក្រោម៖[141]

- ប្រភេទ និងលក្ខណៈនៃវត្ថុ ឬសិទ្ធិដែលមានក្នុងមត៌ក
- មុខរបរ
- អាយុ ស្ថានភាពផ្លូវកាយ និងផ្លូវចិត្ត
- ស្ថានភាពជីវភាព និងស្ថានភាពផ្សេងទៀត
- ការចៀសវាងឱ្យមានការខូចខាតធ្ងន់ធ្ងរដល់តម្លៃ

ការបែងចែកដោយផ្អែកទៅលើ ប្រភេទ និងលក្ខណៈនៃវត្ថុ ឬនៃសិទ្ធិដែលមានក្នុងមត៌ក ជាការបែងចែកឱ្យសហសន្តតិជនឱ្យមានការសមស្របទៅតាមប្រភេទ ឬលក្ខណៈនៃវត្ថុ ឬនៃសិទ្ធិដែលមានក្នុងមត៌ក ដូចជាប្រសិនបើនៅក្នុងចំណោមមត៌កទាំងអស់មានចលនវត្ថុជាឡាន ហើយនៅក្នុងចំណោមសហសន្តតិជនមានសន្តតិជនម្នាក់អាយុ ១០ ឆ្នាំ និងសន្តតិជនម្នាក់ទៀតអាយុ ២៥ ឆ្នាំ ដូច្នេះ ការប្រគល់ឡានទៅឱ្យសន្តតិជនអាយុ ២៥ ឆ្នាំមានការសមស្របជាងការប្រគល់ទៅឱ្យសន្តតិជនដែលមានអាយុ ១០ ឆ្នាំ ដែលមិនអាចប្រើប្រាស់រថយន្តស្របតាមច្បាប់។ ចំពោះសហសន្តតិជនខាងលើដដែល ប្រសិនបើនៅក្នុងចំណោមមត៌កទាំងអស់មានសិទ្ធិលើបំណុលដែលជាភាគហ៊ុននៃក្រុមហ៊ុនមួយ ដូច្នេះ ការប្រគល់ភាគហ៊ុននោះទៅឱ្យសន្តតិជនដែលអាយុ ២៥ ឆ្នាំ ក៏ជាការសមរម្យផងដែរ ព្រោះថា សន្តតិជនដែលមានអាយុ ១០ ឆ្នាំ គឺជាជនដែលត្រូវបានកម្រិតសមត្ថភាព។

ការបែងចែកដោយផ្អែកលើមុខរបរ គឺជាការបែងចែកឱ្យមានការសមស្របទៅតាមមុខរបររបស់សហសន្តតិជន ដូចជាប្រសិនបើកាលមតកជននៅរស់បានបើកអាជីវកម្មលាងរថយន្ត ក្រោយពេលមតកជនស្លាប់នៅក្នុងចំណោមមត៌កទាំងអស់មានអចលនវត្ថុដែលជាទីតាំងលាងរថយន្ត និងសម្ភារៈសម្រាប់លាងរថយន្ត ហើយក្នុងចំណោមសន្តតិជនទាំងអស់ មានសន្តតិជនម្នាក់ក៏ជាអ្នកបើកអាជីវកម្មលាងរថយន្តផងដែរ ហើយក៏ធ្លាប់ជួយគ្រប់គ្រងអាជីវកម្មលាងរថយន្តរបស់មតកជនទៀតផង ដូច្នេះ ការប្រគល់ទីតាំងលាងរថយន្ត និងសម្ភារៈសម្រាប់លាងរថយន្តទៅឱ្យសន្តតិជនម្នាក់នោះជាការសមរម្យ។

[141] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១២៦៧។

ការបែងចែកដោយផ្អែកលើអាយុ ស្ថានភាពផ្លូវកាយ និងផ្លូវចិត្ត ជាការបែងចែកឱ្យសមស្របទៅនឹងអាយុ ស្ថានភាពផ្លូវកាយ និងផ្លូវចិត្តរបស់សហសន្តតិជន ដូចជាប្រសិនបើសន្តតិជនជានិច្ច និងសន្តតិជនលំដាប់ទី១ ត្រូវទទួលបន្តនូវរថយន្តមួយគ្រឿងដែលមានតម្លៃ ៤០ លានរៀល និងប្រាក់ក្នុងគណនីធនាគារចំនួន ៤០ លានរៀល ហើយដោយសារសន្តតិជនលំដាប់ទី១ មានចំណូលជាប្រចាំ រីឯ សន្តតិជនជានិច្ចរស់នៅពឹងលើចំណូលរបស់មតកជនកាលនៅរស់ ដោយគ្មានចំណូលផ្ទាល់ខ្លួនឡើយ ដូច្នេះហើយ ការបែងចែកដោយប្រគល់ឡានឱ្យទៅសន្តតិជនលំដាប់ទី១ និងប្រគល់ប្រាក់ក្នុងគណនីធនាគារទៅឱ្យសន្តតិជនជានិច្ចគឺជាការសមរម្យ។

ការបែងចែកដោយផ្អែកលើស្ថានភាពជីវភាព គឺជាការបែកចែកឱ្យសមស្របទៅនឹងស្ថានភាពជីវភាពរបស់សហសន្តតិជន ដូចជាករណីដែលមតកជនបានបន្សល់ទុកមត៌កមួយចំនួន ក្នុងនោះដែរមានផ្ទះមួយខ្នងដែលមតកជនកាលនៅរស់ និងសន្តតិជនជានិច្ចរស់នៅជាមួយគ្នា ហើយសន្តតិជនជានិច្ចគ្មានលំនៅឋានផ្សេងនោះទេ ដូច្នេះហើយ នៅពេលមានការបែងចែកគួរណាស់តែធ្វើការបែងចែកផ្ទះមួយខ្នងនោះទៅឱ្យសន្តតិជនជានិច្ចដើម្បីជីវភាពរស់នៅប្រចាំថ្ងៃ។

ប្រសិនជាការបែងចែកអាចនឹងបណ្តាលឱ្យមានការខូចខាតធ្ងន់ធ្ងរដល់តម្លៃនៃមត៌កណាមួយក្នុងចំណោមមត៌កទាំងអស់ សហសន្តតិជនទាំងអស់អាចព្រមព្រៀងឱ្យសន្តតិជនណាម្នាក់ធ្វើលទ្ធកម្មមត៌កណាមួយនោះបាន ដោយដាក់ល័ក្ខខ័ណ្ឌឱ្យបង់ប្រាក់សម្រួល ចំពោះសហសន្តតិជនផ្សេងទៀត តាមការពិភាក្សាបាន។

ដោយហេតុថា ការពិភាក្សាបែងចែកមានលក្ខណៈជាការបែងចែកដោយសន្តិវិធី និងដោយការព្រមព្រៀងគ្នារវាងសហសន្តតិជន។ ដូច្នេះហើយ នៅក្នុងដំណើរការបែងចែកសហសន្តតិជនអាចធ្វើលទ្ធកម្មលើមត៌កណាមួយ ឬបង់ប្រាក់សម្រួល ឬលទ្ធកម្មដោយអវិភាគ ឬវិធីសាស្ត្រផ្សេងៗទៀត ធ្វើយ៉ាងណាឱ្យសហសន្តតិជនទាំងអស់យល់ព្រមតាមការបែងចែកនោះជាការស្រេច។

### ២.១.២. សិទ្ធិអាទិភាពរបស់សហព័ទ្ធ

ចំពោះសន្តតិជនជានិច្ច ប្រសិនបើកាលមតកជននៅរស់មានទ្រព្យសម្បត្តិដែលបានទទួលជាកម្មសិទ្ធិអវិភាគជាមួយនឹងសន្តតិជនជានិច្ច ឬក៏ជាទ្រព្យរួមប្តីប្រពន្ធ នៅក្នុងការបែងចែកមត៌ក សន្តតិជនជានិច្ចមានសិទ្ធិអាទិភាពជាងសហសន្តតិជនផ្សេងទៀត ក្នុងការទទួលយកចំណែកកម្មសិទ្ធិអវិភាគដែលទាក់ទងនឹងទ្រព្យសម្បត្តិនោះ រហូតដល់គ្រប់ចំនួននៃចំណែកមត៌ករបស់ខ្លួន។[142]

### ២.១.៣. សំណងភាគព្វកិច្ចរបស់មតកជន

នៅក្នុងការពិភាក្សាបែងចែកមត៌ក ប្រសិនបើមតកជនមានបន្សល់ទុកនូវកាតព្វកិច្ច សហសន្តតិជនត្រូវបែងចែកមត៌កដោយគិតពិចារណាទៅលើកាតព្វកិច្ចដែលខ្លួនត្រូវទទួលខុសត្រូវ ក្រោយពេលបែងចែកមត៌ក។

[142] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១២៦៨។

លើសពីនេះទៀត សហសន្តតិជនមិនអាចប្តូរភាគបន្ទុកនៃកាតព្វកិច្ចបានទេ បើមិនមានការអនុញ្ញាតពីម្ចាស់បំណុល។[143]

តាមការបកស្រាយខាងលើយើងសង្កេតថា កាតព្វកិច្ចមិនមែនជាកម្មវត្ថុនៃការបែងចែកនោះទេចំពោះសន្តតិកម្មដែលសហសន្តតិជនបានយល់ព្រមទាំងស្រុង។ ចំណែកឯ សន្តតិកម្មដែលសហសន្តតិជនបានយល់ព្រមដោយមានកម្រិត គឺសហសន្តតិជនធ្វើលទ្ធកម្មតែទ្រព្យសកម្មនៅសល់ពីការជម្រះបញ្ជីប៉ុណ្ណោះ ដូច្នេះប្រសិនបើឈានដល់ដំណាក់កាលបែងចែកមត៌ក មានន័យថាមត៌ករបស់មតកជនពុំមានអត្ថិភាពនៃកាតព្វកិច្ចទៀតនោះទេ ឬអាចនិយាយម៉្យាងទៀតបានថា ការពិភាក្សាបែងចែកមត៌កចំពោះសន្តតិកម្មដែលសហសន្តតិជនបានយល់ព្រមដោយមានកម្រិតមិនអាចពិចារណាលើសំណងកាតព្វកិច្ចរបស់មតកជននោះទេ។

### ២.១.៤. អានុភាពនៃការពិភាក្សាបែងចែក

ការពិភាក្សាបែងចែកមត៌ក មានអានុភាពប្រតិសកម្ម គិតចាប់ពីពេលដែលបានចាប់ផ្តើមសន្តតិកម្ម។ ចំពោះសិទ្ធិរបស់តតិយជនដែលបានចុះបញ្ជី ឬបានទទួលល័ក្ខខ័ណ្ឌតតាំង ការពិភាក្សាបែងចែកមត៌កមិនអាចអនុវត្តបំពានសិទ្ធិនោះបានឡើយ។[144] នៅក្នុងករណីខ្លះ ដូចជាក្រោយពេលចាប់ផ្តើមសន្តតិកម្ម សន្តតិជនណាម្នាក់បានអនុប្បទានចំណែកមត៌ករបស់ខ្លួនទៅឱ្យតតិយជន ឬម្ចាស់បំណុលរបស់សន្តតិជនរឹបអូសនូវចំណែកមត៌ករបស់សន្តតិជនតាមមាត្រា ១២៧៩ ស្តីពីម្ចាស់បំណុលរបស់សន្តតិជន ហើយជនទាំងនោះបានចុះបញ្ជីទៅតាមលក្ខណៈនៃវត្ថុ ឬមានល័ក្ខខ័ណ្ឌតតាំងចំពោះវត្ថុនោះដូចជាការចុះបញ្ជី និងការផ្ទេរការកាន់កាប់ជាដើម នោះអានុភាពនៃការបែងចែកមត៌កមិនអាចអនុវត្តទៅលើសិទ្ធិទាំងនោះបានឡើយ។ ក៏ប៉ុន្តែ សហសន្តតិជនអាចទារសំណងពីសហសន្តតិជនដែលបានធ្វើការចាត់ចែងនូវមត៌កនោះបាន[145] ដោយសារសហសន្តតិជននោះបានបំពានកាតព្វកិច្ចរក្សាទុក និងគ្រប់គ្រងមត៌ក។[146]

"សហសន្តតិជននីមួយៗ ត្រូវទទួលយកលិខិតបញ្ជាក់សិទ្ធិដែលទាក់ទងទៅនឹងទ្រព្យសម្បត្តិដែលខ្លួនបានធ្វើលទ្ធកម្ម។"[147] ដោយសារលទ្ធផលក្រោយការបែងចែក សហសន្តតិជនដែលបានលទ្ធកម្មនូវសិទ្ធិលើទ្រព្យសម្បត្តិណាមួយនោះ សហសន្តតិជនអាចទទួលនូវលិខិត ឬប័ណ្ណ ឬឯកសារផ្សេងៗ ដែលបញ្ជាក់ពីសិទ្ធិលើទ្រព្យសម្បត្តិនោះបាន។

---

[143] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១២៦៩។
[144] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១២៧៣ កថាខណ្ឌទី១ វាក្យខណ្ឌទី២។
[145] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១២៧២។
[146] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១២៦២។
[147] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១២៧៣ កថាខណ្ឌទី២។

ចំពោះការបែងចែកសិទ្ធិលើបំណុលនៅក្នុងចំណោមមត៌កដែលមតកជនមាន ទៅតាមភាគក្រៅពីចំណែកមត៌កដែលកំណត់ដោយច្បាប់ ពុំអាចតតាំងជាមួយកូនបំណុលបានឡើយប្រសិនបើ[148]៖

- សហសន្តតិជនទាំងអស់មិនបានជូនដំណឹងពីការបែងចែកនោះ
- ការបែងចែកនោះត្រូវបានធ្វើដោយលិខិតយថាភូត តែមិនបានបង្ហាញលិខិតនោះ ឬប្រគល់លិខិតចម្លងនោះទៅឱ្យកូនបំណុលទេ។

ផ្ទុយទៅវិញ ប្រសិនបើកូនបំណុលរបស់មតកជន ដែលបានសងសំណងតាមចំណែកមត៌កដែលកំណត់ដោយច្បាប់ ចំពោះសហសន្តតិជន នៅមុនពេលបានទទួលដំណឹងពីសហសន្តតិជន ការសងនោះអាចតតាំងចំពោះសហសន្តតិជនដែលបានធ្វើលទ្ធកម្មសិទ្ធិលើបំណុលតាមការបែងចែកមត៌កនោះបាន។

## ២.២.ការបែងចែកដោយតុលាការ

ប្រសិនបើការពិភាក្សាបែងចែកមត៌កមិនអាចសម្រេចបានទេ សហសន្តតិជនមានជម្រើសមួយទៀតសម្រាប់បែងចែកមត៌កគឺការដាក់ពាក្យសុំបែងចែកមត៌កទៅតុលាការដែលមានសមត្ថកិច្ច(**២.២.១**) ដោយសហសន្តតិជនទាំងអស់នឹងក្លាយជាជនពាក់ព័ន្ធ(**២.២.២**) ការបែងចែកមត៌កដោយតុលាការទាមទារឱ្យអ្នកទទួលខុសត្រូវលើប្រាក់ប្រដាប់ក្តី(**២.២.៣**) ក្រោយពេលតុលាការទទួលពាក្យសុំ តុលាការនឹងចាប់ផ្តើមវិនិច្ឆ័យលើពាក្យសុំបែងចែកមត៌កនោះ(**២.២.៤**) ជាចុងក្រោយ តុលាការធ្វើការសម្រេចសេចក្តីទៅលើពាក្យសុំរបស់សហសន្តតិជនក្រោយការទាញហេតុផលដោយផ្ទាល់មាត់(**២.២.៥**)។

### ២.២.១. សមត្ថកិច្ចសាលាជម្រះក្តី

សមត្ថកិច្ចតុលាការនៅក្នុងរឿងបែកចែកមរតក ត្រូវបានកំណត់នៅក្នុងច្បាប់ស្តីពីរឿងក្តីរដ្ឋប្បវេណីមិនមែនបណ្តឹង ត្រង់តារាងឧបសម្ព័ន្ធ ផ្នែក៥ ចំណុច១៧ ដែលជាតុលាការមានសមត្ថកិច្ចនៅកន្លែងចាប់ផ្តើមសន្តតិកម្ម ហើយជាប្រភេទសមត្ថកិច្ចផ្តាច់មុខ។[149]

### ២.២.២.ជនពាក់ព័ន្ធ និងអ្នកតំណាងដោយអាណត្តិ

ក្នុងចំណោមសហសន្តតិជនទាំងអស់ សហសន្តតិជនម្នាក់ ឬច្រើននាក់ មានឋានៈក្លាយជាជនពាក់ព័ន្ធនៅក្នុងរឿងក្តីបែងចែកមត៌ក។ ក្នុងនោះ សហសន្តតិជនម្នាក់ ឬច្រើននាក់ ដែលបានដាក់ពាក្យសុំមានឋានៈ

[148] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១២៧៥ កថាខណ្ឌទី១។

[149] ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, លេខ នស/រកម/០៧១០/០១៣, ១០ កក្កដា ២០១០, មាត្រា ៤ កថាខណ្ឌទី១។ (ចាប់ពីពេលនេះតទៅហៅថា "ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង") ។

ជាជនដាក់ពាក្យសុំ រីឯ សហសន្តតិជនម្នាក់ ឬច្រើននាក់ផ្សេងទៀត មានឋានៈជាភាគីម្ខាងទៀតនៃពាក្យសុំ។[150] ហើយសហសន្តតិជនទាំងនោះត្រូវតែជាបុគ្គលដែលអាចក្លាយជាប្រធាននៃសិទ្ធិ និងកាតព្វកិច្ច។[151]

ប្រសិនបើសហសន្តតិជនជាអនីតិជន និងជននៅក្រោមអាណាព្យាបាលទូទៅ សកម្មភាពនៃនីតិវិធីសុពលត្រូវធ្វើឡើងដោយអ្នកតំណាងដែលច្បាប់បានកំណត់ លើកលែងក្នុងករណីអនីតិជនអាចធ្វើសកម្មភាពដោយឯករាជ្យ។[152] ប្រសិនបើសហសន្តតិជនជាជននៅក្រោមហិតូបត្ថម្ភ សកម្មភាពនៃនីតិវិធីសុពលអាចធ្វើឡើងដោយគ្មានការយល់ព្រមពីហិតូបត្ថម្ភកៈបាន។[153]

"ជនពាក់ព័ន្ធអាចធ្វើសកម្មភាពទាក់ទងនឹងនីតិវិធីទាំងអស់ ដោយខ្លួនឯងផ្ទាល់ ឬធ្វើសកម្មភាពនោះ ដោយឆ្លងតាមរយៈអ្នកតំណាងដោយអាណត្តិដែលខ្លួនបានជ្រើសតាំង។"[154] អ្នកតំណាងដោយអាណត្តិក្នុងរឿងក្តីមិនមែនបណ្តឹង ត្រូវតែជាមេធាវី ឬជនដែលទទួលការអនុញ្ញាតពីតុលាការ។[155]

### ២.២.៣. ប្រាក់ប្រដាប់ក្តី

នៅក្នុងនីតិវិធីនៃរឿងក្តីបែងចែកមត៌ក សហសន្តតិជនត្រូវទទួលខុសត្រូវទៅលើប្រាក់ប្រដាប់ក្តីដែលមាន ៣ ប្រភេទ គឺពន្ធដាក់ពាក្យសុំ(**២.២.៣.១**) ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ(**២.២.៣.២**) និងប្រាក់ប្រដាប់ក្តីភាគី(**២.២.៣.៣**)។

#### ២.២.៣.១. ពន្ធដាក់ពាក្យសុំ

សហសន្តតិជនដែលដាក់ពាក្យសុំបែងចែកមត៌កត្រូវបង់ពន្ធចំនួន ៥.០០០(ប្រាំពាន់)រៀល។[156]

#### ២.២.៣.២. ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ

ប្រសិនបើក្នុងរឿងក្តីបែងចែកមត៌ក មានសកម្មភាពមួយចំនួនដែលតម្រូវឱ្យបង់ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ តុលាការត្រូវកំណត់នូវចំនួនទឹកប្រាក់ជាក់លាក់ដែលសហសន្តតិជនត្រូវបង់ទៅឱ្យតុលាការតាមរយៈដីកាសម្រេចបង្គាប់បង់ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ ចំពោះការធ្វើសកម្មភាពមួយចំនួនដូចខាងក្រោម៖[157]

---

[150] ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, មាត្រា ១៥។

[151] ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, មាត្រា ១៦។

[152] ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, មាត្រា ១៧ កថាខណ្ឌទី២។

[153] ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, មាត្រា ១៧ កថាខណ្ឌទី៤ និង ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា ៣៣។ (ចាប់ពីពេលនេះតទៅហៅថា "ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦") ។

[154] ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, មាត្រា ១៨ កថាខណ្ឌទី១។

[155] ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, មាត្រា ១៩ កថាខណ្ឌទី១។

[156] ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, មាត្រា ២២ កថាខណ្ឌទី១។

[157] ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, មាត្រា ២២ កថាខណ្ឌទី២ និង ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦, មាត្រា ៦២។

• ការពិនិត្យភស្តុតាង ការបញ្ជូនឯកសារ ឬសកម្មភាពផ្សេងទៀតនៅក្នុងនីតិវិធីរឿងក្តីដូចជា កម្រៃនៃការបកប្រែឯកសារដែលធ្វើឡើងដោយតុលាការជាដើម

• សោហ៊ុយធ្វើដំណើរ និងសោហ៊ុយស្នាក់នៅដែលចាំបាច់សម្រាប់ចៅក្រម និងក្រឡាបញ្ជី ក្នុងករណីដែលត្រូវធ្វើការពិនិត្យភស្តុតាង ការស្រាវជ្រាវអង្គហេតុ ឬសកម្មភាពផ្សេងទៀតដែលប្រព្រឹត្តនៅក្រៅតុលាការដូចជាការសាកសួរសហសន្តតិជនដែលកំពុងសម្រាកនៅមន្ទីរពេទ្យជាដើម។

### ២.២.៣.៣. ប្រាក់ប្រដាប់ក្តីភាគី

ប្រាក់ប្រដាប់ក្តីភាគី គឺជាចំនួនទឹកប្រាក់ដែលសហសន្តតិជនបានបង់ចំពោះសកម្មភាពស្នើសុំរបស់ខ្លួនទៅកាន់តុលាការ ហើយតុលាការកំណត់ថាសមរម្យដោយគិតពិចារណានូវលក្ខណៈនៃរឿងក្តី ឬលទ្ធភាពទ្រព្យធនរបស់សហសន្តតិជនជាអាទិ៍ ចំនួនទឹកប្រាក់ទាំងនោះអាចជា៖[158]

• ថ្លៃធ្វើលិខិត ដូចជា លិខិតពាក្យសុំ ឬឯកសារផ្សេងៗ ដូចជា ឯកសារត្រៀម ជាអាទិ៍ និងថ្លៃដាក់ឯកសារនោះទៅតុលាការ

• សោហ៊ុយធ្វើដំណើរ ប្រាក់ឧបត្ថម្ភប្រចាំថ្ងៃ និងសោហ៊ុយស្នាក់នៅសម្រាប់ភាគី និងអ្នកតំណាង ដើម្បីបង្ហាញខ្លួនតាមកាលបរិច្ឆេទដែលបានកំណត់

• សោហ៊ុយផ្សេងទៀត ដែលតុលាការទទួលស្គាល់ថាជាសោហ៊ុយចាំបាច់សម្រាប់ការអនុវត្តនូវនីតិវិធីបណ្តឹង។

## ២.២.៤. ការវិនិច្ឆ័យ

សហសន្តតិជនដែលមិនអាចពិភាក្សាបែងចែកមត៌កបាន ត្រូវដាក់ពាក្យសុំបែងចែកមត៌កទៅតុលាការ(**២.២.៤.១**) រួចធ្វើការអះអាងបញ្ជាល់ពីការទាមទាររបស់ខ្លួននៅក្នុងនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់(**២.២.៤.២**)។

### ២.២.៤.១. ពាក្យសុំបែងចែកមត៌ក និងចំណុចដែលត្រូវសរសេរក្នុងពាក្យសុំ

ពាក្យសុំបែងចែកមត៌កអាចត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់បាន។[159] ប៉ុន្តែ ក្នុងការអនុវត្តជាក់ស្តែងរួមទាំងដើម្បីបញ្ជាក់ពីឆន្ទៈច្បាស់លាស់ក្នុងការស្នើសុំ សហសន្តតិជនម្នាក់ ឬ សហសន្តតិជនច្រើននាក់គួរដាក់ពាក្យសុំបែងចែកមត៌ក ជាលាយល័ក្ខណ៍ទៅកាន់តុលាការចំពោះសហសន្តតិជនទាំងអស់ផ្សេងទៀតដែលជាភាគីម្ខាងទៀត។

[158] ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, មាត្រា ២២ កថាខណ្ឌទី២ និង ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦, មាត្រា ៦៣។

[159] ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, មាត្រា ២៦ កថាខណ្ឌទី១។

ថ្វីត្បិតតែករណីនេះជាការដាក់ពាក្យសុំបែងចែកមត៌ក ក៏ប៉ុន្តែនៅក្នុងការអនុវត្តជាក់ស្តែង ជនដាក់ពាក្យសុំ ឬអ្នកតំណាងដោយអាណត្តិ មិនបានធ្វើពាក្យសុំដោយជ្រើសរើសចំណងជើងថា ពាក្យសុំបែងចែកមត៌កតែម្តងទេ ដោយអាចមកពីមូលហេតុជនដាក់ពាក្យសុំបានស្នើសុំនូវចំណុចច្រើនទៅក្នុងពាក្យសុំតែមួយ ឬការណ៍ដែលជនដាក់ពាក្យសុំមិនមានមូលដ្ឋានផ្នែកច្បាប់គ្រប់គ្រាន់ ឬក្នុងករណីខ្លះទៀតអ្នកតំណាងដោយអាណត្តិធ្វើតាមអ្វីដែលជនពាក់ព័ន្ធចង់បាន។ គេសង្កេតឃើញមានការកំណត់ខុសៗគ្នាទៅលើចំណងជើងនៃពាក្យសុំដែលធ្លាប់មានប្រើប្រាស់នៅក្នុងការអនុវត្តជាក់ស្តែងដូចជា ពាក្យសុំបែងចែកមត៌ក ពាក្យសុំទទួលស្គាល់មត៌ក ជាដើម។ ទោះបីជាមានការប្រើប្រាស់ពាក្យពេចន៍ខុសក៏ដោយ ក៏ជាធម្មតាតុលាការព្រមទទួលស្គាល់ពាក្យសុំបែបនោះដែរ អ្វីដែលសំខាន់នោះគឺការស្នើសុំនោះស្របតាមច្បាប់ និងបានបំពេញទម្រង់នៃពាក្យសុំដែលច្បាប់តម្រូវ។

នៅក្នុងលិខិតនៃពាក្យសុំបែងចែកមត៌កត្រូវសរសេរបញ្ជាក់នូវចំណុចសំខាន់ៗដូចខាងក្រោម៖[160]

- ឈ្មោះ ឬនាមករណ៍ និង អាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំ និង អ្នកតំណាងដោយអាណត្តិបើមាន
- ឈ្មោះ ឬនាមករណ៍ និង អាសយដ្ឋានរបស់ភាគីម្ខាងទៀតនៃពាក្យសុំ និង អ្នកតំណាងដោយអាណត្តិ បើមាន
- ខ្លឹមសារនៃដីកាសម្រេចដែលអ្នកដាក់ពាក្យសុំទាមទារ
- អង្គហេតុដែលជាមូលហេតុនៃការទាមទារ
- ឯកសារជាភស្តុតាង

ចំពោះ ឈ្មោះ ឬនាមករណ៍ និង អាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំ គឺជាចំណុចសំខាន់ដែលផ្តល់ភាពច្បាស់លាស់ និងងាយស្រួលដល់ដំណើរការនីតិវិធីបន្តបន្ទាប់របស់តុលាការដូចជា ការកោះហៅ ការបញ្ជូនដីកាសម្រេចជាដើម។ ក្នុងករណីខ្លះដែលអ្នកដាក់ពាក្យសុំបានស្វែងរកអ្នកតំណាងដោយអាណត្តិដើម្បីតំណាងតាមរយៈការប្រគល់សិទ្ធិរបស់ខ្លួននោះ នៅក្នុងពាក្យសុំក៏ចាំបាច់ត្រូវសរសេរបញ្ជាក់ពីឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋានរបស់អ្នកតំណាងដោយអាណត្តិផងដែរ ហើយគោលបំណងគឺស្រដៀងគ្នានឹងអ្នកដាក់ពាក្យសុំដែរ គ្រាន់តែអ្នកតំណាងដោយអាណត្តិដែលភាគច្រើនជាមេធាវីនោះ មិនទទួលការកោះហៅពីតុលាការទេ តែមេធាវីទទួលការអញ្ជើញពីតុលាការតាមរយៈលិខិតអញ្ជើញ។

ចំពោះ ឈ្មោះ ឬនាមករណ៍ និង អាសយដ្ឋានរបស់ភាគីម្ខាងទៀតនៃពាក្យសុំ និង អ្នកតំណាងដោយអាណត្តិ ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង មិនបានកំណត់ឱ្យត្រូវតែមាននោះទេ ប៉ុន្តែការសរសេរបញ្ជាក់បែបនេះមានគោលបំណងដូចគ្នានឹងការសរសេរបញ្ជាក់ ឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំ ឬអ្នកតំណាងដោយអាណត្តិខាងលើដែរ។

[160] ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, មាត្រា ២៦ កថាខណ្ឌទី២។

ចំពោះខ្លឹមសារនៃដីកាសម្រេច គឺជាអ្វីដែលអ្នកដាក់ពាក្យសុំចង់បាន ប៉ុន្តែពុំមែនគ្រប់ករណីទាំងអស់តុលាការសម្រេចតាមអ្វីដែលអ្នកដាក់ពាក្យសុំបានទាមទារនោះទេ ពោលគឺការសម្រេចសេចក្តីរបស់តុលាការគឺផ្អែកលើច្បាប់ត្រឹមកម្រិតនៃការស្នើសុំ ដោយពិនិត្យលើការស្នើសុំរបស់ភាគី។

ចំពោះអង្គហេតុដែលជាមូលហេតុនៃការទាមទារ គឺជាអង្គចម្បងដែលនាំឱ្យសហសន្តតិជនដាក់ពាក្យសុំ អង្គហេតុនេះមិនមែនជាអង្គហេតុទាំងមូលជុំវិញដំណើររឿងដែលគេហៅថា អង្គចាំបាច់ដើម្បីបញ្ជាក់ពីការទាមទារនោះទេ ពោលគឺអង្គហេតុដែលជាមូលហេតុនៃការទាមទារនេះ គឺជាអង្គហេតុមួយផ្នែកដែលនាំឱ្យសហសន្តតិជនមានមូលហេតុគ្រប់គ្រាន់សម្រាប់ដាក់ពាក្យស្នើសុំ។

ចំណែកឯកសារជាភស្តុតាង គឺជាឯកសារដែលជនដាក់ពាក្យសុំត្រូវភ្ជាប់ជូនតុលាការពិនិត្យ។ ក្នុងករណីបែងចែកមត៌កនេះ ភស្តុតាងដែលជនដាក់ពាក្យសុំត្រូវភ្ជាប់ជូនតុលាការពិនិត្យអាចមានដូចខាងក្រោម៖

- សំបុត្រមរណភាពរបស់មតកជន
- សៀវភៅគ្រួសារ សៀវភៅស្នាក់នៅ សំបុត្រអាពាហ៍ពិពាហ៍ សំបុត្រកំណើត ដីកាសម្រេចអំពីការបង្កើតស៊ុំកូនធម្មតា ឬដីកាសម្រេចអំពីការបង្កើតស៊ុំកូនពេញលេញជាដើម ដើម្បីបញ្ជាក់ពីអត្ថិភាពនៃសហសន្តតិជន
- បញ្ជីសារពើភ័ណ្ឌនៃមត៌ករបស់មតកជន ដោយរួមបញ្ចូលទាំងឯកសារយោងនៃសិទ្ធិ ឬកាតព្វកិច្ចក្នុងនោះផងដែរ

### ២.២.៤.២. ការទាញហេតុផលដោយផ្ទាល់មាត់

ការចេញដីកាសម្រេចអំពីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងពុំចាំបាច់ឆ្លងកាត់តាមការទាញហេតុផលដោយផ្ទាល់មាត់ឡើយ។[161] ក៏ប៉ុន្តែ នៅក្នុងការបែងចែកមត៌ក ការសាកសួរសហសន្តតិជនពីមូលហេតុដែលនាំឱ្យការពិភាក្សាបែងចែកមត៌កមិនបានសម្រេច ឬមូលហេតុដែលនាំឱ្យសហសន្តតិជនមិនយល់ស្របតាមការពិភាក្សាបែងចែកមត៌ក ជាការសំខាន់។ នៅក្នុងពេលបែងចែកមត៌ក សហសន្តតិជនពុំអាចអះអាងថាខ្លួនមិនពេញចិត្តនូវចំណែកមត៌កដែលខ្លួននឹងត្រូវទទួលឡើយ ព្រោះថាចំណែកមត៌កនោះគឺកំណត់ដោយច្បាប់ទៅតាមសន្តតិជនម្នាក់ៗ ដូច្នេះ សហសន្តតិជនពុំអាចធ្វើវិវាទដោយយកមូលហេតុនេះបានឡើយ។

នៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់ចំពោះការបែងចែកមត៌កដោយតុលាការ តុលាការត្រូវធ្វើការពិចារណាទៅលើមូលដ្ឋាននៃការបែងចែក សិទ្ធិអាទិភាពរបស់សហាព័ទ្ធ និងសំណងនៃកាតព្វកិច្ចរបស់មតកជនដូចទៅនឹងការពិភាក្សាបែងចែកមត៌កដូចគ្នា ក្រៅពីនោះ តុលាការក៏គួរពិចារណាទៅលើទំនៀមទម្លាប់នៅក្នុងតំបន់ និងមតិលើសពីពាក់កណ្តាលដែលសមរម្យរបស់សហសន្តតិជនផងដែរ។[162]

---

[161] ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, មាត្រា ២៨។

[162] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ១២៧០ កថាខណ្ឌទី២។

នៅក្នុងនីតិវិធីនេះ តុលាការក៏ត្រូវធ្វើការសម្រួលចំណែកមត៌ក និងការការពារភាគបម្រុងរបស់អ្នកមានសិទ្ធិលើភាគបម្រុងផងដែរ ក៏ប៉ុន្តែ សកម្មភាពទាំងនោះអាចធ្វើទៅបានដោយផ្អែកតាមព័ត៌មានដែលសហសន្តតិជនបានកំណត់នៅក្នុងបញ្ជីសារពើភ័ណ្ឌ ឬការអះអាងទាមទារពីការសម្រួលចំណែកមត៌ករបស់សហសន្តតិជនដោយលើកមូលហេតុសន្តតិជនផ្សេងទៀតទទួលបានប្រទានកម្មច្រើន ឬហេតុដែលខ្លួនបានធ្វើវិភាគទានពិសេស ឬការអះអាងទាមទារភាគបម្រុងរបស់សហសន្តតិជនដែលត្រូវបានបំពានភាគបម្រុង និងដោយផ្អែកតាមភស្តុតាងជាដើម។

### ២.២.៥. សេចក្តីសម្រេច

ក្រោយឆ្លងកាត់នីតិវិធីនៃការទាញហេតុផលផ្ទាល់មាត់ តុលាការនឹងធ្វើការសម្រេចសេចក្តីដោយចេញដីកាសម្រេច(**២.២.៥.១**) ហើយដីកាសម្រេចនេះត្រូវជូនដំណឹងទៅជនពាក់ព័ន្ធក្នុងរឿងក្តី(**២.២.៥.២**) បន្ទាប់មកសហសន្តតិជនត្រូវរង់ចាំការចូលជាស្ថាពរដីកាសម្រេច(**២.២.៥.៣**) មុននឹងអាចអនុវត្តដីកាសម្រេចបាន(**២.២.៥.៤**)។

#### ២.២.៥.១. ដីកាសម្រេចបែងចែកមត៌ក

តុលាការត្រូវសម្រេចសេចក្តីដោយធ្វើជាលាយលក្ខណ៍អក្សរ ដែលហៅថាដីកាសម្រេចបែងចែកមត៌ក។ ដីកានេះត្រូវសរសេរសំអាងហេតុ និងសេចក្តីសម្រេចបញ្ចប់ ហើយមានការចុះហត្ថលេខាដោយចៅក្រម។[163]

#### ២.២.៥.២. ការជូនដំណឹងអំពីដីកាសម្រេចបែងចែកមត៌ក

ដីកាសម្រេចអំពីការបែងចែកមត៌កត្រូវជូនដំណឹងទៅសហសន្តតិជនដែលជាអ្នកដាក់ពាក្យសុំ និងសហសន្តតិជនដែលជាភាគីម្ខាងទៀតនៃពាក្យសុំ ដែលត្រូវទទួលដីកាសម្រេចនេះ។ ការជូនដំណឹងអំពីដីកាសម្រេចពីការបែងចែកមត៌កត្រូវធ្វើឡើងតាមរយៈការបញ្ជូន ឬការផ្ញើជូនឯកសារចម្លងយថាភូតនៃដីកាសម្រេចអំពីការការបែងចែកមត៌កនោះ។[164]

ការបញ្ជូនអាចជាការបញ្ជូនដោយការប្រគល់[165] ឬការបញ្ជូនជាសាធារណៈ[166]។

---

[163] ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, មាត្រា ៣៥។

[164] ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, មាត្រា ៣៦។

[165] ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, មាត្រា ៣៦ និង ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦, មាត្រា ២៤៧។

[166] ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, មាត្រា ៣៦ និង ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦, មាត្រា ២៥៥។

### ២.២.៥.៣. ការចូលជាស្ថាពររបស់ដីកាសម្រេចបែងចែកមត៌ក

ចំពោះដីកាសម្រេចបែងចែកមត៌កត្រូវចូលជាស្ថាពរក្រោយផុតអំឡុងពេល ២(ពីរ)សប្តាហ៍ នៃការប្តឹងជំទាស់។[167] អំឡុងពេលនៃការប្តឹងជំទាស់ត្រូវគិតចាប់ពីថ្ងៃបានទទួលការជូនដំណឹងអំពីដីកាសម្រេចបែងចែកមត៌ក។[168]

ក្រោយផុតអំឡុងពេលខាងលើ ជនពាក់ព័ន្ធ ឬអ្នកតំណាងដោយអាណត្តិរបស់ជនទាំងនោះត្រូវដាក់ពាក្យសុំបញ្ជាក់ការចូលជាស្ថាពរនៃដីកាសម្រេចទៅកាន់តុលាការ។[169] បន្ទាប់មកតុលាការនឹងចេញលិខិតបញ្ជាក់ការចូលជាស្ថាពរនៃដីកាសម្រេចបែងចែកមត៌កសម្រាប់សហសន្តតិជនយកទៅប្រើប្រាស់តាមច្បាប់។

ដីកាសម្រេចបែងចែកមត៌កដែលបានចូលជាស្ថាពរ ត្រូវក្លាយជាលិខិតអនុវត្តដែលកំណត់ក្នុងមាត្រា ៣៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណី[170] ស្តីពី លិខិតអនុវត្ត។

### ២.២.៥.៤. អានុភាពអនុវត្តនៃដីកាសម្រេចបែងចែកមត៌ក

សហសន្តតិជនដែលជាជនពាក់ព័ន្ធអាចយកដីកាសម្រេចបែងចែកមត៌កដែលបានចូលជាស្ថាពរទៅដាក់ពាក្យសុំរូបមន្តអនុវត្តនៃដីកាសម្រេចបែងចែកមត៌កបាន។[171]

ក្រោយពេលទទួលបានរូបមន្តអនុវត្តដីកាសម្រេចបែងចែកមត៌ក សហសន្តតិជនដែលជាជនពាក់ព័ន្ធអាចប្រើប្រាស់រូបមន្តអនុវត្តនោះទៅបែងចែកមត៌កតាមខ្លឹមសារនៃដីកាសម្រេចបែងចែកមត៌កបាន។

[167] ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, មាត្រា ៣៧ កថាខណ្ឌទី១។
[168] ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, មាត្រា ៤០ កថាខណ្ឌទី១។
[169] ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, មាត្រា ៣៧ និង ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦, មាត្រា ១៩៣។
[170] ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, មាត្រា ៣៨។
[171] ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, មាត្រា ៣៨ និង ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦, មាត្រា ៣៤៩។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

កើត ចាស់ ឈឺ ស្លាប់ គឺជាទិដ្ឋភាពមួយដែលកើតឡើងជាប្រចាំក្នុងសង្គម។ ម្យ៉ាងវិញទៀត ការណ៍ដែលមតកជនពុំបានបន្សល់ទុកនូវលិខិតបណ្តាំនៅពេលដែលលខ្លួនមានជីវិតគឺបានបង្កនូវបញ្ហាស្មុគស្មាញក្រោយពេលមតកជនស្លាប់។ អាស្រ័យហេតុនេះសន្តតិកម្មតាមច្បាប់ និងនីតិវិធីបានដើរតួនាទីយ៉ាងសំខាន់ដើម្បីជាប្រយោជន៍ចៀសវាងនូវទំនាស់ក្នុងការបែងចែកមរតក។

ក្រោយការខិតខំប្រឹងប្រែងសិក្សាស្រាវជ្រាវយ៉ាងលម្អិត លើប្រធានបទ"**នីតិវិធីក្នុងការទទួលបានសន្តតិកម្មតាមច្បាប់(ករណីគ្មានមតកសាសន៍ និងគ្មានធាតុផ្សំបរទេសរួមបញ្ចូល)**" យើងអាចធ្វើការសន្និដ្ឋានបានថា សន្តតិកម្មតាមច្បាប់ដែលបានបញ្ញត្តិក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ គឺបានកំណត់គ្រប់គ្រាន់ពីភាពគ្រប់លក្ខណៈសម្បត្តិជាសន្តតិជន និងសិទ្ធិលើមត៌ករបស់ខ្លួន។ សន្តតិកម្មត្រូវបានចាប់ផ្តើមដោយសារមរណៈភាពរបស់មតកជន។ ក្រោយពេលសន្តតិកម្មបានចាប់ផ្តើម ថ្វីត្បិតតែមានគោលការណ៍ទទួលបន្តដោយស្វ័យប្រវត្តិ ប៉ុន្តែច្បាប់បានធ្វើការសម្របសម្រួលដោយកំណត់អំឡុងពេលសមរម្យមួយដល់សន្តតិជនដើម្បីសម្រេចចិត្តថាទទួលយក ឬបោះបង់នូវសន្តតិកម្មដែលមានចំពោះខ្លួន។ សន្តតិជនអាចទទួលយកនូវចំណែកមត៌កទាំងស្រុង ប៉ុន្តែប្រសិនបើយល់ថាការការទទួលយកនោះនឹងអាចធ្វើឱ្យប៉ះពាល់ប្រយោជន៍នាពេលអនាគត សន្តតិជនអាចយល់ព្រមដោយមានកម្រិត ឬបោះបង់នូវចំណែកមរតករបស់ខ្លួនបាន ហេតុដូច្នេះ ទើបការសម្រេចចិត្តរបស់សន្តតិជន គឺពិតជាមានសារៈសំខាន់យ៉ាងខ្លាំងក្នុងរបបសន្តតិកម្ម ព្រោះប្រសិនបើធ្វើការសម្រេចចិត្តមិនត្រឹមត្រូវទេ នោះនឹងអាចផ្តល់ផលប៉ះពាល់ដល់សន្តតិជនខ្លួនឯងផ្ទាល់។ បន្ថែមពីនេះទៀត ក្រមនេះក៏បានធានានូវសមភាពនៃការទទួលបន្តនូវមត៌កផងដែរតាមរយៈវិធានការណ៍សម្រួលចំណែកមត៌ក ឬការការពារនូវភាគបម្រុងរបស់អ្នកមានសិទ្ធិ ក៏ដូចជាជម្រើសនៃការបែងចែកមត៌កផងដែរ។ នៅក្នុងការបែងចែកមត៌កសហសន្តតិជនអាចបែងចែកដោយការពិភាក្សា ឬបើការពិភាក្សាពុំបានសម្រេចការបែងចែកត្រូវធ្វើដោយតុលាការតាមពាក្យសុំ។

ការបែងចែកមត៌កដោយតុលាការត្រូវអនុវត្តតាមច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង និងក្រមនីតិវិធីរដ្ឋប្បវេណី។ សហសន្តតិជនត្រូវដាក់ពាក្យសុំទៅតុលាការដែលមានសមត្ថកិច្ច ដោយតាំងខ្លួនជាជនពាក់ព័ន្ធ និងត្រូវទទួលខុសត្រូវលើបន្ទុកនៃប្រាក់ប្រដាប់ក្តី។ ក្រោយពេលតុលាការទទួលពាក្យសុំថាត្រូវតាមទម្រង់ តុលាការត្រូវធ្វើការទាញហេតុផលដោយផ្ទាល់មាត់មុននឹងឈានដល់ការសម្រេចសេចក្តី។ សហសន្តតិជនអាចយកដីកាសម្រេចទៅអនុវត្តបានក្រោយពេលដីកាសម្រេចនោះបានចូលជាស្ថាពរ និងបានសុំរូបមន្តអនុវត្ត។

# អនុសាសន៍

# អនុសាសន៍

តាមរយៈការសិក្សាស្រាវជ្រាវ និងចងក្រងនូវអត្ថបទសារណាលើប្រធានបទ **"នីតិវិធីក្នុងការទទួលបានសន្តតិកម្មតាមច្បាប់(ករណីគ្មានមតកសាសន៍ និងគ្មានធាតុផ្សំបរទេសរួមបញ្ចូល)"** យើងខ្ញុំអាចសង្កេតបានថា សន្តតិកម្មគឺជាយន្តការមួយយ៉ាងសំខាន់ក្នុងការផ្ទេរបន្តនូវមត៌កពីមតកជន ទៅសហសន្តតិជន ហើយត្រូវធានាឱ្យបាននូវតម្លាភាពរវាងសន្តតិជនម្នាក់ៗ។ ដើម្បីទទួលបាននូវភាពស្មើគ្នានេះទៀតសោតគឺចាំបាច់ស្វែងយល់នូវលក្ខខណ្ឌមួយចំនួនដូចជាសន្តតិជនចាំបាច់ត្រូវមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាសន្តតិជន។ ផ្ទុយមកវិញប្រសិនបើសន្តតិជនណាមួយត្រូវបានក្លាយជាអភ័ព្វបុគ្គល ឬត្រូវបានកាត់ផ្តាច់ពីសន្តតិកម្ម សន្តតិជនរូបនោះពុំមានសិទ្ធិក្នុងការទទួលបាននូវមត៌កឡើយ។ មួយវិញទៀត នីតិវិធីនៃការទទួលបាននូវសន្តតិកម្ម និងសិទ្ធិក្នុងការទទួលបន្តនូវសន្តតិកម្មពុំទាន់យល់ដឹងទូលំទូលាយនៅឡើយទេ ដោយហេតុថាទ្រឹស្តីគតិយុត្តិនៅកមានលក្ខណៈស្មុគស្មាញ រីឯការអនុវត្តជាក់ស្តែងពុំសូវមានការយកចិត្តទុកដាក់លើលក្ខខណ្ឌ។ ហេតុនេះ យើងខ្ញុំសំណូមពរទៅដល់ស្ថាប័នរដ្ឋ គ្រឹះស្ថានអប់រំ អ្នកជំនាញវិជ្ជាជីវៈ ធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយនូវបទប្បញ្ញត្តិទាក់ទងនឹងសន្តតិកម្មតាមច្បាប់ជូនទៅដល់សាធារណៈជនទូទៅ អ្នកសិក្សាផ្នែកច្បាប់ ដើម្បីធានានូវការអនុវត្តសិទ្ធិសន្តតិកម្មរបស់សន្តតិជន ឬម្ចាស់បំណុលរបស់មតកជន ឬម្ចាស់បំណុលរបស់សន្តតិជន ឱ្យស្របតាមច្បាប់ចៀសវាងការបំពានសិទ្ធិ ព្រមទាំងធានាការពារនូវកម្មសិទ្ធិទ្រព្យសម្បត្តិឯកជនរបស់ប្រជាជនទូទៅទោះបីជាម្ចាស់កម្មសិទ្ធិបានទទួលមរណភាពហើយក្តី។

ជាចុងក្រោយ ក្នុងនាមជាបញ្ញាវន្តជំនាន់ថ្មី និងជាទំពាំងស្នងឫស្សី យើងខ្ញុំសង្ឃឹម និងមានជំនឿយ៉ាងមុតមាំថា រាជរដ្ឋាភិបាល មន្ត្រីមានសមត្ថកិច្ចគ្រប់ជាន់ថ្នាក់ មិត្តនិស្សិតដែលមានជំនាញខាងនីតិសាស្ត្រ និងប្រជាពលរដ្ឋគ្រប់រូបនឹងព្យាយាមពង្រីកការយល់ដឹង និងពង្រឹងសមត្ថភាពលើវិស័យច្បាប់ទាំងឯកជន និងសាធារណៈដើម្បីធានាឱ្យបាននូវវិសាលភាពពេញលេញក្នុងការអនុវត្តដែលអាចជាប្រយោជន៍រួមសម្រាប់សង្គមជាតិបានទៀតផង។

# ឯកសារយោង

# ឯកសារយោង

## ច្បាប់

ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី, លេខ នស/រកម/០៥១១/០០៧, ៣១ ឧសភា ២០១១។

ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, លេខ នស/រកម/០៧១០/០១៣, ១០ កក្កដា ២០១០។

ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦។

## សៀវភៅ

គណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់. ២០០៧. *សន្ទានុក្រមពាក្យច្បាប់ ខ្មែរ~អង់គ្លេស~បារាំង ផ្នែករដ្ឋប្បវេណី និង នីតិវិធីរដ្ឋប្បវេណី.* បោះពុម្ពលើកទី១. កន្លែងបោះពុម្ព៖ ទីស្តីការគណៈរដ្ឋមន្ត្រី។

គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី និងក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី. ២០០៩. *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី*, ភាគ១, *គន្ថីទី១-ទី៣.* ភ្នំពេញ៖ ក្រសួងយុត្តិធម៌។

គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី និងក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី. ២០០៩. *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី*, ភាគ៥, *គន្ថីទី៧.* ភ្នំពេញ៖ ក្រសួងយុត្តិធម៌។

គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី និងក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី. ២០០៩. *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី*, ភាគ៦, *គន្ថីទី៨-ទី៩.* ភ្នំពេញ៖ ក្រសួងយុត្តិធម៌។